ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 28-Nov-2016, 14:08
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦**

**ម៉ោង ០៨:៥៩ នាទី**

**សវនាការលើកទី៤៤៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ឹយ

កញ្ញា អេវេលីន ខាំផូស សង់ចេស

*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន

*(Mr. Nicolas KOUMJIAN)*

លោក សេង លាង

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោកស្រី ដូរីន ជិន*(Mrs.Doreen CHEN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក សេង លាង | ខ្មែរ |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោកស្រី ដូរីន ជិន | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ស៊ូ សុធារី (2-TCCP-224) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ស៊ុំ សុធាវី/ស៊ុំ សុទ្ធាវី** (2-TCCP-224)

សួរបន្តដោយលោក លោក នីកូឡាស គូមជែន ផ្តើមពី ........ ទំព័រ ៣
សួរដោយលោក លើវ សុវណ្ណា ផ្តើមពី ........ ទំព័រ ១១
សួរដោយលោកស្រី ដូរីន ជិន ផ្តើមពី ........ ទំព័រ ២៩
សួរដោយលោក គង់ សំអុន ផ្តើមពី ........ ទំព័រ ៣៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៩:១៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ស៊្វ សុធាវី បញ្ចប់ ហើយនិងចាប់ផ្តើមសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-264។ ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយ-ការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលទាំងឡាយ ដែលអង្គជំនុំជម្រះកោះអញ្ជើញចូលរួមក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។ សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោកស្រី ស៊្វ សុធាវី។ លោកស្រីមានវត្តមានរួចហើយ នៅក្នុងបន្ទប់សវនាការ។ នៅថ្ងៃនេះដែរ មានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូប ដែលមានរហស្សនាម 2-TCCP-264។ សូមអរគុណលោកប្រធាន។

[០៩:០១:៤១]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោក ឯម ហ៊ុយ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ដែលបានបញ្ជាក់

ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន មិនអាចផ្ដង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធផលចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦។

មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះមានអាការៈឈឺចង្កេះ និងវិលមុខ បានផ្ដល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៣:១០]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្ត សូមជូនវេទិកាទៅព្រះរាជអាជ្ញាសួរដើមបណ្ដឹងរដ្ឋប្បវេណីបន្តទៀត។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក នីកូឡាស គូមជែន៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។

**ស៖** ខ្ញុំសូមប្ដូរប្រធានបទនៅព្រឹកនេះ ហើយនិងសួរទៅលោកស្រីនូវសំណួរខ្លះៗពាក់ព័ន្ធទៅនឹង

ការឃុំខ្លួនរបស់លោកស្រីនៅតាមមន្ទីរឃុំឃាំងផ្សេងៗ ដែលលោកស្រីបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាច្រើន។ លោកស្រីបានលើកឡើងអំពីការឃុំខ្លួនរបស់លោកស្រីនៅក្រាំងជ័យ បើសិនណាជាអានមិនច្រឡំទេ តើគេឃុំនៅក្រាំងជ័យនេះ អស់រយៈពេលប៉ុន្មានដែរ?

[០៩:០៥:៤២]

**លោក សេង លាង៖**

មិនមែនក្រាំងជ័យទេ គឺឃុំឃាំងនៅក្រាំងឆេះ។

**លោកស្រី ស៊ូ សុធាវី៖**

**ឆ៖** ខ្ញុំត្រូវគេឃុំខ្លួននៅក្រាំងឆេះ ក្នុងឃុំអង្គខ្នុរ ជាមណ្ឌលកែប្រែរបស់ឃុំ។ ខ្ញុំអត់ចាំថ្ងៃចាំអីទាំងអស់ទេ ព្រោះក្នុងពេលឃុំខ្លួននោះមានរយៈយូរ ខ្ញុំមិនអាចចាំបាន។

**ស៖** លោកស្រីរកនឹកឃើញទេ នៅពេលដែលលោកស្រីចូលទៅដល់កន្លែងឃុំឃាំងនេះ <> លោកស្រី<បានឃើញអ្វី? តើលោកស្រី>មាននឹកឃើញមានអ្វីនៅលើជញ្ជាំងអីដែរឬទេ?

**ឆ៖** គឺទៅដល់ថ្ងៃមុនដំបូង ពួកយើងដឹងហើយស្រេច គេឲ្យទៅកន្លែងសួរចម្លើយ។ កន្លែងសួរចម្លើយនេះគេមានព្យួរតាំងពីញញួរ តាំងពីខ្សែតី តាំងពីប្រដាប់ដកក្រចក សព្វគ្រប់ទាំងអស់។ គេថាបើគេសួរអក្សរ “ក” ឆ្លើយអក្សរ “ក”, សួរអក្សរ “ខ” ឆ្លើយអក្សរ “ខ” តាមគេទាំងអស់។

**ស៖** តើលោកស្រីធ្លាប់បានឮអ្នកដទៃទៀតដែលត្រូវបានគេ<សួរចម្លើយ> – ខ្ញុំសួរពីនេះវិញ តើលោកស្រីមានបានដឹងថាអ្នកដែលជាប់ឃុំឃាំងនោះ ត្រូវបានគេ<សួរចម្លើយ>ដែរឬទេ?

**ឆ៖** មិនបានឃើញផ្ទាល់ភ្នែកទេ។ ពេលគេធ្វើទារុណកម្មនោះ គឺកន្លែងគេមានធ្វើទារុណកម្មប៉ុន្តែយប់ឡើងម៉ោងពីរដណ្តប់យប់ ម៉ោងមួយ ឮសូរស្រែកឲ្យគ្រលួច។ អ៊ីចឹងបានសេចក្តីថា ពេលគេសួរចម្លើយ គេមិនដែលសួរក្បាលព្រលប់ ឬពេលថ្ងៃ ច្រើនសួរពាក់កណ្តាលអធ្រាត្រ។

[០៩:០៦:៥៦]

**ស៖** តើប្រជាជនប្រភេទណាដែលត្រូវគេឃុំឃាំងខ្លួននៅទីនោះ? <តើលោកស្រីដឹងទេ ហេតុអ្វីបានជាអ្នកទោសត្រូវបានគេឃុំឃាំងនៅក្នុងគុកនោះ?>

**ឆ៖** តាមការពិតទៅកន្លែងហ្នឹងមិនជាប្រជាជនប្រភេទណាទេ ស្រីក៏មាន ប្រុសក៏មាន ប្រភេទទី៣ដូចខ្ញុំក៏មាន មានប្រភេទទី៣ គេផ្សេងទៀតក៏មាន ប៉ុន្តែអន្លង់ដាក់ឃុំឃាំងហ្នឹងខុសគ្នា។ អ៊ីចឹងទាក់ទងគ្នាបានតែអន្លង់ដែលយើងជាប់ជាមួយគ្នាទេ ក្រៅពីហ្នឹងយើងអត់ដឹងទេ ព្រោះយើងណាស់មួយ

ទួលក្រាំងឆេះហ្នឹងមួយ គឺថាធំមែនទែន។

**ស៖** នៅពេលដែលលោកស្រីថា នៅក្នុងអន្លង់ រណ្ដៅនេះ លោកស្រីចង់និយាយថាម៉េចនុ៎ង?

**ឆ៖** ព្រោះមន្ទីរកែប្រែហៅគុកនៅក្រាំងឆេះនេះ មិនមែនយកដាក់លើផ្ទះថ្ម ឬសាលារៀន ឬកុដិលោកអីទេ គឺជីកដីទៅក្រោម។ ជីកដីទៅក្រោមប្រហែលជា៥ម៉ែត្របួនជ្រុងហ្នឹង គេយកដើមត្នោតយកមកដែងពីក្រោមមក ហើយកប់ដីពីលើ ហើយផ្លូវឡើងគេធ្វើជណ្ដើរទៅ ហើយគេប្រក់កុំឲ្យទឹកហូរចូលប៉ុណ្ណឹង។

**ស៖** តើក្រាំងឆេះនេះមានទីតាំងនៅទីណា ស្ថិតនៅក្នុងស្រុកណា ខេត្តណា?

**ឆ៖** ក្រាំងឆេះនេះស្ថិតនៅឃុំអង្គខ្នុរ កាលជំនាន់ប៉ុលពត ឥឡូវនេះស្ថិតនៅស្រុកបូរីជលសារ។ អ៊ីចឹងកាលជំនាន់អាពត មាននៅក្នុងឃុំអង្គខ្នុរ ស្រុកទ្រាំង -- ស្រុកកោះអណ្ដែត ខេត្តតាកែវ។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ ក្រាំងឆេះនេះស្ថិតនៅក្នុងខេត្តតាកែវ។ ខ្ញុំមានសំណួរមួយទៀតពាក់ព័ន្ធនឹងចំណុចនេះ តើក្រោយមកលោកស្រីត្រូវបានគេបញ្ជូនទៅឃុំខ្លួននៅគុកភ្នំសន្លុងមែនឬទេ?

[០៩:០៩:១៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី លោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំស្ដាប់យ៉ាងប្រុងប្រយ័ត្នចំពោះសំណួររបស់សហព្រះរាជអាជ្ញាអស់រយៈពេលប៉ុន្មាននាទីមកហើយនេះ ហើយខ្ញុំកត់សម្គាល់ឃើញថា មន្ទីរឃុំឃាំងដែលគាត់លើកហ្នឹងមិនស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្ដីទេ។ ពិតណាស់ក្នុងក្របខ័ណ្ឌនៃការថ្លែងអំពីព្យសនកម្មដើមបណ្ដឹងរដ្ឋប្បវេណីអាចធ្វើបាន ក៏ប៉ុន្តែឥឡូវនេះយើងស្ដាប់សក្ខីកម្មគាត់អំពីអង្គហេតុទេ មិនមែនជាការថ្លែងទុក្ខសោកទេ។ <ខ្ញុំជំទាស់ទៅនឹងអ្វីដែលសហព្រះរាជអាជ្ញាសួរពាក់ព័ន្ធនឹងអង្គហេតុ ដែល> មិនមានចែងនៅក្នុងដីកាដំណោះស្រាយ ឬក៏នៅក្នុងកិច្ចដំណើរការបំបែកនីតិវិធីទេ។

**លោក នីកូឡាស គូមជែន៖**

នេះជាជំហររបស់សហព្រះរាជអាជ្ញា <ហើយក៏ជាចំណុចសំខាន់នៅក្នុងសំណុំរឿងរបស់យើង> គឺថាការធ្វើទារុណកម្មបុគ្គលណាមួយ <ការឃុំឃាំង>មនុស្សដែលគ្មានទោស ហើយការចាត់ថ្នាក់ប្រជាជនទៅជាខ្មាំង ហើយយកទៅសម្លាប់ចោលនោះ គឺថាវាជាផ្នែកមួយនៃគោលនយោបាយ

<ជាតិ>។ ហេតុដូច្នេះ វាពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់ ខៀវ សំផន និង នួន ជា ចំពោះឧក្រិដ្ឋកម្មទាំងនេះ។ <បើសិនណាមេធាវីការពារក្ដីយល់ព្រមថា នេះជាគោលនយោបាយជាតិ នោះខ្ញុំមិនចាំបាច់លើករឿងនេះមកនិយាយទេ។ ប៉ុន្តែ>បើសិនណាថា<ពួកគេមិនព្រមទេ ដូចដែលពេលខ្លះ> នួន ជា អះអាងថា នេះជាសេចក្ដីសម្រេចរបស់ថ្នាក់មូលដ្ឋាននោះ គឺថាយើងខ្ញុំ<គិត>ថា <វាមានសារសំខាន់ដែលយើងយ៉ាងហោចណាស់និយាយដោយសង្ខេបនូវ>អ្វីកើតឡើងនៅក្នុងប្រទេស។ <ខ្ញុំសន្យាថានិយាយដោយសង្ខេបបំផុត ដោយសារថាខ្ញុំនៅសល់ពេលតែពីរបីនាទីទៀតប៉ុណ្ណោះ។>

[០៩:១១:០៧]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមឆ្លើយតបដោយខ្លី <សំណួរ>មិនមែន<អ្វីដែល>សហព្រះរាជអាជ្ញាចង់និយាយអ្វីទេ ក៏ប៉ុន្តែ<ហេតុអ្វីបានជា>អង្គជំនុំជម្រះ<ភ្ជាប់ទៅនឹងអ្វីដែលខ្លួន>បានកំណត់វិសាលភាពរួចហើយ។ <ដូច្នេះបើ>អង្គជំនុំជម្រះ<មិន>បានកំណត់អង្គហេតុ<នេះទេ យើងមិនត្រូវនិយាយពីវានោះទេ។ វាច្បាស់ណាស់ថា លោកបានផ្តល់បញ្ជីឈ្មោះ>មន្ទីរសន្តិសុខនៅក្នុងវិសាលភាព<នៃការជំនុំជម្រះនេះ>។ អ៊ីចឹងបើដូចសហព្រះរាជអាជ្ញាលើកឡើងហ្នឹង មានន័យថា យើងអាចនិយាយអំពីមន្ទីរសន្តិសុខណាក៏បានដែរ។ <បើអ៊ីចឹង ម៉េចចាំបាច់ត្រូវការមានដីកាដំណោះស្រាយ ឬដីកាបំបែកនីតិវិធីធ្វើអី>។

**លោក នីកូឡាស គូមជែន៖**

*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ចៅក្រម កូ្ល ឌា ហ្វេនស៍៖**

យើងអាចដោះស្រាយបញ្ហានេះសិន។ ការអនុវត្តកន្លងមក គឺថា បើសិនណាជាការសួរដោយសង្ខេបមិនសួរជាលម្អិតទេ យើងអនុញ្ញាតឲ្យសួរពាក់ព័ន្ធទៅនឹងគោលនយោបាយជាតិ។ ដូច្នេះយើងសង្ឃឹមថា សហព្រះរាជអាជ្ញាអន្តរជាតិ គឺថានឹង<និយាយដោយសង្ខេបតាមការសន្យារបស់គាត់>។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកស្រី តើលោកស្រីត្រូវបានគេឃុំខ្លួននៅភ្នំ គុកភ្នំសន្ទុងមែនឬទេ? <តើគុកនោះស្ថិតនៅកន្លែងណា>?

**លោកស្រី ស៊ូ សុធាវី៖**

**ឆ៖** រឿងថ្ងៃ រឿងខែនោះ ខ្ញុំអត់សូវដឹងទេ ព្រោះមកនៅក្នុងគុករហូត ពន្លឺថ្ងៃក៏ឃើញតែពេល

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

វេលាតិច ហើយអាការដើរហើរចេញក្រៅ ក៏មានពេលវេលាតិចដែរ។ អ៊ីចឹងខ្ញុំអត់ដឹងទេ តែគេបញ្ជូនចេញពីក្រាំងឆេះ មកគុកសន្ទុង។ សន្ទុងក៏ក្នុងខេត្តតាកែវដែរ ជារបស់ឃុំ។

**ស៖** នៅឯគុកភ្នំសន្ទុង តើលោកស្រីអាចរៀបរាប់អំពីស្ថានភាពនៃគុកនោះ <ដោយសង្ខេប> បានទេ?

**ឆ៖** កាលពីជំនាន់ ប៉ុល ពត គុកនៅសន្ទុង *(ឮមិនច្បាស់)* ល្អាងមួយ តែដោយសម័យនេះ គឺគេល្អាងហ្នឹងគេបិទចោលអស់ហើយ ឬគេរើចោលអស់ហើយក៏មិនដឹងទេ ក៏ប៉ុន្តែខ្ញុំទៅមួយរយៈមុនដែលខ្ញុំទៅគោរពបូជា ដែលធ្លាប់មានបន់បំណន់ទៅ ខ្ញុំទៅបានគោរពបូជា អត់មានទេ។ ប៉ុន្តែទៅនោះ គេឲ្យខ្ញុំរើថ្មក្នុងមួយថ្ងៃឲ្យបាន១ម៉ែត្រគូប ដើម្បីយកឲ្យគេធ្វើជាស្ពានទៀត ខ្ញុំមិនដឹងទេ ប៉ុន្តែដល់ពេលបាន១ម៉ែត្រគូប គេដឹកទៅសិន អ្នកណាធ្វើមិនបាន១ម៉ែត្រគូប បង្អត់បាយ។

**ស៖** តើអ្នកដែលជាប់ឃុំឃាំងហ្នឹង គេមានឲ្យគ្រែ ឲ្យអីដេកទេ?

**ឆ៖** គ្មានគ្រែមួយៗដេកទេ គឺមានតែក្តារ ឫស្សីដែលគេរៀបអ៊ីចឹងទៅ ដេកលើឫស្សីហ្នឹងទៅ គេដាក់ខ្នោះទៅពីក្រោមជើងយើងហ្នឹង ឲ្យយើងដេកទៅ គេស៊កខ្នោះក្រោមហ្នឹងទៅ។ អត់មានគ្រែឲ្យដេកម្នាក់មួយ ម្នាក់មួយទេ គឺឲ្យដេកជារនាបផ្ទាល់តែម្តង ទាំងអស់គ្នា។

[០៩:១៤:៣៥]

**ស៖** តើលោកស្រីមានធ្លាប់បានដឹងថា ប្រជាជនទាំងអស់នោះ ត្រូវបានគេចោទប្រកាន់ពីបទល្មើសអ្វីដែរឬទេ ទើបបានគេឃុំឃាំងខ្លួននៅទីនោះ?

**ឆ៖** រឿងបទល្មើសជនផ្សេងនានា យើងអត់ដឹងទេ ព្រោះពេលនោះសុទ្ធតែដាំដើមគគ្រប់គ្នាអត់ហ៊ានសួរនាំអីទេ ព្រោះពេលធ្វើការ កងឈ្លបហ្នឹង និងកងសន្តិសុខ គេនៅក្រោយខ្នង ទុកសួរអីក៏មិនហ៊ានដែរ ដឹងតែពីធ្វើការរើថ្មទៅ ឲ្យបាន១ម៉ែត្រគូប។ បើមិនបាន១ម៉ែត្រគូប អត់បាយស៊ី អ៊ីចឹងចេះខំប្រឹងរើ។ តែបើរឿងស៊ើបសួរអ្នកនេះមានទោសអី អ្នកនោះមានទោសអី យើងអត់ហ៊ានទេ។ ក្នុងនាមជនរងគ្រោះដូចគ្នា ជាប់គុកដូចគ្នា ខ្លាចគេសម្លាប់ចោល អត់ហ៊ានសួរនាំទេ។

**ស៖** នៅពេលដែលលោកស្រីត្រូវបានឃុំឃាំងខ្លួននៅគុកនោះ តើមានអ្នកទោសណាត្រូវបានបាត់ខ្លួនដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមជំទាស់ដដែល ដូចដែលខ្ញុំបានលើកឡើងមុននេះបន្តិចអ៊ីចឹង គឺគាត់និយាយលម្អិតអំពីលក្ខខណ្ឌនៃមន្ទីរសន្តិសុខ ឬក៏មន្ទីរឃុំឃាំង<ដែលមិនមាននៅក្នុងវិសាលភាពនៃការជំនុំជម្រះនេះ>។ អ៊ីចឹងខ្ញុំសូមជំទាស់។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកសហព្រះរាជអាជ្ញាអន្តរជាតិមានសំណួរប៉ុន្មានទៀតពាក់ព័ន្ធទៅនឹងពន្ធនាគារមួយនេះ?

[០៩:១៦:១៥]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមានសំណួរតិចតួចទៀតទេ។ នេះគឺជាចម្លើយរបស់សាក្សី ដែលវាពាក់ព័ន្ធទៅនឹងផ្នែកនៃការបោសសម្អាត ហើយក៏មានការលើកឡើងថា បទពិសោធន៍របស់សាក្សីទាំងអស់នេះ ហើយ ម៉ែខល វីកឃើរី ក៏បានលើកឡើងថា វាជាទីតាំងមួយរបស់ ប៉ុល ពត ហើយនៅក្នុងភូមិភាគនិរតីនេះ គឺវាពាក់ព័ន្ធទៅនឹងគោលនយោបាយជាតិនេះតែម្តង។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** តើមានអ្នកទោសបាត់ខ្លួនដែរឬទេ? បើសិនណាជាលោកស្រីដឹង តើដឹង<ដោយរបៀបណា>?

**លោកស្រី ស៊ូ សុធាវី៖**

**ឆ៖** រឿងបាត់ខ្លួន វាជាធម្មតាទេ ពីរបីថ្ងៃបាត់។ ម្នាក់ហ្នឹងអត់ឃើញមកធ្វើការទៅ ក៏លបសួរគ្នាទៅ ថាឈឺក៏អី? គេថាអត់ដឹង។ បើអ៊ីចឹងអត់ហ៊ានសួរនាំតទៀត។ តែធម្មតាជំនាន់ ប៉ុល ពត តែបាត់ខ្លួនចេញពីមន្ទីរឃុំឃាំង បាត់ខ្លួនអត់ឃើញទៅដេក ប្រាកដជាទៅរៀនសូត្រ។ ពាក្យ "រៀនសូត្រ" មួយមុខនេះ មិនអាចសន្និដ្ឋានបានទេ មិនមែនរៀនសូត្រដូចសម័យឥឡូវ។ រៀនសូត្រជំនាន់ហ្នឹង គឺពាក្យហ្នឹងសាហាវណាស់។

**ស៖** តើលោកស្រីធ្លាប់បានចេញទៅក្រៅ ហើយបានឃើញអ្វី ឬធុំក្លិនអ្វីដែរឬទេ?

[០៩:១៧:៥៧]

**ឆ៖** ព្រោះកន្លែងភ្នំនោះ គេកម្រវើរបៀតណាស់។ អ៊ីចឹងហើយ យើងមិនបានសូវដែលជួបប្រទះនូវអ្វីដែលចម្លែកទេ ព្រោះគេមានកន្លែងគេវើផ្សេង។ អ៊ីចឹងគេមានទួលឯលិចភ្នំហ្នឹងទៅទៀត ដែលជា

កន្លែងសម្ងាត់របស់គេ សម្រាប់សម្លាប់ហ្នឹង។ ខ្ញុំដឹងថាទួលហ្នឹងសម្លាប់មនុស្ស ដោយសារជំនាន់ឥឡូវទេបានដឹងថា ទួលហ្នឹងគេធ្វើបុណ្យធ្វើទានអី អ្នកដែលស្លាប់ទៅជំនាន់ ប៉ុល ពត។ តែតាមខ្ញុំនៅក្នុងគុកនោះគឺថាបាត់ច្រើនដែរ ក៏ប៉ុន្តែមិនដឹងគេយកទៅសម្លាប់ចោលទួលហ្នឹង ឬមួយយកទៅរៀនសូត្រកន្លែងណាក៏មិនដឹងដែរ។ ប៉ុន្តែគ្រាន់តែពាក្យជំនាន់ខ្មែរក្រហម តែរៀនសូត្រ បាត់ហើយ។

**ស៖** ខ្ញុំបញ្ចប់ការសួរសំណួរពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខទាំងនេះហើយ។ ខ្ញុំសុំសួរពីបទពិសោធន៍ របស់លោកស្រីនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនៅភូមិភាគនិរតី គឺនៅខេត្តកណ្តាល និងនៅខេត្តតាកែវ។ តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេ លោកស្រីមានជួបពើបប្រទះ ឬក៏ថាបានដឹងរឿងបញ្ហាជនជាតិវៀតណាមនៅក្នុងរបបនោះដែរឬទេ?

**ឆ៖** នៅខេត្តតាកែវ ខ្ញុំនៅសហករណ៍ហ្នឹងរយៈកាលពេលខ្លីណាស់ ទៅនៅតែកងចល័ត អត់ដឹងរឿងរ៉ាវអីវែងឆ្ងាយច្រើនទេ។ ដល់មកនៅក្នុងគុករហូតទៀត ជាប់គុកមានដែលដឹងថាមានវៀតណាមអីៗណា អីណា វ៉ៃគ្នាអីណា អត់ដឹង។ ដល់មកនៅខេត្តកណ្តាលទៀត គេបញ្ជូនមកនៅខេត្តកណ្តាល គេលែងចេញពីគុកសន្លុងហ្នឹងមក នៅគុកខេត្ត -- មកនៅខេត្តកណ្តាលហ្នឹង ក៏អត់ដែលឃើញថាមានប្រជាជនវៀតណាមអីនៅក្បែរហ្នឹង គេវ៉ៃចោល។ មនុស្ស មិនដឹងគេវាយចោលពីមុនមកក៏មិនដឹងដែរ តែជំនាន់ខ្ញុំទៅនៅខេត្តកណ្តាល ក្រោយពាក់កណ្តាលហើយហ្នឹង គឺអត់មានដែលឃើញ ដឹងរឿងប្រជាជនវៀតណាម ដឹងតែរឿងជាតិចាម។

**ស៖** សូមអរគុណលោកស្រី។ ចុះចំពោះអតីតទាហាន លន់ នល់ វិញ តើនៅពេលដែលលោកស្រីនៅទីនោះ ចន្លោះពីឆ្នាំ៧៥ ទៅដល់៧៩ តើគេប្រព្រឹត្តមកលើអតីតទាហាន លន់ នល់ ឬក៏ក្រុមគ្រួសារទាហាន លន់ នល់ ហ្នឹង ដោយរបៀបណាដែរ?

[០៩:២០:៤៦]

**ឆ៖** ខ្ញុំរឿងគេអ្នកខាងក្រៅ ក៏អត់ដឹងដែរ ដឹងក្រុមគ្រួសាររបស់ខ្ញុំក្នុងរយៈកាលដែលខ្ញុំរស់នៅនេះ ការឈឺចាប់ច្រើនណាស់។ បងរបស់ខ្ញុំទាហាន លន់ នល់ ទាំងអស់ ឪពុកខ្ញុំក៏ទាហាន លន់ នល់ ទាំងអស់គ្នាត្រូវគេសម្លាប់ទាំងអស់។ ឲ្យតែជាប់សែស្រឡាយទាហាន សូម្បីតែជីដូនមួយ ជីទួតមួយ គេមិនមើលមុខដែរ គេដឹងថាក្រុមគ្រួសារយើងជាមន្ត្រីយោធា គេអត់ដែលស្គាល់ទេ ប៉ុន្តែគ្រួសារខ្ញុំ ដូចខ្ញុំនិយាយពីម្សិលមិញថា ប្រាំមួយដណ្តប់នាក់ មួយបងប្អូនបង្កើត ឪពុកមួយទៀត ជាទាហានទាំងអស់។ សូម្បីតែខ្ញុំពីមុនឆ្នាំ៧៥ ក៏ខ្ញុំជាទាហានដែរ។ ដោយឡែកតែខ្ញុំមានអាកប្បកិរិយាខុសគេ គេមិនសួរតាម

ដានរឿងទាហានហ្នឹង តែក្រុមគ្រួសារខ្ញុំដែលបែកទៅ គឺស្លាប់ដោយសារតែពាក្យធ្វើទាហានហ្នឹងមួយមុខ។

**ស៖** តើខ្មែរក្រហមដឹងថា គ្រួសារណាធ្វើទាហានហ្នឹង ដឹងដោយរបៀបណា?

**ឆ៖** មិនបាច់អ្នកណាចាំទៅប្រាប់ រាយការណ៍ប្រាប់ទេ ក្រុមគ្រួសារខ្ញុំ ឪខ្ញុំជាកុងត្រូល័រមេព្រៃ ហើយដល់ពេលឆ្នាំ៧០ គេ*ដេតាសេ*គាត់ទៅជាទាហានទាំងអស់។ បងប្អូនខ្ញុំសុទ្ធទាហាន ហើយបុណ្យស័ក្តិក៏កាន់តែធំ ចំណេះវិជ្ជាក៏សុទ្ធតែនិស្សិត និងបញ្ញវន្តទាំងអស់ បានគេដឹង គេសម្លាប់ចោល។ ក្នុងភូមិឃុំរបស់ខ្លួនឯងនៅហ្នឹងគឺអស់បងពីរនាក់ នៅខាងក្រៅទៀត មិនដឹងជាស្រុកណាស្រុកណី ប៉ុន្តែគេស៊ើបសួរតាមរយៈបណ្តាញទៅ គេដឹងទាំងអស់ ថាក្រុមគ្រួសារខ្ញុំជាទាហាន ជាគ្រូបង្រៀន សាស្ត្រាចារ្យបានគេសម្លាប់ចោលអស់។ អត់មានសេសសល់ទេ។

[០៩:២៣:០៥]

**ស៖** លោកស្រី តើលោកស្រីធ្លាប់ដែលបានឃើញដែលគេប្រមូលស្រង់ប្រវត្តិរូប និងរក្សាទុកប្រវត្តិរូបប្រជាជនធម្មតាដែរឬទេ ដូចជាសមាជិកគ្រួសាររបស់លោកស្រីជាដើម?

**ឆ៖** មិនមែនតែប្រជាជនធម្មតាទេ សូម្បីតែមូលដ្ឋាននេះ ក៏មានប្រវត្តិរូបដែរ។ ក្រុមគ្រួសារខ្ញុំព្រោះតែមានប្រវត្តិរូបហ្នឹងហើយ ម្តាយខ្ញុំគាត់ចាស់ជរា គាត់ស្លូតត្រង់ គេសួរម៉េច ថាអ៊ីចឹង ដើម្បីឲ្យកូនរស់ ព្រោះគេប្រាប់ថា បើសិនណាជាទាហានគេឲ្យទៅធ្វើវិញ គ្រូបង្រៀនគេឲ្យទៅរៀនវិញ គេប្រាប់និស្សិតមកពីបរទេស គេមកច្រើនណាស់ ជួយការពារ ជួយខ្មែរយើង អ៊ីចឹងម្តាយខ្ញុំឆ្លើយទាំងអស់ អ៊ីចឹងបងប្អូនខ្ញុំបែកគ្នាចេញពីភ្នំពេញទៅនៅស្រុកផ្សេងៗពីគ្នា ស្លាប់ទាំងអស់ គ្មានអ្នកណាសល់ទេ។

**ស៖** សំណួរមួយទៀត។ នៅពេលលោកស្រីជាប់ឃុំឃាំងនៅគុកភ្នំសន្លុង តើលោកស្រីធ្លាប់ឮពីគុកក្រាំងតាចាន់ នៅក្នុងស្រុកត្រាំកក់ដែរឬទេ នៅពេលនោះ?

**ឆ៖** គុកក្រាំងតាចាន់នៅស្រុកត្រាំកក់នេះ ខ្ញុំបានស្គាល់មួយភ្លែត ពេលគេជម្លៀសចេញពីភ្នំសន្លុងហ្នឹងទៅខេត្តកណ្តាល គេឲ្យរួចទៅខេត្តកណ្តាល គេយកទៅផ្ញើនៅក្រាំងតាចាន់១យប់ ដោយសារកាលហ្នឹងកងទ័ពវៀតណាមចូលមកវ៉ៃកៀកភ្នំសន្លុងហ្នឹងហើយ គេក៏រំដោះឲ្យខ្ញុំទៅនៅខាងក្រាំងតាចាន់ហ្នឹងបានតែ១យប់ទេ គឺអត់បានចូលទៅក្នុងគុកគេ បន្ទប់គេ គឺគេផ្ញើនៅប៉ុស្តិ៍ពីខាងលើ។

**ស៖** ដូច្នេះលោកស្រីត្រូវបានគេឃុំឃាំងនៅខាងក្រៅគុកក្រាំងតាចាន់ ប៉ុន្តែឃុំឃាំងហ្នឹងគឺនៅក្បែរគុកក្រាំងតាចាន់នេះឯង បើខ្ញុំយល់មិនច្រឡំគឺអ៊ីចឹង។ ប្រហែលជាអាចឃុំឃាំងខ្លួននៅក្នុងរបងគុក

ក្រាំងតាចាន់ដែរ ប៉ុន្តែមិននៅក្នុងអគារគុកក្រាំងតាចាន់ទេ អ៊ីចឹងមែនទេ?

[០៩:២៥:៥៤]

**ឆ៖** ពិតប្រាកដណាស់ ព្រោះយកទៅធ្វើហ្នឹង មិនមែនយកទៅដាក់គុកក្រាំងតាចាន់ទេ ព្រោះក្រាំងតាចាន់ហ្នឹង ឮសួរសន្តិសុខនិយាយនៅហ្នឹងថា អត់មានអ្នកទោសទេ ប៉ុន្តែខ្ញុំឃើញទៅហើយ កន្លែងហ្នឹងគេឃុំឃាំង ខ្ញុំដឹង ព្រោះខ្ញុំជាប់គុកពីរកន្លែងនេះ ខ្ញុំដឹងថាកន្លែងនេះគុកដែរ។ ប៉ុន្តែខ្ញុំគេយកទៅធ្វើនៅកន្លែងសន្តិសុខធ្វើការនៅខាងលើ អត់មានដាក់ខ្នោះដាក់អីទេ ព្រោះពីខាងសន្ទុងមក គេប្រាប់ថាទោសស្រាលទេ។ គេគ្រាន់តែនិយាយប៉ុណ្ណឹងហើយ គេក៏ទុកហ្នឹង ខ្ញុំក៏ដេកធម្មតា ដល់ព្រលឹមឡើង គេឲ្យដើរចេញមកៗ។

**ស៖** សូមអរគុណលោកស្រី។ បើលោកស្រីមិនដឹងទេ ក៏ឆ្លើយថាមិនដឹង។ តើលោកស្រីដឹងថាអ្នកទោសនៅគុកក្រាំងតាចាន់ហ្នឹង<មានបាត់ខ្លួនទេ តើពួកគេ>ត្រូវបានគេប្រព្រឹត្តដោយរបៀបណាដែរឬទេ?

**ឆ៖** អត់បានសួរនាំថាគេប្រព្រឹត្តរបៀបណា ឃើញរបៀបណា ព្រោះរយៈពេលខ្ញុំទៅនៅហ្នឹងមួយយប់ខ្លីណាស់។ គេបញ្ជូនចេញពីសន្ទុងទៅ គឺពេលយប់ ទៅដល់ហ្នឹងកណ្ដាលយប់ទៅហើយ។ បើអ៊ីចឹងអត់បានដឹងដំណឹងព័ត៌មានអី ព្រលឹមឡើងហ្នឹង ភ្លឺឡើងហ្នឹងសន្តិសុខ គេនាំខ្ញុំទៅខេត្តកណ្ដាលម្ដងទៅ អត់មានរឿងដឹងថាអី គ្រាន់ដឹងថាហ្នឹងអត់មានអ្នកទោសទេ ខ្ញុំសួរគេអ្នកនៅខាងលើនេះ គេលាក់ការណ៍ជិត គេថាអត់មានអ្នកទោសទេ។ តែក្រោយនេះ ខ្ញុំទៅក្រាំងតាចាន់ ដល់ពេលខ្ញុំឃើញក្រាំងតាចាន់ បងខ្ញុំនៅនុ៎ង ដែលខ្ញុំដឹងថាក្រាំងតាចាន់ ក៏មានបងប្អូនស្លាប់នៅហ្នឹងដែរ។ អ៊ីចឹងហើយបានខ្ញុំថាក្រាំងតាចាន់សាហាវជាងក្រាំងឆេះ និងសន្ទុងទៅទៀត។

[០៩:២៧:៥៧]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកស្រីសាក្សី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី នួន ជា មានសំណួរលើដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក លីវ សុវណ្ណា៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន និងអង្គសវនាការទាំងមូល។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** សូមជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ លីវ សុវណ្ណា ជាមេធាវីជាតិនៅក្នុងក្រុមការពារក្ដីលោក នួន ជា។ ព្រឹកនេះ ខ្ញុំសូមតាំងសំណួរមួយចំនួនចំពោះលោក។ ទី១ ខ្ញុំចង់ដឹងពីប្រវត្តិខ្លះរបស់លោក។ ពីម្សិលមិញលោកបានថ្លែងថា លោកមុនឆ្នាំ១៩៧៥ លោកបានជាអ្នកច្រៀងនៅបារ ហើយអម្បាញ់មិញលោកថា លោកជាទាហាន លន់ នល់។ អ៊ីចឹងក្រៅពីមុខរបរនេះ តើលោកអាចមានមុខរបរអីផ្សេងទៀត ដូចជាការសម្ដែងភាពយន្ត សម្ដែងសិល្បៈអីដែរទេ?

[០៩:២៩:១៣]

**លោកស្រី ស៊ូ សុធារី៖**

**ឆ៖** ខ្ញុំអត់មានបានសម្ដែងខ្សែភាពយន្តទេ ព្រោះសម្រស់វាស្អាតពេក គេមិនអាចជួលទៅសម្ដែងទេ តែបើច្រៀង ពីរោះគួរសមដែរ។ កាលហ្នឹងខ្ញុំអត់ទាន់វះកទេ។ អ៊ីចឹងខ្ញុំអាចច្រើនបាន ខ្ញុំលេងល្ខោនបាសាក់បាន យីកេបាន ប៉ុន្តែខ្ញុំអត់បានសម្ដែងខ្សែភាពយន្តទេ។ ប៉ុន្តែខ្ញុំទាហានមែន ទាហានឆ្នាំមុនឆ្នាំ៧០ហ្នឹងទៀត គេប្រកាសសង្គ្រាមមកនោះ គឺខ្ញុំបានធ្វើតាំងពី៦៨, ៦៩មកណោះ ព្រោះខ្ញុំជាពេទ្យបម្រើកងទ័ព។ តែរឿងវាវែងពេក ខ្ញុំមិនបាននិយាយអស់ទេ គ្រាន់តែថាខ្ញុំក៏ជាទ័ពដែរ។ មួយពូជទ័ពទាំងអស់ គ្រូបង្រៀនទាំងអស់។ បើអ៊ីចឹងបានសេចក្ដីថា ទ័ពពាក់កណ្ដាល គ្រូបង្រៀនពាក់កណ្ដាល។ ហើយចំណែកខ្ញុំដោយឡែកតែឯងទេ ព្រោះខ្ញុំទាបពេក រៀនមិនបានខ្ពស់ដូចបងៗរបស់ខ្ញុំទេ ប្អូនរបស់ខ្ញុំ។ អ៊ីចឹងខ្ញុំបានត្រឹមទុតិយភូមិនៅឆ្នាំ១៩៦០ ក៏ប៉ុន្តែជំនាញរបស់ខ្ញុំខាងសាលាវិចិត្រសិល្បៈ។

**ស៖** បាទ អរគុណ។ ឥឡូវខ្ញុំសូមចូលនៅក្នុងប្រធានបទរបស់យើង ខ្ញុំចង់សួរលោកបញ្ហាមួយចំនួនមុនពេលដែលលោករៀបការ។ ពីម្សិលមិញលោកបានថ្លែងថា ពីនៅក្នុងខែកុម្ភៈ ឆ្នាំ២០ -- ឆ្នាំ១៩៧៧ គឺមានគោលនយោបាយឲ្យរៀបអាពាហ៍ពិពាហ៍ ហើយពេលនោះគឺមានគេបង្ខំឲ្យលោករៀបអាពាហ៍ពិពាហ៍។ អ៊ីចឹងលោកអាចពណ៌នាបានលម្អិតតិចបានទេ ថាតើគោលនយោបាយដែលឲ្យរៀបអាពាហ៍ពិពាហ៍ហ្នឹង គេនិយាយថាយ៉ាងម៉េចគោលនយោបាយហ្នឹង?

[០៩:៣១:០៨]

**ឆ៖** ខ្ញុំបានជម្រាបពីម្សិលមិញហើយ ថាការបង្ខំរៀបការហ្នឹងចាប់ពីខែកុម្ភៈ ឆ្នាំ១៩៧៧ហ្នឹងមក គេអត់ទាន់បានសម្លុតគំរាមកំហែងខ្ញុំទេ ខ្ញុំបានប្រាប់តាំងពីម្សិលមិញ។ គ្រាន់តែខ្ញុំឮសូរថាគេរៀប

គ្រួសារ និងរៀបអាពាហ៍ពិពាហ៍ឲ្យយុវជន យុវនារី ហើយគ្រាន់តែប៉ុណ្ណឹងមក ហើយក៏ស្ងាត់ទៅ។ តែនេះខ្ញុំដឹងខ្លាំង ពេលគេបង្ខំកាត់សក់ ឲ្យកងទ័ពមកកាត់សក់នេះ បានខ្ញុំដឹងថាខ្ញុំបែបមានគេបង្ខំឲ្យរៀបការហើយ។ ដល់ហើយមកពេលចុងក្រោយ បានប្រើពាក្យបង្ខំមែន ក្នុងរយៈកាលមួយខែ ពីរមកមានគេបង្ខំ។ លើកទី១ គេបង្ខំ ព្រមរៀបការ ឬមិនព្រម? ខ្ញុំថា បានសារភាពតាំងពីម្សិលមិញ ខ្ញុំប្រាប់ហើយថាខ្ញុំម្ដាយចាស់ជរាណាស់ បើខ្ញុំរៀបការទៅម្ដាយខ្ញុំបាននរណាមើល។ គេក៏ឆ្លើយវិញ បានអង្គការមើលហើយ ចាំបាច់អ្នកឯងមើលអីទៀត អ៊ីចឹងអ្នកឯងត្រូវតែរៀបការ។ ហើយខ្ញុំក៏បានប្រាប់គាត់ ខ្ញុំសូមអង្វរចាំបន្តិចទៀត ខ្ញុំមើលម្ដាយខ្ញុំសិន។ គេក៏លែងមាត់លែងក គេដើរចេញទៅវិញ។ បើអ៊ីចឹងនេះរៀបការនេះ ពីខែកុម្ភៈ ដល់ខែសីហា បានជារៀបការរយៈកាលពេលវែង។ ប៉ុន្តែការគំរាមក៏មានច្រើនដែរ។ ប៉ុន្តែគំរាមកំហែង ខ្ញុំចាំមិនអស់ទេ គំរាមកំហែងយកទៅសម្លាប់ យកទៅរៀនសូត្រ ខ្ញុំមិនបានចាំអស់ទេ។ សូមមេធាវីអភ័យទោស។

**ស៖** បាទ អរគុណ។ អ៊ីចឹងអ្នកដែល--

[០៩:៣២:៤៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី សូមកុំសួរសំណួរដដែលៗ ព្រោះថាសំណួរនេះត្រូវបានសួរកាលពីម្សិលមិញរួចមកហើយ ហើយខ្ញុំចាំកាលពីម្សិលមិញសំណួរហ្នឹងត្រូវបានឆ្លើយដោយដើមបណ្ដឹងរួចទៅហើយ។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ម្សិលមិញខ្ញុំបានស្ដាប់ដែរ លោកថាមានគេបង្ខំហ្នឹង តើអ្នកដែលបង្ខំលោកហ្នឹងគឺឈ្មោះអី?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមទោសលោកមេធាវី យើងស្ដាប់សំណួរនេះរួចទៅហើយ។ ប្រសិនបើលោកមានសំណួរដែលមិនបានសួរកាលពីម្សិលមិញ ដូច្នេះសូមលោកលើកសំណួរដែលមិនបានសួរកាលពីម្សិលមិញទៅ យើងមិនចង់ស្ដាប់អ្វីដែលបានសួរម្ដងហើយម្ដងទៀត ម្ដងហើយម្ដងទៀតបែបនេះទៀតទេ។

**លោកស្រី ដូរីន ជិន៖**

សូមជម្រាបសួរលោកប្រធាន។ សូមជម្រាបលោកស្រីចៅក្រម តាមការយល់ដឹងរបស់យើង គឺយើងត្រូវសួរដេញដោលសំណួរ ហើយពេលខ្លះអាចថាយើងត្រូវសួរសំណួរដែលស្ដាប់ឮសួរ ដូចថាសួរដដែលៗ ប៉ុន្តែ<ពេលខ្លះ>យើង<អាចទទួលបានចម្លើយខុសគ្នា។ យើងបានឮហើយកាលពីដើមសប្ដាហ៍

01355059



នេះ។> ម៉្យាងទៀតពេលខ្លះយើងអាចទៅសួរសំណួរដែលព្រះរាជអាជ្ញាបានសួរ<ហើយ ហើយយើងបានទទួលចម្លើយខុសគ្នា។ ខ្ញុំគិតថា នេះជាសិទ្ធិជាមូលដ្ឋានរបស់យើង>។ បើតាមតែខ្ញុំយល់គឺថា សហការីរបស់ខ្ញុំ គឺថាគាត់អាចមានសំណួរថ្មី ប៉ុន្តែពេលខ្លះគាត់អាចនឹងសួរដេញដោលទៅលើអ្វីដែលបានសួររួចមកហើយ។ ដូច្នេះ ខ្ញុំគិតថាវាជារឿងត្រឹមត្រូវចំពោះសិទ្ធិរបស់មេធាវី។

[០៩:៣៤:៥០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ការពិតគឺថាវាជារឿងត្រឹមត្រូវដែលមេធាវីការពារក្តីអាចសួរដេញដោល ប៉ុន្តែ<សួរ>សំណួរ<>ដដែលៗ<គេត្រូវបានច្បាប់ហាមឃាត់។ ហើយខ្ញុំអត់បានឃើញមានអ្វីថ្មីបន្តិច>នោះទេ។ យើងស្តាប់ឮសំណួរដែលបានសួរកាលពីម្សិលមិញ។ <ដូច្នេះពន្យល់យើងមក ថាមានសំណួរថ្មីនោះ។> ខ្ញុំមិនគាំទ្រជាមួយនឹងអ្វីដែលលោកស្រីថា យើងត្រូវសំណួរដដែលៗ ដើម្បីទទួលបាននូវចម្លើយផ្សេងនោះឡើយ <បើមិនអ៊ីចឹងទេ តើការហាមឃាត់>ការសួរសំណួរដដែលៗវាមិនមានន័យអ្វីនោះឡើយ។ ដូច្នេះដើម្បីបញ្ជាក់ឲ្យបានច្បាស់ គឺថាសំណួរដដែលៗ គឺមិនអនុញ្ញាតឲ្យ<សួរ>បានទេ<តាមវិធាន៨៧(៣) នេះគឺជាច្បាប់។ តើមាន>សំណួរ<ថ្មីទេ។ ខ្ញុំមិនបានឮសំណួរថ្មីទេ តាំងពីពេលគាត់ចាប់សួរមក>។

**លោក លីវ សុវណ្ណា៖**

បាទ អរគុណលោកស្រី។ ប្រហែលជាការខ្វះខាតរបស់ខ្ញុំ ក៏ខ្ញុំមិនដឹងដែរ ព្រោះម្សិលមិញគឺខ្ញុំអត់ទាន់បានឮថា អ្នកដែលបង្ខំគាត់ហ្នឹងថាជាប្រធានកង។ តើប្រធានកងឈ្មោះអី? គឺយើងអត់ទាន់មានទេ។ អ៊ីចឹងព័ត៌មានទាំងអស់នេះ គឺខ្ញុំសួរនេះ គឺដើម្បីជួយឲ្យអង្គជំនុំជម្រះបានទទួលអង្គហេតុមួយដ៏ពេញលេញ។ អ៊ីចឹងខ្ញុំបាទសូមអនុញ្ញាតបន្តទៅសំណួរផ្សេង បើសិនជាមិនឲ្យខ្ញុំសួរកន្លែងនេះ។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ក្រៅពីគោលនយោបាយ លោកថា គេបានប្រាប់ពីនយោបាយហ្នឹង តើលោកបានស្តាប់ឮហ្នឹងគឺនៅពេលណាមួយ នៅក្នុងអង្គប្រជុំ ឬមួយក៏នៅក្នុងណា គោលនយោបាយដែលឲ្យរៀបអាពាហ៍-ពិពាហ៍នេះ?

[០៩:៣៦:២៣]

**លោកស្រី ស៊្វ សុធារី៖**

**ឆ៖** ខ្ញុំបានជម្រាបលោកពីម្សិលមិញហើយ ខ្ញុំថា រឿងកម្មវិធីអីគេមិនដែលហៅពួក១៧មេសា

ចូលរួមប្រជុំទេ។ បើគេហៅទៅហ្នឹង មានតែហៅយកសម្លាប់ ហើយយកទៅប្រើ។ អ៊ីចឹងខ្ញុំបានប្រាប់លោក ថាគោលនយោបាយ បើគេប្រាប់ ថាដើម្បីបន្តពូជ ដើម្បីបានកូន ដើម្បីការពារជាតិ ដើម្បីនាំបក្សដឹងគុណ គឺថ្ងៃដែលរៀបការហ្នឹងតែម្តង។ ឥឡូវនេះអង្គចៅក្រមមិនឲ្យខ្ញុំឆ្លើយថាឈ្មោះអីក៏ដោយ ក៏បានប្រាប់ពីម្សិលមិញហើយ មិនមែនថា ខ្ញុំមិនប្រាប់ទេ ថាអ្នកដែលបង្ខំយើង អ្នកដែលណែនាំយើងក្នុងពេលហ្នឹង គឺយើងមិនដែលដឹងឈ្មោះទេ ព្រោះឈ្មោះអ្នកខ្មែរក្រហមហ្នឹង មិនដែលដឹងឈ្មោះ។ សូម្បីតែរឿងអ្នកដឹកនាំប្រទេសហ្នឹង តាម៉ុក ហ្នឹងមិនមែន តាម៉ុក ទេ ការពិតឈ្មោះផ្សេង។ អ្ហ៎! ប៉ុល ពត ហ្នឹងមិនមែន ប៉ុល ពត ទេគឺ សា ឡុតស។ បើអ៊ីចឹងបានសេចក្តីថាឈ្មោះផ្សេងពីគ្នា ខ្ញុំមិនអាចឆ្លើយបានថាឈ្មោះណាជាពិតប្រាកដ ទៅជាហៅ“តា”, គេហៅ“យាយ”, គេហៅ“មីង”, ហៅ“ពូ”។ អ៊ីចឹងខ្ញុំមិនអាចប្រាប់បានទេ ហើយសូមរង់ចាំស្តាប់តែពាក្យខ្ញុំឆ្លើយ ខ្ញុំហ៊ានប្រឈមមុខនឹងមុខអង្គតុលាការ ខ្ញុំអត់ចោទគេផ្តេសផ្តាស។ ខ្ញុំគ្មានរឿងពិតជាក់ស្តែង ខ្ញុំអត់និយាយ។ សូមទោស។

**ស៖** បាទ អរគុណ។ ឥឡូវខ្ញុំចូលដល់ថា លោកថា ម្សិលមិញគឺលោកបានលើកឡើងថា លោកហើយនិងប្រពន្ធរបស់លោកហ្នឹង គឺបានជជែកគ្នាមុន ថាឲ្យគាត់ជួតក្បាលក្រមា ហើយលោកបង់កក្រមា ហើយថាយើងត្រូវតែរៀបការជាមួយគ្នាបាន១។ ពេលនុ៎ង តើប្រពន្ធរបស់លោកហ្នឹងបានឆ្លើយតបជាមួយលោកថាម៉េច?

[០៩:៣៨:២៨]

**ឆ៖** ខ្ញុំពិបាកជម្រាបលោកមេធាវីដែរ ខ្ញុំមានឱកាស ក្នុងពេលនេះខ្ញុំបានប្រាប់ថា ខ្ញុំស្គាល់ប្រពន្ធខ្ញុំ បាននៅកងជាមួយគ្នា នៅភូមិជិតគ្នា។ ខ្ញុំបានឃើញ មានចិត្តអាណិត កំព្រាដូចគ្នា ខ្ញុំបានឆ្លៀតឱកាសគឺឆ្លៀតឱកាសហ្នឹង បើឲ្យគេដឹង គេយកទៅវ៉ៃចោលមុនបាត់ហើយ។ យើងឆ្លៀតឱកាស ក៏ទៅប្រាប់ថាឲ្យជួតក្បាលក្រមាទៅណ៎ា ខ្ញុំបង់កក្រមា ក្រែងលោមានផែនការអីទៅ យើងស្រួលងាយរង់ចាំគ្នា។ ខ្ញុំបាននិយាយពីម្សិលមិញអស់ហើយ បើលោកមេធាវីនៅតែស្តាប់មិនបានទៀត ខ្ញុំពិបាកនឹងឆ្លើយណាស់សូមអភ័យទោស។

**ស៖** សូមទោស ខ្ញុំសួរហ្នឹងគឺចង់ដឹងពីការឆ្លើយតបរបស់ខាងប្រពន្ធលោកមកវិញ តើគាត់សម្តែងជាកាយវិការ ឬក៏គាត់ងក់ក្បាល ឬមួយក៏គាត់និយាយពាក្យអីតបមកលោកវិញ នៅពេលដែលលោកស្នើសុំបែបនោះ?

**ឆ៖** ខ្ញុំពិបាករង់ចាំ ខ្ញុំប្រាប់ទៅប្រពន្ធខ្ញុំ ថាប្រពន្ធខ្ញុំគ្មានអត់ចេញស្តីអីទេ ស្រីមិនដែលហ៊ានចេញ

ស្ដីមកតវ៉ាយើងប្រុស។ ខ្ញុំប្រាប់ប៉ុណ្ណឹង ដល់ខ្ញុំស្គាល់ យើងកំព្រាដូចគ្នា។ ខ្ញុំបានប្រាប់ហើយ បញ្ជាក់ហើយបញ្ជាក់ទៀតថា ខ្ញុំកំព្រា ខ្លួនឯងកំព្រា អ៊ីចឹងអត់មានម៉ែឪដូចគ្នា យើងធ្វើតាមគ្នាទៅ ខ្ញុំប្រាប់តាមរបៀបទទូរក្រមា ទទូរអីហ្នឹងហើយ អីហើយ ឆក់ឱកាសនោះ មិនមែនទៅអង្គុយជជែកគ្នាលេងរាល់ថ្ងៃដូចនៅកោះពេជ្រ ឬមាត់ទន្លេទេ សូមលោកមេធាវី ប្រាប់ថា ខ្ញុំមិនអាចចងចាំដែលពាក្យប្រពន្ធខ្ញុំឆ្លើយមកវិញរបៀបម៉េច របៀបបងឯងធ្វើម៉េចៗអ៊ីចឹង ខ្ញុំអត់អាចឆ្លើយបាន។ ខ្ញុំគ្រាន់តែឆ្លើយថា ខ្ញុំបានប្រាប់ទៅដៃគូរបស់ខ្ញុំឲ្យធ្វើតាមខ្ញុំទៅ ជូតក្បាលក្រមាអ៊ីចឹងខ្ញុំនេះទៅ អាហ្នឹងខ្ញុំនិយាយបានខ្លះ។ តែបើនិយាយអាពាក្យតម្អូញតម្អែរ ពាក្យរៀបរាប់ ខ្ញុំមិនអាចនិយាយប្រាប់មេធាវីអស់ទេ។ ខ្ញុំឈឺចាប់ខ្លាំងណាស់អំពើអស់ទាំងនេះ។

**ស៖** បាទ អរគុណ។ ម្សិលមិញលោកបាននិយាយថា ការរៀបការហ្នឹងគឺមានចម្រុះជាមួយខាងប្រជាជនថ្មី ក៏ដូចជាប្រជាជនចាស់។ អ៊ីចឹងខ្ញុំចង់សួរថា តើប្រពន្ធរបស់លោកដែលលោកអះអាងថាគាត់ជាប្រធានកង១៧មេសា ប្រជាជន១៧មេសាហ្នឹង តើគាត់ជាប្រជាជនចាស់ ឬមួយក៏ជាប្រជាជន១៧មេសា?

[០៩:៤១:២១]

**ឆ៖** លោកនៅតែសួរដដែលៗ។ ខ្ញុំ១៧មេសា គេឲ្យទៅរៀបប្រធានកងជាមួយ១៨មីនាទេ។ ប្រពន្ធខ្ញុំក៏១៧មេសាដែរ ខ្ញុំៗរៀបពីម្សិលមិញ ឯកឧត្តមទាំងអស់ក៏ឮដែរ មេធាវីខាងដើមបណ្ដឹងក៏ឮដែរ ហើយលោកនៅចង់សួរទៀត ថាតើជាមេធា -- ជា១៧មេសា ឬ១៨? អ្នក១៧ គេរៀប១៧ អ្នក១៨ គេរៀប១៨។ ជនពិការ កងទ័ព គេលើកទឹកចិត្ត។ រឿងមូលដ្ឋាននៅនេះ ខ្ញុំបានជម្រាបពីម្សិលមិញអស់ហើយ គាត់នៅតែសួរខ្ញុំអ៊ីចឹងទៀត ខ្ញុំពិបាកនឹងឆ្លើយតប ប៉ុន្ដែលោកសួរមួយអស់ចុះ ខ្ញុំនឹងឆ្លើយ រង់ចាំឆ្លើយជាមួយលោក។ អរគុណ។

**ស៖** បាទ អរគុណច្រើន។ ឥឡូវខ្ញុំចង់ដឹងថាតើគាត់ប្រធានកងហ្នឹង តើគាត់គ្រប់គ្រង ឬដឹកនាំប្រជាជនថ្មីប៉ុន្មាននាក់ដែរ? លោកបានអាចដឹងទេ?

**ឆ៖** តាមបែបផែនរបស់កងនារី តែយើងទៅឈរបៀតកន្លែងគេនៅ មិនបានផង លោក។ ទៅសួរខ្ញុំថាគេក្ដាប់ប៉ុន្មាននាក់ គេធ្វើរួមប៉ុន្មាននាក់ អីប៉ុន្មាននាក់ ខ្ញុំមិនដឹង ប៉ុន្ដែដឹងតួនាទីជាប្រធានកង។ ត្រង់អ្នកឯង គេចែកក្រុមប៉ុន្មានអីប៉ុន្មាន អត់ដឹងទេ ព្រោះជំនាន់នោះឈរនិយាយគ្នាអត់ស្រួលទេ ខ្ញុំប្រាប់មេធាវី ប្រាប់ថាគាត់ហ្នឹងឈរនិយាយគ្នាអត់ស្រួលទេ។ សូម្បីតែខ្ញុំហ្នឹង តែម្ដាយបង្កើតមិនហ៊ាននិយាយ

ជាមួយស្រួលបួល ស្វាត់ៗ។ បើអ៊ីចឹងអត់អាចដឹងទេ ការរាក់ជ្រៅ គេដឹកនាំប៉ុន្មាននាក់អីប៉ុន្មាននាក់ ខ្ញុំអត់ៗដឹងទាំងអស់។ ខ្ញុំមិនដឹងពីសមត្ថភាពរបស់ខាងស្ត្រីហ្នឹងគេធ្វើរៀបម៉េចអីរបៀបម៉េច ព្រោះស្ត្រីគេក្តាប់ដោយស្ត្រី បុរសដោយបុរស។ បើប្រុសយើងមិនប៉ានជ្រួតជ្រែកទៅ មានលទ្ធភាព បើប្រធានកងគេចាស់ៗទេ បានគេទៅ។ ថ្មីៗ ទុកជាឈ្មោះប្រធានកងដូចគ្នា ក៏មិនប៉ានទៅអើតដែរ ព្រោះការងាររបស់គេហ្នឹង គេបែកចែកគ្នាដាច់ហើយ។ ហើយបុរស និងស្ត្រីក៏មិនអាចទៅនិយាយគ្នាក្នុងនាមយុវជនយុវនារីហ្នឹង ក្នុងប្រធានកងដូចគ្នា ក៏មិនប៉ាននិយាយគ្នាដែរ។ លោកដឹងតើ ស្រីនិងប្រុសនិយាយជាមួយគ្នាខុសរបៀប ខូចសីលធម៌។

[០៩:៤៣:៤៤]

**ស៖** បាទ--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ -- ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសូមជម្រាបថា លោកឆ្លើយតាមសំណួរដែលមេធាវីគាត់សួរ។ ចម្លើយដែលឆ្លើយថា មិនដឹង ក៏ជាចម្លើយដែរ។ សូមអញ្ជើញ!

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បាទអរគុណលោកប្រធាន។ ខ្ញុំសុំបន្តសំណួររបស់ខ្ញុំបាទថែមទៀត។ តើលោក ម្សិលមិញ បានលើកឡើងថា ពេលដែលរៀបអាពាហ៍ -- ថ្ងៃរៀបការហ្នឹងគឺមានភ្លើងអគ្គិសនីនៅលើទួលនោះ។ តើទួលនោះមានភ្លើងអគ្គិសនីជាប្រចាំ ឬមួយក៏ប្លែកតែថ្ងៃដែលលោករៀបការទេទើបមានភ្លើងអគ្គិសនីបំភ្លឺ?

**លោកស្រី ស៊ូ សុធារី៖**

**ឆ៖** ខ្ញុំអត់ដឹងថា កន្លែងនោះមានភ្លើងពីអង្កាល់ទេ ប៉ុន្តែថ្ងៃខ្ញុំរៀបការហ្នឹង គឺឃើញមានភ្លើងអគ្គិសនីរបស់គេ មាន។

**ស៖** ម្សិលមិញ ក៏លោកបានថ្លែងថា គេឲ្យតម្រង់ជួរជាពីរជួរ។ អ៊ីចឹងលោកនៅជួរទី៧ លេខរៀងទី៧ អ៊ីចឹងពីលេខរៀងទី១, ទី២ គឺជាប្រជាជនចាស់។ អ៊ីចឹងការតម្រង់ជួរហ្នឹង គឺគេតម្រង់ជួរចម្រុះតាំងប្រជាជនចាស់ ប្រជាជនថ្មីលាយគ្នា ឬមួយគេបែងចែកយ៉ាងម៉េចដែរ?

[០៩:៤៥:៣៩]

**ឆ៖** គេបែងចែករួចហើយ ប្រជាជនចាស់ គេរៀបប្រជាជនចាស់ ប្រជាជនថ្មី រៀបប្រជាជនថ្មី អ៊ីចឹងខ្ញុំជួរទី៧។ ប្តេជ្ញាចាប់ដៃគ្នាហើយ ខ្ញុំមកឈរមុខគេ គេហៅខ្ញុំចូលក្រោយ ខ្ញុំបានជម្រាបពីម្សិល-

មិញហើយ។

**ស៖** បាទ ខ្ញុំៗចង់ដឹងលម្អិតបន្តិច ថាតើពេលដែលមានទាំង១០៧គូ ដែលទៅជុំគ្នាហ្នឹងគឺមានប្រជាជនចាស់ និងប្រជាជនថ្មី៨០គូ។ អ៊ីចឹងលោកថា តម្រង់ជួរមុនដែលគេចាប់ផ្តើមកម្មវិធី គឺគេឲ្យយើងតម្រង់ជួរ។ អ៊ីចឹងខ្ញុំសួរថា តើជួរដែលតម្រង់ជួរហ្នឹង វាមានប៉ុន្មានជួរ? ពីរជួរ បួនជួរ ឬប៉ុន្មានជួរឲ្យច្បាស់ត្រង់ហ្នឹង?

**ឆ៖** ពួកចាស់ គេមួយជួរគ្នាទៅ ពីរជួរគ្នាគេទៅ។ ពួកខ្ញុំថ្មី ឈរពីរជួរពួកខ្ញុំថ្មីៗ។

**ស៖** បាទ ហើយនៅក្នុងកម្មវិធីនោះ តើមាន -- លោក ម្សិលមិញបានប្រាប់ហើយ អ្នកចូលរួមជាអធិបតីហ្នឹង មានមេឃុំ មានប្រធានសហករណ៍ មានប្រធានភូមិ តែខ្ញុំចង់ដឹងថា តើមានការឡើងថ្លែងរបស់ថ្នាក់ដឹកនាំទាំងនោះ គាត់បានឡើងថ្លែង ឬក៏ឡើងនិយាយអីទេមុនដែលឲ្យយើងរៀបការនោះ?

**ឆ៖** ខ្ញុំបានប្រាប់ហើយថា មានគេឡើងថ្លែង។ គេប្រាប់ថា អង្គការដឹងគុណអ្នកឯង រៀបការប្រពន្ធឲ្យអ្នកឯង រៀបការប្តីឲ្យអ្នកឯង។ ក្នុងពេលនេះ ដើម្បីតបស្នងសងគុណអង្គការវិញទៅ គឺកូនចៅ។ អង្គការគេនិយាយសំខាន់បំផុត គឺថាចង់បានតែកូនចៅប៉ុណ្ណឹងទេ ប្រជាជនយើងមិនសូវមាន។

[០៩:៤៧:៥៨]

**ស៖** តើថ្លែងនោះ ថ្លែងតែម្នាក់ ឬក៏ថ្លែងច្រើនគ្នា ក្នុងថ្នាក់អ្នកដឹកនាំហ្នឹង? ហើយបើអ្នកថ្លែងនុ៎ងតើឈ្មោះអីដែរ លោកចាំទេ?

**ឆ៖** អត់ចាំទេឈ្មោះ ខ្ញុំប្រាប់ហើយថា ខ្ញុំមិនសូវជាចាំរឿងប្រធានណាឈ្មោះអី ប្រធានណាឈ្មោះអី តែទាល់តែទៅឃើញតែម្តង បានស្គាល់ថាជាពួក ខ្ញុំអត់ដឹងថាឈ្មោះអីជាឈ្មោះអី ជួនកាលគេហៅអ៊ីចេះ ជួនកាលគេហៅអ៊ីចុះ។

**ស៖** តើអ្នកឡើងនិយាយហ្នឹង ប៉ុន្មាននាក់ដែរ ម្នាក់ ពីរនាក់ ឬក៏បីនាក់?

**ឆ៖** តាមខ្ញុំដឹងច្បាស់លាស់ទៅ មិនភ្លេចទេ គឺនិយាយតែម្នាក់ ប្រធានស្រុកហ្នឹង គណៈតាស្រុកហ្នឹងទេឡើងនិយាយ គ្មានអ្នកណាហ៊ានឡើងនិយាយ។ តែតាហ្នឹងចាប់ក្បាលមីក្រូហើយ អាក្រោមៗម៉េចហ៊ានក្រោយ។

**ស៖** ខ្ញុំចង់ដឹងថា ថាតើអ្នកដែលចូលរួម ដែលតាមការកត់សម្គាល់របស់លោកហ្នឹង អ្នកចូលរួមជាមួយលោកហ្នឹង តើគេមានប្រើប្រាស់ក្រមាដែរទេ អ្នកផ្សេងទៀតនោះ?

**ឆ៖** កុមារហ្នឹងជាមនុស្ស ឬក្រមាអី? សួរម្តងទៀត ឲ្យច្បាស់។

**ស៖** បាទ សូមទោស។ ក្រមាៗដែលលោកថា លោកមានក្រមាមួយបង់ក ហើយប្រពន្ធលោក គឺគាត់ឲ្យជូតក្បាល។ អ៊ីចឹងខ្ញុំសួរថាតើអ្នកផ្សេងទៀត គាត់ប្រើប្រាស់ក្រមាដែរឬទេ?

**ឆ៖** បាទ រឿងក្រមា ជំនាន់ ប៉ុល ពត សូម្បីតែកូនក្មេងក៏មានប្រើដែរ ទាំងអស់គ្នា។

[០៩:៥០:៣៥]

**ស៖** ហើយថ្ងៃដែលរៀបការនោះ ដែលតម្រង់ជួរហ្នឹង តើពួកគេផ្សេងទៀតហ្នឹង គេក្រមាហ្នឹង គេដាក់នៅកន្លែងណាដែរ? គេប្រើប្រាស់ជាប់ខ្លួនហ្នឹង គេដាក់ភ្ជាប់ម៉េចដែរ លោកអាចរៀបរាប់បានខ្លះទេ?

**ឆ៖** ខ្ញុំពិបាកនឹងរៀបរាប់ដែរ តែរឿងខ្ញុំជាក់ស្តែង រឿងឃើញជាក់ស្តែងពេលរៀបការមួយ គឺក្រមាគេបង់កទាំងអស់។

**ស៖** ចុះខាងនារី គាត់បង់កទាំងអស់ដែរ ឬមួយក៏យ៉ាងម៉េចដែរ ខាងនារី?

**ឆ៖** ខ្ញុំបានជម្រាបពីម្សិលមិញហើយ ខ្ញុំថាបង់កទាំងអស់គ្នា បានៗខ្ញុំមានប្រើបច្ចេកទេសមួយឲ្យប្រពន្ធខ្ញុំជូតក្បាលក្រមាហ្នឹង ព្រោះវាបង់កទាំងអស់។

**ស៖** ចុះពេលដែលតម្រង់ជួរហ្នឹង តើលោកមានសម្លឹងទៅរកមើលអនាគតប្រពន្ធរបស់លោកដែរទេ ពេលនៅក្នុងជួរហ្នឹង?

**ឆ៖** បើមិនសម្លឹង មានផែនការអី ធ្វើម៉េចដឹងរឿងយើង ទាល់ដឹង សម្លឹង មើលឃើញឲ្យច្បាស់ថានៅត្រង់ណា។

**ស៖** ដោយសារចំនួនវា៨០គូ បើអ៊ីចឹង៨០នាក់ ដែលតម្រង់ជួរហ្នឹង អ៊ីចឹងខ្ញុំចង់ដឹងថា តើប្រពន្ធលោកឈរហ្នឹង តើឈរនៅខាងមុខ ខ្ញុំមិនឲ្យលោកទាយជាក់លាក់ទេ លើកជាក់លាក់ទេ ខាងមុខកណ្តាល ឬមួយក៏ខាងក្រោយគេបង្អស់?

[០៩:៥៣:០៣]

**ឆ៖** ជម្រាបមេធាវី មិនមែន៨០គូទេ បើចង់សួរៗឲ្យអស់ចំណុច ព្រោះគូ១០៧គូ -- ១១៧គូ។ ៨០គូនេះ តែពួកខ្ញុំមូលដ្ឋាន -- អ៎ុនែ! ១៧មេសាទេ។ បើអ៊ីចឹង៨០គូ សួរតែពីរឿង១៧មេសា ខ្ញុំឆ្លើយ១៧មេសា ដល់សួរមានវគ្គមានខាងនេះ ខ្ញុំពិបាកឆ្លើយ។ អ៊ីចឹង១០៧គូនេះ ៨០គូ១៧មេសា ហើយខ្ញុំគូទី៧។ អ៊ីចឹងតែកន្លែងណាប្រពន្ធឈរ ខ្ញុំសម្លឹងរួចហើយ បានមើលឃើញច្បាស់។

**ស៖** ខ្ញុំសូមបញ្ជាក់ឡើងវិញបន្តិច អំមិញដោយសារខ្ញុំថា៨០គូ ដោយសារលោកថា តម្រង់ជួរ

ហ្នឹង វាគេចែកចេញជាពីរក្រុម។ ក្រុមខាង១៧មេសាហ្នឹងមួយក្រុម ក្រុមខាងប្រជាជនចាស់មួយក្រុម។ អ៊ីចឹងឥឡូវលោកថា វាមិនមែន៨០គូទេ។ អ៊ីចឹងតើការតម្រង់ជួរហ្នឹងពីរជួរ ឬបួនជួរ? សូមលោកបញ្ជាក់ឲ្យបានច្បាស់លាស់ចំណុចនេះ។

**ឆ៖** ខ្ញុំប្រាប់ហើយ ១០៧គូ ប៉ុន្តែពួកខ្ញុំ៨០គូ គឺឈរជិតគ្នាហ្នឹង គ្រាន់តែពីរជួរ ខាងគេពីរជួរ។

**ស៖** បាទ ខ្ញុំច្បាស់ហើយ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើប្រពន្ធរបស់លោកហ្នឹង គាត់ឈរ ដែលឈរក្នុងជួរ៨០គូហ្នឹង តើគាត់ឈរនៅដើមគេ កណ្ដាលគេ ឬក៏ក្រោយគេ?

**ឆ៖** នៅឈរជិតគ្នាហ្នឹង។

**ស៖** ជួរហ្នឹង តើជួរស្ត្រីបុរសនៅពីរផ្សេងគ្នា ឬមួយក៏ជិតគ្នាម៉េច លោកអាចពន្យល់បាន ពាក្យថាជិតគ្នាហ្នឹង លោកអាចពន្យល់បានទេ?

**ឆ៖** ខ្ញុំមិនដឹងពន្យល់ប្រាប់ម៉េចទេ ថាពីរជួរហើយ នៅឈរជិតគ្នាទៀត។ ខ្ញុំដឹងតែប៉ុណ្ណឹង មិនដឹងពន្យល់របៀបនេះ អត់ចេះពន្យល់។

**ស៖** ឧទាហរណ៍លោកថា លោកឈរជួរទី៧ រាប់ពីមុខមកលោកនៅលេខរៀងទី៧ ចុះប្រពន្ធលោកដែលឈរម្ខាងជួរទៀតហ្នឹង តើគាត់នៅប៉ុន្មានប្រហែលជាជួរទីប៉ុន្មាន អីទីប៉ុន្មានដែរ លោកអាចដឹងថា ពន្យល់កន្លែងហ្នឹងបានទេ?

[០៩:៥៦:៣៥]

**ឆ៖** ខ្ញុំបានជម្រាបហើយពីម្សិលមិញ ខ្ញុំប្រកាសថាខ្ញុំជួរទី៧ ពេលខ្ញុំចាប់ដៃគ្នាហើយទេ បានគេហៅចូលមកជួរទី៧ គឺប្ដេជ្ញា។ តែអង្កាល់ពីពេលឈរហ្នឹង មិនមែនទី៧ទេ គឺឈររះពីរជួរហ្នឹងទៅទាំងអស់គ្នា។ ហ្នឹងខ្ញុំប្រាប់បញ្ជាក់ហើយបញ្ជាក់ទៀតថាខ្ញុំជួរទី៧ ពេលដែលខ្ញុំប្ដេជ្ញា គេហៅខ្ញុំចូលមកប្ដេជ្ញាមុនគេ ខ្ញុំទី៧ហើយ ១, ២, ៣, ៤, ៥, ៦, ៧ ខ្ញុំប្ដេជ្ញាចុងក្រោយគេ។

**ស៖** បាទ អរគុណ។ អ៊ីចឹងវាកាន់តែច្បាស់ ឲ្យអង្គសវនាការយល់កាន់តែច្បាស់ហើយ។ អ៊ីចឹងខ្ញុំចង់សួរថា គម្លាតដែលលោកឈរទៅកន្លែងទីតាំងដែលប្រពន្ធលោកឈរនោះ តើគម្លាតពីគ្នាប៉ុន្មានម៉ែត្រដែរ?

**ឆ៖** នៅជិតគ្នាប្រហែលខ្ទង់១ម៉ែត្រ២ហ្នឹងឯង។

**ស៖** ឥឡូវខ្ញុំសូមចូលដល់ពេលដែលរៀបការហើយ រៀបការហើយនុ៎ង តើលោក -- ដែលលោកលើកឡើងពីម្សិលមិញបានលើកហើយ ខ្ញុំចង់បញ្ជាក់ពេលវេលាឲ្យបានជាក់លាក់បន្តិច តើលោក

តាមការចងចាំរបស់លោក លោកអាចឆ្លើយបានទេថា ប៉ុន្មានខែក្រោយរៀបការ ទើបអាចលោករួមដំណេកជាមួយប្រពន្ធលោកហ្នឹង បើសិនជាលោកអាចចងចាំបាន?

**ឆ៖** អត់ចាំថ្ងៃទេ ព្រោះរយៈពេលយូរបានខ្ញុំបានរួមដំណេកគ្នា។

**ស៖** តើបើអាចគិតជាខែ អាចលោកអាចចាំបានទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[០៩:៥៨:៥៣]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី ចាំមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហម ចាំលោកឆ្លើយ។

**លោកស្រី ស៊ូ សុធារី៖**

**ឆ៖** ខ្ញុំអត់បានចាំទេ រឿងបានរួមរស់នៅជាមួយគ្នា អាយកគ្នាហ្នឹងប៉ុន្មានថ្ងៃៗអត់ដឹង ព្រោះអត់មាន នៅពេលវេលាណារាប់ថ្ងៃទេ ធ្វើម៉េចបន់ឲ្យរួចតែភ្លឺ។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** អ៊ីចឹងលោកអាច ម្សិលមិញលោកថ្លែងថា មានរយៈពេលហ្នឹងគឺមានការហៅលោកទៅតែងតែហៅទៅសួរ ទៅនាំជាបន្តបន្ទាប់ទាក់ទងនឹងរឿងថា មិនព្រមរួមភេទ មិនព្រមរួមដំណេកជាមួយប្រពន្ធ។ អ៊ីចឹងខ្ញុំចង់ដឹងតើលោកអាចៗចាំបានទេថា គេហៅលោកទៅហ្នឹងប៉ុន្មានដងដែរ មុនដែលរហូតដល់ពេលដែលលោកបានរួមដំណេកហ្នឹង?

**ឆ៖** មិនអស់មិនហើយទេ គេហៅទៅរៀនសូត្រ ប្រធានក្រុមគេហៅទៅប្រាប់ហ្នឹង ខាងស្ត្រីគេហៅខាងស្រី មិនអស់មិនហើយ អត់ចាំ មិនបានដឹងដង។

**ស៖** ក្រៅពីហៅលោកទៅប្រាប់ហ្នឹង តើគេមានចាត់វិធានការអីបន្ថែមទៀតទេ?

**ឆ៖** ដឹងគេចាត់វិធានការម៉េចទេ ដល់ចុងក្រោយគេ បានគេបង្ខំខ្លាំង គេឲ្យស្រា ឲ្យផឹកពីរនាក់ប្ដីប្រពន្ធហ្នឹងទៅ។ តែខ្ញុំវាមិនចាំថ្ងៃចាំពេល ព្រោះពេលជំនាន់ពេលខ្មែរក្រហម យើងអត់រកពេលចាំម៉ោងចាំថ្ងៃ ចាំខែបានទេ។

[១០:០១:២២]

**ស៖** បាទ ឥឡូវខ្ញុំសូមបញ្ជាក់បន្ថែម លើព័ត៌មានម្សិលមិញលោកថា បន្ទាប់ពីគេឲ្យស្រាមក គឺលោកបានក្រេបស្រាហ្នឹង ហើយថា ហៅទឹកដូវនិស្ស័យហ្នឹង ធ្វើឲ្យលោក ហើយនិងប្រពន្ធលោកក៏បាន

រួមដំណេកជាមួយគ្នា។ អ៊ីចឹងខ្ញុំចង់ដឹងថា ពេលដែលរួមដំណេកជាមួយប្រពន្ធលោកពេលនោះ តើលោកគិតថា ជាការរួមដំណេកដោយអារម្មណ៍ផ្ទាល់របស់ប្ដីប្រពន្ធ ឬមួយក៏រួមដំណេកដោយសារអ្វីដែរ?

**ឆ៖** សូមទោស។ ខ្ញុំមិនអាចឆ្លើយបានពេលអាការរួមដំណេកជាមួយគ្នា ស៊ីករបៀបម៉េច អីរបៀបម៉េច ខ្ញុំមិនអាចឆ្លើយបាន។

**ស៖** បាទ សូមទោសប្រហែលជាសំណួរខ្ញុំមិនច្បាស់។ ខ្ញុំចង់សួរអារម្មណ៍ដែលលោកពេលដែលចាប់ផ្ដើម យើងថារួមភេទហ្នឹង អារម្មណ៍របស់យើងនេះ របស់លោកនេះ តើវាជាការរួមភេទដោយចេញពីឆន្ទៈ ចេញពីរបស់លោក ឬមួយក៏ក្នុងអារម្មណ៍របស់លោកគិតម៉េច បានជាឈានដល់ការរួមភេទគ្នាហ្នឹង រួមដំណេកគ្នាហ្នឹង?

**ឆ៖** ខ្ញុំបានប្រាប់ពីម្សិលហើយ សូមអង្គចៅក្រមអត់ទោសឲ្យខ្ញុំ ថាខ្ញុំបានប្រាប់ថា ខ្ញុំគ្មាននិស្ស័យជាមួយស្រីញីទេប៉ុនក្រចកទេ។ លោកបើស្ដាប់ខ្ញុំជាប្រភេទទី៣ លោកប្រហែលជាមិនហ៊ានសួរអាហ្នឹងទេ ព្រោះខ្ញុំអត់មានអារម្មណ៍អីទាំងអស់ ខ្លាចងាប់តែប៉ុណ្ណឹងទេ ដែលទៅនេះនោះ។

[១០:០៣:១១]

**ស៖** បាទ អ៊ីចឹងការរួមភេទរបស់លោក ដោយសារលោកខ្លាចស្លាប់។ អ៊ីចឹងខ្ញុំចង់ដឹងថា តើការខ្លាចស្លាប់ហ្នឹង មូលហេតុអីបានជាលោក គិតថា មិនព្រមរួមភេទជាមួយ – រួមដំណេកជាមួយប្រពន្ធលោកហ្នឹង គឺអាចស្លាប់ហ្នឹង តើមានមូលហេតុអីគេខ្លះ លោកអាចលើកបានទេ?

**ឆ៖** សូមលើកសំណួរម្ដងទៀត។

**ស៖** អំមិញលោកបានលើកឡើងថា លោករួមដំណេកដោយសារខ្លាចស្លាប់។ អ៊ីចឹងខ្ញុំចង់ដឹងថា មូលហេតុអី ឬក៏ហេតុផលអីដែលលោកគិតថា បើសិនជាមិនរួមដំណេកវិញនោះ វាអាចនឹងលោកស្លាប់ន៎ុង? អ៊ីចឹងខ្ញុំចង់ដឹងពីមូលហេតុ ឬក៏ហេតុផលអីដែលលោកគិតបែបនេះ?

**ឆ៖** ខ្ញុំពិបាកនឹងឆ្លើយដែរ ពាក្យនេះ ព្រោះវាជាន់នឹងអាខ្ញុំឆ្លើយរួចមកហើយ គេយកទៅរៀនប្រជុំ រៀនសូត្រកសាង សុទ្ធតែមានវិធានការហើយ។

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់កន្លែងនេះបន្ថែមបន្តិច អំមិញលោកថាគេហៅទៅប្រជុំ ទៅរៀនសូត្រជាច្រើនលើក ចាំមិនអស់ទេ ហើយខ្ញុំសួរថា តើមានវិធានការអី? អ៊ីចឹងលោកថា គេឲ្យស្រា។ អ៊ីចឹងជាវិធានការរបស់គេ គឺគេឲ្យស្រាមកលោក ដើម្បីលោកពិសាជាមួយប្ដីប្រពន្ធ។ អ៊ីចឹងខ្ញុំសួរថា តើក្រៅពីវិធានការដែលលោកគិតថា វិធានការក្រៅពីហ្នឹង តើមានតម្រុយអី ក៏មានហេតុផលអី លោកអាច

01355068



ពន្យល់បានទេ?

[១០:០៥:៣១]

**ឆ៖** វិធានការគេមាន។ គេហៅទៅកសាងពីរបីសា រាប់មិនអស់មិនហើយហ្នឹង គេថាត្រូវតែសម្លាប់ចោល បើមិនព្រមធ្វើគ្នា។ ឥឡូវហ្នឹងខ្ញុំពេលដល់ស្រវឹងអីចឹង ប្រធានភូមិគេឲ្យស្រាមក ខ្ញុំផឹកពីរនាក់ប្តីប្រពន្ធខ្ញុំទៅ ក៏បានទៅជាមួយគ្នាទៅ។ ហើយឲ្យខ្ញុំផ្តោះផ្តងម៉េចទៀត? អត់មានបញ្ចេញយោបល់អីថា ចេះប្រើពាក្យនេះ ប្រើពាក្យនោះទេ។ សូមលោកមេធាវីឈប់សួរអារឿងការយកគ្នាហ្នឹងទៅ ខ្ញុំនិយាយមិនកើតទេ។

**ស៖** ឥឡូវខ្ញុំសុំបែរទៅសំណួរពីម្សិលមិញដែលលោកថា មានលោកស្គាល់មិត្តភក្តិស្រីៗ -- មិត្តភក្តិដែលមានភេទទីពរដូចលោកហ្នឹង ពីរបីនាក់ដែរ ដែលគេបង្ខំឲ្យរៀបការ ហើយគាត់មិនព្រម គាត់ចងក និងលេបថ្នាំ។ អីចឹងខ្ញុំចង់សួរថា តើពួកគាត់ហ្នឹងនៅក្នុងកងជាមួយលោកដែរ ឬក៏មិនមែនទេ?

**ឆ៖** កងចល័តមិននៅជាមួយគ្នាទេ។ កងចល័តនៅផ្សេងពីគ្នា ក៏ប៉ុន្តែគេឃុំផ្សេង ខ្ញុំឃុំផ្សេង គ្រាន់តែនៅបៀតធ្វើការជាមួយគ្នា រួមគ្នា។

**ស៖** តើលោកអាចចាំឈ្មោះពួកគាត់ខ្លះទេ? គាត់ឈ្មោះអីគេខ្លះទៅ?

**ឆ៖** ខ្ញុំអត់អាចចាំទេ ព្រោះវានៅកងខុសគ្នា ហើយឃុំខុសគ្នាទៀត។ គ្រាន់តែដឹងថា អ្នកនេះប្រភេទដូចខ្ញុំ អ្នកនោះប្រភេទដូចខ្ញុំ។ បាននិយាយគ្នាតែប៉ុណ្ណឹង រឿងឈ្មោះមិនដែលហៅគ្នាទេ។

**ស៖** តើលោកឧស្សាហ៍បានប្រាស្រ័យទាក់ទង ឬក៏និយាយគ្នាញឹកញាប់ទេ ជាមួយពួកគាត់ទាំងនោះ?

**ឆ៖** ជំនាន់នេះ ជំនាន់សេរី ខ្ញុំនិយាយម៉ោងប៉ុន្មានក៏បានដែរ ជាមួយប្រភេទទីពរគ្នាខ្ញុំ។ តែជំនាន់ខ្មែរក្រហម រកតែពេលច្រកបាយអត់កើត ពេលបត់ជើងអត់កើតផង រឿងអីត្រូវបាននៅអង្គុយនិយាយគ្នា ប្រាស្រ័យទាក់ទងដឹងរឿងរ៉ាវអីច្រើនទេ។

[១០:០៨:១៤]

**ស៖** ចុះបើលោកមិនដែលបានប្រាស្រ័យទាក់ទងនិយាយគ្នាច្រើន ហេតុអីបានជាលោកដឹងថាពួកគាត់ចងក ឬពួកគាត់លេបថ្នាំសម្លាប់ខ្លួន? ហេតុអីបានជាលោកដឹង?

**ឆ៖** ព្រោះខ្ញុំបានជម្រាបហើយថា ធ្វើការជិតគ្នា រឿងអីដែលធ្វើការជិតគ្នា តែងតែដឹងបន្តិចបន្តួច។

**ស៖** តើលោកដឹងហ្នឹងក្រោយពីលោករៀបការ ឬក៏មុនពេលដែលលោករៀបការ?

**ឆ៖** ខ្ញុំបានជម្រាបតាំងពីម្សិលមិញថា ខ្ញុំបានដឹងរឿងរ៉ាវអស់នេះ ស្ដាប់នេះ គឺមុនខ្ញុំរៀបការ។

**ស៖** ហើយលោកមិញថាដឹងគាត់ចងក លេបថ្នាំ។ អ៊ីចឹងមូលហេតុអីបានជាលោកដឹង អះអាងថា គាត់ចងក ឬលេបថ្នាំដោយសារគេបង្ខំឲ្យគាត់រៀបការ? ហេតុអីបានជាលោកដឹង?

**ឆ៖** លោកដឹងថា ក្អែកមួយជាក្អែកដប់ទេ? ខ្ញុំមិនដឹកសួរគេ ក៏គេត្រូវការនិយាយដែរ។ បើអ៊ីចឹងខ្ញុំដឹងតាមពាក្យគេនិយាយ អ្នកនៅជាមួយគ្នា គេនិយាយ។

**ឆ៖** លោកដឹងតែក្អែកមួយ ជាក្អែក១០ទេ ខ្ញុំមិនដឹកសួរគេ ក៏គេត្រូវការនិយាយដែរ។ បើអ៊ីចឹងខ្ញុំដឹងតាមពាក្យគេនិយាយ អ្នកនៅជាមួយគ្នា គេនិយាយ។

**ស៖** តើលោកចាំបានអ្នកដែលនិយាយប្រាប់លោកហ្នឹង តើគាត់ឈ្មោះអី? ហើយគាត់មានតួនាទីដឹកនាំដែរទេ ឬមួយក៏ជាកងចល័ត សមាជិកកងចល័តធម្មតាដូចតែលោកដែរ?

**ឆ៖** បើជំនាន់ប៉ុលពត មានសេរីភាពដើរហើរសួរគេអ៊ីចឹង ជាក់ស្ដែងរឿងអានេះងាប់ រឿងអានោះងាប់ រឿងអី ប្រហែលជាដឹងច្រើន។ តែជំនាន់ប៉ុលពត សូមជម្រាបលោកមេធាវីថា បានត្រឹមមួយដឹងទេ រឿងឈ្មោះ រឿងអីអាណា និយាយអី តួនាទីអី ខ្ញុំអត់ដឹងទាំងអស់។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាស២០នាទីចាប់ពីពេលនេះតទៅ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:២០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា ឡើងបន្តសំណួរ។

**លោក លីវ សុវណ្ណា៖**

បាទ សូមអរ--

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំមានសំណើមួយសម្រាប់ពាក់ព័ន្ធទៅនឹងដើមបណ្ដឹរដ្ឋប្បវេណីបន្ទាប់ គឺដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-264 ដែលដើមបណ្ដឹងរដ្ឋប្បវេណីនេះ រូបនេះ ពេលនេះ លោកស្រីបានអញ្ជើញមកដល់តុលាការរួចហើយ ក៏ប៉ុន្ដែបញ្ហា គឺថាពេលដែលខ្ញុំជួបគាត់តាំងម្សិល ហើយរហូតមកដល់ពេលនេះ គឺលោកស្រីមានសុខភាពមិនល្អទេ ហើយពេលនេះកំពុងតែស្ថិតនៅក្នុងអង្គភាពពេទ្យរបស់សាលាក្ដីខ្មែរក្រហម។ ហើយដែលយើងខ្ញុំគិតថា យ៉ាងហោចណាស់ថ្ងៃនេះ លោកស្រីប្រហែលជាមិនអាចផ្ដល់សវនា -- មកឆ្លើយនៅចំពោះមុខសវនាការគេ។ ហើយលោកស្រីពេលនេះកំពុងតែស្ថិតនៅក្រោមការពិនិត្យរបស់ពេទ្យរបស់សាលាក្ដីខ្មែរក្រហម។ អ៊ីចឹងសូមលោកប្រធានពិនិត្យពិចារណាសំណើរបស់ខ្ញុំ។ បាទ សូមអរគុណ។

[១០:៣៣:២៦]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះនឹងពិនិត្យតាមជាក់ស្ដែង។

**លោក លីវ សុវណ្ណា៖**

បាទ អរគុណលោកប្រធាន។ សូមអនុញ្ញាតបន្តសំណួរខ្ញុំមួយចំនួនទៀត។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ជម្រាបសួរសាជាថ្មីលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ឥឡូវយើងបែរមកប្រធានបទយើងដែលលោកទាក់ទងនឹងភេទទី៣ ដូចលោក ដែលលោកអះអាងពីម្សិលមិញថា បានសម្លាប់ខ្លួន ហើយនិងដោយការចងក ជាមួយនឹងការលេបថ្នាំបំពុល ដោយសារគេបង្ខំរៀបការ។ ឥឡូវខ្ញុំចង់ដឹងថា ដេញដោលអំមិញហ្នឹងគឺលោកថា លោកមិនអាចបាននិយាយទេ ហេតុអី សំណួរខ្ញុំថាហេតុអីបានជាលោក

ដឹងជាក់លាក់ថា ដោយសារការបង្ខំរៀបការ បានជាពួកគាត់ហ្នឹងទៅចងក និងលេបថ្នាំសម្លាប់ខ្លួននោះ? ហើយលោកដឹងតាំងពីប្រភេទថ្នាំទៅទៀត ថាយកធ្វើ ធ្វើពីជ័រឈើ អ៊ីចឹងតើព័ត៌មានទាំងអស់នេះ លោកបានដឹងដោយវិធីយ៉ាងណា ថាគេប្រាប់ លោកថាអត់ទាន់បាន អត់ស្គាល់អ្នកប្រាប់ទេ? អ៊ីចឹងលោកអាចបញ្ជាក់មើល ថាតើព័ត៌មានទាំងអស់នេះ លោកដឹងពីប្រភពណាខ្លះ?

[១០:៣៤:៤៣]

**លោកស្រី ស៊ូ សុជាវី៖**

**ឆ៖** ខ្ញុំបានប្រាប់រួចហើយថា រឿងរ៉ាវទាំងអស់នេះ គឺអ្នកធ្វើការនៅជិតៗគ្នាហ្នឹងនិយាយខ្សឹបប្រាប់គ្នា។ ថាម្នាក់ដែលប្រភេទទី៣ គេបង្ខំរៀបការដូចអ៊ំឯងដែរហ្នឹង បានផឹកទឹកសន្លាក់ដៃនោះងាប់ទៅហើយ រលួយ។ ដោយសាររឿងអី? ខ្ញុំសួរមួយម៉ាត់ប៉ុណ្ណឹង គេឆ្លើយថា ការបង្ខំរៀបការនៅយុំ។ ហ្នឹងជារឿងប៉ុណ្ណឹង។ ខ្ញុំគ្រាន់តែបានសួរនាំតែប៉ុណ្ណឹង ក្នុងរឿងការឲ្យពិភាក្សាគ្នាស្អិតល្អួតថាស្លាប់ដោយសារអ៊ីចេះអ៊ីចុះ ឬមួយក៏ទៅដេកផឹកថ្នាំអត់ទេ។

**ស៖** បាទអរគុណ។ ខ្ញុំចង់ដឹងថាអ្នកដែលធ្វើការជាមួយលោក ដែលប្រាប់លោកហ្នឹងគាត់ឈ្មោះអីដែរ ដែលបានគាត់ប្រាប់លោកហ្នឹង?

**ឆ៖** ខ្ញុំបានជម្រាបហើយ ថាឈ្មោះខ្ញុំមិនសូវស្គាល់ទេ។

**ស៖** បាទ អរគុណ។ ឥឡូវខ្ញុំចង់ចូលប្រធានបទថ្មីទាក់ទងនឹងរឿងមិត្តភក្តិរបស់លោក។ តើនៅក្នុងវង់ដែលជាអ្នកចម្រៀងធ្វើការជាមួយលោកមុនឆ្នាំ មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ហ្នឹង មានឈ្មោះសារាយ ហ្នឹងប៉ុន្មាននាក់ដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណី ចាំមីក្រូហ្វូនដំណើរការសិន ចេញភ្លើងក្រហម ចាំលោកឆ្លើយ។

[១០:៣៦:៣៩]

**លោកស្រី ស៊ូ សុជាវី៖**

**ឆ៖** ឈ្មោះ សារាយ ហ្នឹងពីរនាក់។ សារាយ មួយស្លាប់នៅក្នុងបន្ទប់ហ្នឹងហើយ ខ្មែរក្រហមបាញ់ ប៉ុន្តែខ្ញុំថាស្លាប់ទៅចុះ ព្រោះបាញ់រះទៅក្នុងហ្នឹង។ រស់នៅក្នុងហ្នឹងមានតែខ្ញុំមួយ ហើយនិង ស៊ីណាត ទេដែលវាចេញរួចថ្ងៃ១៧ មេសាហ្នឹង។ រដ្ឋា និងឈ្មោះប៉ុន្មាននាក់ទៀតហ្នឹងនៅក្នុងហ្នឹងស្លាប់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01355072



ទាំងអស់ ទាំងបួននាក់ហ្នឹង។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បាទអរគុណ។ ហើយអំមិញខ្ញុំចង់បញ្ជាក់ថែមបន្តិចដែលលោកថា លោកពេលវៀតណាមវ៉ៃចូលហ្នឹង លោក គេបានយកលោកមកផ្ញើនៅក្បែរគុកក្រាំងតាចាន់។ អ៊ីចឹងខ្ញុំចង់ដឹងថាតើពេលហ្នឹងគឺនៅក្នុងឆ្នាំណាដែរ?

**ឆ៖** ខ្ញុំបានប្រាប់ហើយថាខ្ញុំមកនៅ គេផ្ញើតែមួយយប់ ខ្ញុំអត់ដឹងថាគុកក្រាំងតាចាន់ផងទេ គ្រាន់តែស្គាល់ថាកន្លែងហ្នឹងផ្ញើស្អីៗ គ្រាន់តែសួរគេ ខ្ញុំសួរល្ហបនៅហ្នឹង គេថា កន្លែងនេះគុកក្រាំងតាចាន់។ ប៉ុន្តែខ្ញុំអត់ដឹងថាគុកហ្នឹងសម្រាប់ដាក់អ្នកទោសទេ ព្រោះខ្ញុំអត់មានឃើញអ្នកទោសអ្នកអី ប៉ុន្តែគ្រាន់តែអារម្មណ៍របស់ខ្ញុំទេ។ គេព្រលឹមឡើងចេញទៅវិញ បើតាមការខ្ញុំប៉ាន់ស្មាន និងអារម្មណ៍របស់ខ្ញុំដែលខ្ញុំពេលទៅដល់ និងពេលដើរចេញ គឺមិនយូរទេ ព្រោះខ្ញុំដើរមួយយប់ទៅជាមួយល្ហបពីខាងសន្លុងទៅហើយ យកទៅផ្ញើហ្នឹង ក៏មិនមានទុកយូរដែរ ព្រោះវាឆ្ងាយគ្នាដែរ។

**ស៖** បាទ ខ្ញុំចង់ដឹងឆ្នាំ តើនៅពេលវៀតណាមវ៉ៃចូលហ្នឹង នៅក្នុងឆ្នាំណា ដែលលោកថាវៀត-ណាមវ៉ៃចូលហ្នឹង?

[១០:៣៨:៣៥]

**ឆ៖** ៧៨, ៧៩ហ្នឹង ដើមឆ្នាំ -- ចុងឆ្នាំ៧៨ហ្នឹងទៅហើយទេ ដែលវៀតណាមវ៉ៃចូលហ្នឹងដេញក្នុងក្លាំងហ្នឹង គេយកខ្ញុំពីសន្លុងយកមកផ្ញើហ្នឹងៗ។ ហើយខ្ញុំបានជម្រាបហើយថា ខ្ញុំអត់ជាប់គុកនៅក្រាំងតាចាន់ទេ គេយកមកផ្ញើមួយភ្លែតហ្នឹងហើយ ព្រលឹមឡើងទៅខាងខេត្តកណ្ដាលទៀត។

**ស៖** អ៊ីចឹងសូមលោកបញ្ជាក់ឲ្យច្បាស់ តើចុង៧៨ ប្រហែលជាខែណាដែរ តាមការកត់ចំណាំរបស់លោក?

**ឆ៖** ខ្ញុំអត់ចាំខែណា ថ្ងៃណា ដឹងតែចុង៧៨។

**ស៖** អ៊ីចឹងខ្ញុំសូមសួរត្រឡប់ទៅក្រោយតិច ពេលលោករៀបការហ្នឹង តើពេលហ្នឹងលោករួចខ្លួនពីភ្នំ មន្ទីរឃុំឃាំងភ្នំសន្លុងហើយ ឬមួយក៏ពេលដែលលោករៀបការហ្នឹង គឺជាប់នៅគុកសន្លុងហ្នឹងក្រោយពេលរៀបការ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី ចាំមីក្រូហ្វូនដំណើរការសិន ចាំឆ្លើយ។

**លោកស្រី ស៊ូ សុធាវី៖**

**ឆ៖** ខ្ញុំការប្រពន្ធនេះ ខ្ញុំការក្នុងខេត្តកណ្ដាល ៧៧ ខែសីហា។

[១០:៤០:៣០]

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ចុះលោកជាប់នៅគុកសន្ទុងហ្នឹងមុនការ ឬក៏ក្រោយរៀបការ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី ចាំមីក្រូហ្វូនដំណើរការសិន មានភ្លើងក្រហម ចាំលោកឆ្លើយ។

**លោកស្រី ស៊ូ សុធាវី៖**

**ឆ៖** គឺខ្ញុំការនៅខេត្តកណ្ដាល ពេលគេ*(ឮមិនច្បាស់)*ចេញមកពីខាងខេត្តនេះ។ ហើយខ្ញុំសូមជម្រាបថា ខ្ញុំច្រឡំឆ្នាំទេ អម្បាញ់មិញហ្នឹងគឺថាខ្ញុំមកនៅក្នុងខេត្តនេះ គឺខេត្តកណ្ដាលនេះ គឺក្នុងឆ្នាំ៧៧ តែអានោះពីដើមឆ្នាំ៧៦ទេ ដែលគេជម្លៀសខ្ញុំ អាមុនដូរមកពីតាកែវមកហ្នឹង គឺឲ្យមកខេត្តកណ្ដាលតែម្ដង គឺពេលគេយកធ្វើក្រាំងតាចាន់នេះ គឺខ្ញុំនៅមិនទាន់រៀបការទេ។ អ៊ីចឹងដល់ចេញពីក្រាំងតាចាន់មួយភ្លែតហ្នឹងមក ៗខេត្តកណ្ដាលទេ ដល់៧៧បានខ្ញុំការនោះ ខែសីហានេះ ប៉ុន្តែអាហ្នឹង៧៨ ចុងចិតសិប -- ចុង៧៦ទេ សូមទោស។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** អ៊ីចឹងលោកដែលថា អះអាងនៅជាប់នៅ គេយកមកធ្វើនៅជិតមន្ទីរក្រាំងតាចាន់ហ្នឹងនៅចុង៧៦--

**ឆ៖** *(មីក្រូហ្វូមិនទាន់ប្រតិបត្តិការ)*

**ស៖** តែព្រឹត្តិការណ៍ហ្នឹង លោកអះអាងថាវៀតណាមវ៉ៃចូល បានគេយកលោកមកធ្វើទីនោះ។ អ៊ីចឹងតើលោកមានឮសូរគ្រាប់កាំភ្លើងវ៉ៃចូល? ហើយតើវៀតណាមវ៉ៃចូលកម្ពុជាហ្នឹង វ៉ៃចូលដល់ម្ដុំណាដែរ លោកអាចដឹងបានទេ?

[១០:៤២:២៨]

**ឆ៖** ខ្ញុំអត់បានឮស្គរសំឡេងគ្រាប់ សំឡេងអីទេ គ្រាន់តែខ្ញុំអ្នកដែលគេបញ្ជូនខ្ញុំមក គេថាវៀត-ណាមវ៉ៃចូលមកហើយ ឥឡូវត្រូវបញ្ជូនតាឯងទៅខាងខេត្តកណ្ដាល។ គ្រាន់តែប្រាប់ប៉ុណ្ណឹង អត់មានថាបញ្ជូនទៅឯណាទៅឯណី។ តែដល់ពេលយប់ឡើងចូលសម្រាកហ្នឹងមួយយប់ ក៏ខ្ញុំក៏មិនទាន់ដឹងទៀត ខ្ញុំសួរសន្តិសុខថា ហ្នឹងអីៗៗអ៊ីចឹងទៅ គេប្រាប់តាមដំណើរម៉េច ថាក្រាំងតាចាន់ហើយ។ ហើយអ៊ីចឹងខ្ញុំអត់ដឹងទេ ទាល់តែខ្ញុំនៅពេលសង្គមនេះទេ ដែលខ្ញុំបានស្គាល់ អូ!ក្រាំងតាចាន់! អញធ្លាប់ស្គាល់ដែរតើ! អញបានមកដេកនៅមួយយប់ដែរ ប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ ឥឡូវខ្ញុំចង់ចូលទៅប្រធានបទមួយទៀត ដែលលោកបានឆ្លើយម្សិលមិញក៏ដូចព្រឹកមិញថា លោកត្រូវបាត់បងប្អូនចំនួន១៥នាក់ ហើយនិងម្ដាយលោកមួយទៀត ១៦។ អ៊ីចឹងខ្ញុំចង់បញ្ជាក់ថាតើ១៥នាក់នេះ ជាបងប្អូនបង្កើត ឬមួយក៏បងប្អូនជីដូនមួយរបស់លោក?

**ឆ៖** សាច់បងប្អូនបង្កើត ខ្ញុំមិនរាប់ជាមួយ ខ្ញុំរាប់តែម្ដាយខ្ញុំ ឪពុកខ្ញុំ និងបងប្អូនខ្ញុំ ៗអត់មានដែលទៅរាប់អ្នកណាឆ្ងាយទេ ហើយសូមជម្រាបថាបងប្អូនខ្ញុំម្ដាយមួយ ឪពុកមួយ។

**ស៖** អ៊ីចឹងលោកមានបងប្អូនចំនួនប៉ុន្មាននាក់ដែរសរុបទាំងអស់?

**ឆ៖** ទាំងខ្ញុំហ្នឹងគឺប្រាំមួយដណ្ដប់ -- ប្រាំដណ្ដប់ហ្នឹងហ្មង គឺម្ដាយខ្ញុំមួយទៀត ប្រាំមួយដណ្ដប់ ឪពុកខ្ញុំមួយ ប្រាំពីរដណ្ដប់។ គឺបងប្អូនខ្ញុំបង្កើតតែម្ដង សរុបរួម ស្រីតែពីរទេ ក្រៅពីហ្នឹងប្រុសទាំងអស់ ១៥នាក់។

[១០:៤៤:៣៣]

**ស៖** បាទ អរគុណ។ អ៊ីចឹងលោកចាំទេ តើបងប្អូនបង្កើតរបស់លោកទាំង១៤នាក់ផ្សេងដែលបានស្លាប់ហ្នឹង គាត់មានឈ្មោះអីគេខ្លះដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកៗស្រីដើមបណ្ដឹងរដ្ឋប្បវេណី ចាំមេក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហម ចាំលោកឆ្លើយ។

**លោកស្រី ស៊ូ សុធារី៖**

**ឆ៖** ខ្ញុំចាំបានខ្លះ ព្រោះខ្ញុំ ឥឡូវដែល ៗជម្រាបលោកថា ខ្ញុំបាត់ការចងចាំច្រើន លោកថាម៉េចក៏ឆ្លើយបែកអូរហូរនេះ ខ្ញុំឆ្លើយកាត់។ តែបងខ្ញុំបង្អស់នោះ បងយ៉ាត, បងយង់, បងយ៉េង, បងស្រីយ៉ន, បងស្រីយឿន, ហើយមកប្អូនទៀត ចាំប្អូនយ៉ា ហើយប្អូនយ៉ុង ហើយមកម្នាក់ទៀតភ្លេចឈ្មោះទៅ មិន

ដឹងជាស្អីទេ ហើយខ្ញុំហ្នឹងឈ្មោះ វី ហ្នឹង។ ចាំមិនអស់ទេ បងប្អូនច្រើនពេក។

**លោក លីវ សុវណ្ណា៖**

បាទ អរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ អរគុណលោកប្រធាន ខ្ញុំសូមជូនវេទិកាទៅសហភាតារបស់ខ្ញុំ គាត់បន្តថែមបន្តិចទៀត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីលោក នួន ជា!

[១០:៤៦:០៩]

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរពីរបីដែលត្រូវសួរលោកប៉ុណ្ណោះ។ នៅពេលនេះ គឺយើងនឹងនិយាយអំពីអ្វីដែលបានពិភាក្សារួចមកហើយ ប៉ុន្តែខ្ញុំសួរលោកនូវសំណួរដែលមានលក្ខណៈខុសប្លែកបន្តិច ដូច្នេះសូមលោកអត់ធ្មត់ជាមួយខ្ញុំ។ ដូច្នេះសំណួរទី១ របស់ខ្ញុំគឺពាក់ព័ន្ធទៅនឹងប្រពន្ធរបស់លោក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ <ឈ្មោះ ឡេង រដ្ឋា>។ សំណួររបស់ខ្ញុំ គឺទាក់ទងទៅនឹងអ្វីដែលលោកស្រីនិយាយកាលពីម្សិលមិញ ពេលរសៀល នៅម៉ោងប្រហែលជា១៥:០៨។ លោកបាននិយាយថា លោកស្គាល់ប្រពន្ធរបស់លោក <ព្រោះ>លោកស្រីនៅក្នុងកងចល័ត ហើយដោយសារតែពួកលោកទាំងពីរ គឺមានស្ថានភាពដូចគ្នា គឺជាកូនកំព្រា អត់មានឪពុកម្តាយបងប្អូន ហើយលោកមិនសូវបានជជែកជាមួយគាត់នោះឡើយ។ <លោកបានសម្រេចចិត្តនិយាយជាមួយនាង> ទោះបីជា<>លោកមិន<ដឹងថាវាជា>ថ្ងៃរៀបការ<ក៏ដោយ>។ ដូច្នេះសំណួរទី១ របស់ខ្ញុំចង់សួរថា តើលោកស្រីដឹងអំពីប្រវត្តិរបស់ប្រពន្ធរបស់លោកស្រីហ្នឹងដោយរបៀបណា ដែលថាគាត់ជាក្មេងកំព្រានោះ?

**លោកស្រី ស៊ូ សុធាវី៖**

**ឆ៖** ខ្ញុំបានស្គាល់គ្នាមួយរយៈនៅក្នុងកងចល័តជាមួយគ្នាហ្នឹង គឺដោយសារទៅភូមិ។ ពេល១០ថ្ងៃហ្នឹង គេឲ្យទៅលេងភូមិម្តង ក៏បានជួបគ្នាដោយចៃដន្យទេ។ ខ្ញុំបានសួរទៅថា តើមិត្តនារីមានបងប្អូនប៉ុន្មាននាក់? ថាខ្ញុំកូនកំព្រា។ ខ្ញុំដឹង សួរទៅដឹងតែប៉ុណ្ណឹង។ ពេលណាទៅ ខ្ញុំសួរតែរឿងប៉ុណ្ណឹង ក៏ដឹងតែកំព្រាប៉ុណ្ណឹងដែរ។

[១០:៤៨:០០]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ប្រសិនបើខ្ញុំយល់មិនខុស គឺថាលោកស្រីបានជួប<និយាយ>ជាមួយប្រពន្ធមុនថ្ងៃរៀបការ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំបានស្គាល់គ្នាមុនរៀបការហ្នឹងយូរហើយ ប៉ុន្តែដល់ថ្ងៃរៀបការហ្នឹង ចូលទៅនិយាយ ដោយសារការស្គាល់គ្នាហើយ បាន១ម៉ាត់ចូលទៅនិយាយជាមួយ ប្រាប់រឿងវាអាថ៌កំបាំងនេះ ឲ្យជួត ក្បាលក្រមា ហើយខ្ញុំបង់កក្រមាហ្នឹងអីហ្នឹង។

**ស៖** នៅព្រឹកនេះ លោកបានឆ្លើយជាមួយសហការីរបស់ខ្ញុំ ហើយលោកបានពិភាក្សាអំពីការ ដែលលោកមិនពេញចិត្តអំពីការរៀបការ។ <ខ្ញុំគិតថា នេះជាការនិយាយអំពីសំណើសុំរៀបការលើក ទី១។> លោកបានប្រាប់តុលាការថា ម្តាយរបស់លោកចាស់ណាស់ទៅហើយ ហើយលោកត្រូវមើល ម្តាយរបស់លោក ហើយគេប្រាប់ថា អង្គការនឹងមើលថែម្តាយរបស់លោក ហើយគេនឹងឲ្យលោករៀប ការ ហើយលោកស្នើសុំពន្យារ ហើយវាកើតឡើងនៅពេលដំបូង ប៉ុន្តែជាចុងក្រោយ លោកនៅតែរៀប ការដោយការបង្ខំនៅក្នុងខែ៨ ឆ្នាំ៧៧ ប៉ុន្តែនៅក្នុងចន្លោះខែកុម្ភៈ ដល់ ខែ៨ ៧៧ហ្នឹង លោក<រងនូវការ គំរាមកំហែងជាច្រើនដង>។ កាលពីម្សិលមិញលោកជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកបាន និយាយថា នៅក្នុងឆ្នាំ៧៧ លោកបានស្តាប់អំពីប្តីប្រពន្ធដែលត្រូវបានគេយកទៅសម្លាប់ ដោយគេកុហក ថាយកទៅរៀនសូត្រ។ ពេលនោះលោកដឹងថា លោកត្រូវតែស្វែង<នារីម្នាក់ ហើយធ្វើពុតដូចជាប្តី> ប្រពន្ធ<>។ ដូច្នេះខ្ញុំចង់សួរថាតើនៅពេលណាដែលលោកគិតថា លោកត្រូវតែស្វែងរកស្ត្រីម្នាក់ដើម្បី រៀបការធ្វើជាប្រពន្ធរបស់នោះ?

[១០:៤៩:៥៥]

**ឆ៖** ខ្ញុំសូមសំណួរម្តងទៀត ព្រោះពីម្សិលមិញ ខ្ញុំអត់មានចង់បានណាថារកប្រពន្ធទេ ព្រោះខ្ញុំ បានប្រកែកជាមួយគេរួចហើយ ថាម្តាយខ្ញុំឈឺ។ ឥឡូវនេះ សុំសំណួរហ្នឹងម្តងទៀត ឲ្យច្បាស់លាស់។

**ស៖** មិនអីទេលោក។ ខ្ញុំចង់សួរទាក់ទងទៅនឹងអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញ។ លោកនិយាយថា លោកដឹងថា លោកចាំបាច់ត្រូវស្វែងរកស្ត្រីម្នាក់ដើម្បីយកមករៀបការ ហើយធ្វើពុត ថាជាប្តីប្រពន្ធ។ <លោកថា រឿងនេះកើតឡើង>នៅក្នុងឆ្នាំ៧៧ <នៅពេល>លោកបានឮអំពីប្តីប្រពន្ធ មួយគូដែលគេយកទៅសម្លាប់ ដោយប្រើលេសថាយកទៅរៀនសូត្រ គឺលោកនិយាយអំពីឆ្នាំ៧៧។ ដូច្នេះ ខ្ញុំចង់សួរថា តើលោកអាចបញ្ជាក់បានច្បាស់ទេ ថានៅក្នុងឆ្នាំ៧៧ហ្នឹង ក្នុងថ្ងៃណាខែណា ឬក៏ពេលណា ដែលលោកចាប់ផ្តើមយល់ឃើញថា លោកគឺចាំបាច់ត្រូវស្វែងរក<ស្ត្រី>ម្នាក់ <ហើយធ្វើពុតថា>ជាប្តី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រពន្ធនោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមមេធាវីផ្ដល់ម៉ោងផង តើដើមបណ្ដឹងរដ្ឋប្បវេណីគាត់និយាយពាក្យសម្ដីហ្នឹងនៅពេលណាដែរ ដើម្បីយើងពិនិត្យមើលប្រតិចារឹកឱ្យបានដឹងច្បាស់។

[១០:៥១:២១]

**លោកស្រី ដូរីន ជិន៖**

សូមអរគុណលោកស្រីមេធាវី។ យើងមិនទាន់មានប្រតិចារឹកនៅឡើយ ដោយសារមានការពន្យារពេល ប៉ុន្តែឥឡូវនេះ ខ្ញុំសូមបន្តទៅមុខទៀតចុះ ហើយនៅពេលដែលខ្ញុំមានប្រតិចារឹក ខ្ញុំនឹងបន្តទៀត។

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** ឥឡូវនេះខ្ញុំសូមបន្តទៅសំណួរថ្មីមួយផ្សេងទៀតសិន។ កាលពីម្សិលមិញនៅម៉ោង១៥:០៨ នៅពេលដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានសួរលោក ។បានឆ្លើយ ក្រោយពេលដែលលោក<បាន ជួបគ្នា> គេប្រាប់ថា វាជាថ្ងៃរៀបការ។ បន្ទាប់មកទៀតនៅពេលដែលមេធាវីដើមបណ្ដឹងសួរដដែល <នៅម៉ោងប្រហែល១៥:១៤នាទី> គឺលោកបានឆ្លើយថា ក្នុងចំណោម១០៧គូហ្នឹង គឺ<អត់មានអ្នកណាបដិសេធទេ។> អ្នកខ្លះ គឺស្រក់ទឹកភ្នែកដោយស្ងាត់ស្ងៀម ជាពិសេសស្ត្រី។ <មិនមាន>អ្នក<បញ្ចេញសំឡេង>បដិសេធមិនព្រមរៀបការ<ទេ>។ ដូច្នេះខ្ញុំចង់សួរនៅពេលនេះថា តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលថានៅពេលដែលពួកគេឈរតម្រៀបជាជួរហ្នឹង គឺពួកគេមិនអាចជជែកគ្នាបានទេ តើអ៊ីចឹងមែនទេ?

**លោកស្រី ស៊ូ សុធារី៖**

**ឆ៖** ការចូលទៅតម្រៀបជួរហ្នឹង ដូចខ្ញុំនិយាយប្រាប់មេធាវីអំមិញហើយថា ខាងមូលដ្ឋានឈរជាពីរជួរ ខាង១៧មេសាឈរពីរជួរ។ អ៊ីចឹងរកពាក្យអីនិយាយតតាំងជាមួយគ្នាមិនបានទេ គឺឈរមួយជួរ ។ម្នាក់ អ៊ីចឹងអត់មាននិយាយគ្នាកើតទេ គឺស្ងាត់ស្ងៀមទាំងអស់។

[១០:៥២:៥៧]

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** សូមអរគុណ។ កាលពីម្សិលមិញនៅប្រហែលម៉ោង១៥:១០ នៅពេលដែលមេធាវីដើមបណ្ដឹងសួរ លោកបានរៀបរាប់អំពីអ្វីដែលកើតឡើងនៅក្នុងពេលតម្រង់ជួរនោះ។ ខ្ញុំសូមដកស្រង់៖ “បុរសៗឈរមួយជួរ ស្ត្រីឈរមួយជួរ។ ហើយបន្ទាប់មកទៀត គេលេងបិទពួន។” <លោកបានសង្ស័យថា>នេះគឺជាអ្វីដែលអាចកើតឡើង។ ហេតុដូច្នេះហើយ ទើបលោកប្រាប់<ស្ត្រីម្នាក់ {ខ្ញុំសន្និដ្ឋានថានាងជាអនាគត>ប្រពន្ធរបស់លោក} ឲ្យពាក់ក្រមានៅលើក្បាល ហើយលោកពាក់ក្រមានៅក។ <វាមិនទាន់>ងងឹត<ខ្លាំងនោះទេ។ លោកអាចមានអារម្មណ៍ដឹងថាជាគាត់ ហើយនេះគឺជារបៀបដែលលោកកាន់ដៃរបស់គាត់>។ លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំចង់សួរថា ប្រសិនបើលោកមិនអាចនិយាយជាមួយគ្នានៅពេលដែលឈរជាជួរហ្នឹង តើលោកធ្វើយ៉ាងណាអាចប្រាប់ប្រពន្ធលោកអំពីការពាក់ក្រមានៅក នៅក្បាលអីបែបនេះនោះ?

**ឆ៖** ខ្ញុំសូមជម្រាបលោកស្រីមេធាវីថា ខ្ញុំមិនបានថាទេ ពាក្យលេងបិទពួន។ ខ្ញុំថា ការនេះរៀបលេងបិទពួន។ ស្ដាប់ឲ្យច្បាស់ ខ្ញុំមិនមែនថាការហ្នឹង លាក់ ឲ្យគេ -- ឲ្យលេងបិទពួនទេ។ ហើយខ្ញុំប្រាប់ដំណឹងព័ត៌មានពីទទូរក្បាលក្រមា បង់កក្រមាហ្នឹង គឺក្នុងពេលរយៈម៉ោងមុនដែលពេលគេចាប់រៀបស្គាល់ហ្នឹងទៅទៀត មិនមែនពេលដែលគេរៀបការហ្នឹង បានទៅនិយាយគ្នាទេ គឺនិយាយពេលមុន។ ខ្ញុំបានជម្រាបហើយ ខ្ញុំថាម៉ោងហៅចូលដល់ខ្ញុំក៏ជួប។ ជួបក៏ខ្ញុំក៏បានស្ទុះទៅនិយាយ ឆ្លៀតឱកាសទៅនិយាយជាមួយនឹងដៃគូរបស់ខ្ញុំហ្នឹង។ ខ្ញុំអត់មាន ពេលបានតម្រៀបជួរនិយាយគ្នា ឬក៏ការហ្នឹងគេឲ្យលេងបិទពួនទេ។ គេថា ខ្ញុំប្រៀបថាការហ្នឹង ដូចប្រៀបធៀបលេងបិទពួន។

[១០:៥៥:១៥]

**ស៖** ឥឡូវនេះ ខ្ញុំព្យាយាមបញ្ជាក់ឲ្យច្បាស់។ លោកបាននិយាយថា លោកនិយាយជាមួយប្រពន្ធរបស់លោក មុនពេលដែលលោកមកត្រង់ជួរ។ ប៉ុន្តែម្សិលមិញ នៅប្រហែលម៉ោង១៥:០៨គឺថា នៅពេលដែលលោកមកតម្រង់ជួរ ទើបគេប្រាប់លោកថា ជាថ្ងៃរៀបការ។ ដូច្នេះតើលោក<បានត្រូវរ៉ូវគ្នាជាមួយនាងតាំងពីមុនពេលឮថា លោកនឹងត្រូវរៀបការទៀត តើមែនទេ>?

**ឆ៖** ខ្ញុំបាននិយាយ តែនិយាយមុនពេលមកប្រជុំហ្នឹង គឺខ្ញុំជួបប្រពន្ធខ្ញុំ ខ្ញុំនិយាយរឿងហ្នឹងព្រោះខ្ញុំ កម្រិតខ្ញុំ ខ្ញុំដឹងថា ថ្ងៃនេះជាថ្ងៃដែលគេឲ្យមករៀបការហើយ នឹក ខ្ញុំនឹកឃើញ អត់មានអ្នកណាប្រាប់ខ្ញុំទេ។ ខ្ញុំនឹកឃើញថា ថ្ងៃនេះរៀបការ មានកងស្រី កងយុវជនមួយនេះ ព្រោះដំណឹងការរៀបការយុវជននេះ តាំងពីខែកុម្ភៈ ឲ្យដំណឹងមុន។ ខ្ញុំបាននិយាយអ៊ីចឹងពីម្សិលមិញ ត្រង់និយាយម៉េចទៀត អត់

ដឹងទេ។ ហើយខ្ញុំមកជួបគ្នាក្នុងពេលវេលាមុនម៉ោងហ្នឹង ខ្ញុំបាននិយាយរួចហើយ។ ហើយបានចូលកាន់ដៃ តម្រង់ជួរហ្នឹង គឺយើងដឹងរឿងរ៉ាវហ្នឹងទាំងអស់ ព្រោះវាប្លែកណាស់។ អារម្មណ៍របស់ខ្ញុំប្លែក អ៊ីចឹងខ្ញុំនឹកតាមអារម្មណ៍របស់ខ្ញុំទេ គឺអត់មានអ្នកណាប្រាប់យើងមុនទេ។ ខ្ញុំប៉ានិយាយនេះ គឺអារម្មណ៍ខ្ញុំអ្នកនិយាយ។ ដៃគូរបស់ខ្ញុំនេះ ឲ្យជូតក្បាលក្រមា ជូតអី គឺខ្ញុំអារម្មណ៍របស់ខ្ញុំ ចេញពីបេះដូងរបស់ខ្ញុំថា ថ្ងៃនេះប្រាកដជាគេរៀបការឲ្យ ប៉ុន្តែខ្ញុំមិនទាន់និយាយចេញពាក្យទេ គឺអារម្មណ៍របស់ខ្ញុំប្រើមក។ នឹកឃើញថា ថ្ងៃនេះច្បាស់ជារៀបការ។ ហើយសូមស្ដាប់ឲ្យច្បាស់ថា ពេលកាន់ដៃគ្នាហ្នឹង អត់បាននិយាយទេ ដូចខ្ញុំប្រាប់អ៊ីចឹងថា ខ្លាចងាប់ណាស់។

[១០:៥៧:២៤]

**ស៖** មិនអីទេ។ ឥឡូវនេះ យើងបន្តទៅពិធីរៀបការ ហើយនិងអំពីការតម្រង់ជួរ ការរៀបការ។ ខ្ញុំបានឮការពិភាក្សាអំពីការសួរដេញដោល ដែលថាមាន១០៧គូ ដែល<ជាង>៨០<គូ>ជាអ្នក<១៧>មេសា។ ដូច្នេះខ្ញុំចង់សួរថាតើលោកធ្វើយ៉ាងម៉េច ទើបដឹងច្បាស់ថា មាន១០៧គូបែបនេះ?

**ឆ៖** លោកស្រីមេធាវី ខ្ញុំសូមជម្រាបថា មិនមែន១០៧គូទេ ខ្ញុំប្រាប់ថា១១៧គូ។ ខ្ញុំនិយាយច្បាស់ណាស់ អត់មាន១០៧គូ ចេញពីពីពាក្យខ្ញុំទេ។ ខ្ញុំនិយាយ១១៧គូ ៨០គូជាអ្នក១៧មេសា។ ខ្ញុំបាននិយាយអ៊ីចឹង ពីម្សិលមិញ ខ្ញុំនៅចងចាំច្បាស់ណាស់ អត់មាន១០៧ទេ គឺ១១៧។

**ស៖** ដូច្នេះខ្ញុំចង់សួរថា លោកធ្វើម៉េចដឹងអំពីចំនួនច្បាស់លាស់បែបនេះ?

**ឆ៖** រឿងអីដែលមិនដឹងចំនួន ព្រោះគេប្រកាសហើយៗហ្នឹង គេដឹងចំនួនហើយ គេប្រាប់ថាប៉ុននេះ ១៧មេសា៨០គូ ហើយអ្នកមូលដ្ឋាន សល់ពី៨០មក ១៧ដឹងប៉ុន្មាន សរុបរួមមក១១៧គូ។ ហើយខ្ញុំ គូទី៧នេះ គេហៅឡើងមកនិយាយគូទី៧ ខ្ញុំចំណាត់ខ្លួនឯងថា ជាគូទី៧បណ្ដោយទៅ។

**ស៖** ឥឡូវនេះ ខ្ញុំបន្តទៅផ្នែកបន្ទាប់នៃសំណួរ។ ម្សិលមិញនៅម៉ោង១៥:២២ លោកបាននិយាយអំពីអ្វីដែលកើតឡើងភ្លាមៗ ក្រោយពេលពិធីរៀបការ។ ហើយខ្ញុំសូមដកស្រង់អ្វីដែលលោកឆ្លើយ។ លោកនិយាយថា លោកទៅខាងសាច់ថ្លៃរបស់លោក គឺជាផ្ទះ ៗនុំងមិនខ្ពស់ពីដីទេ នៅពេលដែលលោកទៅទីនោះប្រហែលម៉ោងដប់ ដប់មួយយប់ គឺលោកជជែកជាមួយនឹងសាច់ថ្លៃ ហើយនិងប្រពន្ធរបស់លោក <ហើយលោកបានឃើញស្រមោលនៅក្រោមផ្ទះ>។ ហើយនៅពេលព្រឹកឡើង លោកឃើញដានជើងមនុស្សនៅក្រោមផ្ទះហ្នឹង។ <>នៅពេល<មិនទាន់>រៀបការ គឺគេតែងតែទៅលួចទៅស្ដាប់ ថាតើលោកជាភ្នាក់ងារ សេ.អ៊ី.អា ឬក៏ កា.ហ្សេ.បេ។ <ទោះជាយ៉ាងណា នៅពេលនេះគឺគេចង់ដឹង>ថាតើ

លោករួមដំណេក ឬក៏អត់។ ដូច្នេះខ្ញុំចង់សួរថា តើលោកធ្វើយ៉ាងម៉េចបានដឹងថា គេតាមដាន? ថាតើលោកបានរួមដំណេក ឬក៏អត់ ហើយមិនមែនជាការតាមដានរឿងបញ្ហាផ្សេងៗ? <ឧទាហរណ៍ដូចជាបញ្ហាសន្តិសុខទូទៅ ឬក៏>ថាតើលោកជាភ្នាក់ងារ ឬក៏ជាគិញរបស់ សេ.អ៊ី.អា, កា.ហ្សេ.បេ នោះទៅវិញ?

[១១:០០:៤៣]

**ឆ៖** ក្រោយពីរៀបអាពាហ៍ពិពាហ៍ហ្នឹង យប់ជ្រៅហើយម៉ោងដប់ មួយដណ្តប់ ខ្ញុំបានក៏អង្គុយនិយាយថ្លៃខ្ញុំ អង្គុយនិយាយលេងគ្នា លេងអ៊ីចឹងទៅ។ ផ្ទះនៅជនបទជំនាន់ខ្មែរក្រហម ខ្ញុំប្រាប់អ៊ីចឹងថា ឫស្សីរនាប ជះរបាំងមើលពីលើផ្ទះមកឃើញ ព្រោះផ្ទះអត់ខ្ពស់ទេ ១ម៉ែត្រជាងទេ។ បើអ៊ីចឹងឃើញស្រមោល ឃើញទាំងអស់ គឺមិនមែនឃើញដានជើងទេ លូនតែម្តង ដូចពស់ថ្លាន់លូនអ៊ីចឹង។

**ស៖** អ៊ីចឹងលោកឃើញ?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំ<គិត>ថា មេធាវីមិនមានប្រតិចារឹក<ទេ> ប៉ុន្តែ<គេបានធ្វើប្រតិចារឹកហ្នឹងចេញរួចហើយកាលពី>ព្រឹកនេះ ខ្ញុំចង់កែសម្រួលបន្តិចអំពីអ្វីដែលគាត់បានកត់ត្រា។ យោងតាមប្រតិចារឹកសេចក្តីសេចក្តីព្រាងប្រតិចារឹក<ដែលខ្ញុំមាន គឺមិនបាននិយាយ>ថាគាត់ឃើញដាន<ទេ។> គឺគាត់និយាយថា៖ "ប៉ុន្តែនៅពេលព្រឹក យើងឃើញ<ហ្វូង>មនុស្សលូននៅក្រោមផ្ទះ ហើយយើងដឹងច្បាស់ថាពួកគេមកតាមដានយើង។" នេះគឺជាអ្វីដែលប្រតិចារឹក សេចក្តីព្រាងប្រតិចារឹកជាភាសាអង់គ្លេសបានរៀបរាប់ គឺនៅម៉ោង១៥:២៣។

[១១:០២:០៥]

**លោកស្រី ដូរីន ជិន៖**

សូមអរគុណលោកព្រះរាជអាជ្ញា។

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** ដូច្នេះលោកនិយាយថាមានមនុស្សនៅក្រោមផ្ទះ។ តើលោកធ្វើយ៉ាងណាបានដឹងថា គេមកហ្នឹង មកដើម្បីតាមដានពីអ្វី?

**លោកស្រី ស៊ូ សុធារី៖**

**ឆ៖** រាល់ដង ពីរបីថ្ងៃគេមកតាមដាន ព្រោះយើងអត់ដែលសូវនៅផ្ទះទេ ទៅនៅតែកងចល័ត។

តែក្រោយពីថ្ងៃរៀបការហ្នឹង លូនទៅហ្នឹង វាមានស្លាកស្នាមមករួចហើយ បានខ្ញុំនឹកឃើញថាអ៊ីចឹង ខ្ញុំនិយាយថាអ៊ីចឹង។ វាស្លាកស្នាម គេទៅស៊ើបការណ៍នៅក្រោមផ្ទះ គេលូននៅក្រោមផ្ទះ។ អ៊ីចឹងហើយខ្ញុំនិយាយតាមពាក្យសម្តីដែលខ្ញុំដឹង ចងចាំថា ថ្ងៃនេះប្រហែលជាគេដឹងថាអញការប្រពន្ធហើយ បែបគេមកស៊ើបសួររឿងហ្នឹងហើយ។ ខ្ញុំបានពិភាក្សាជាមួយដៃគូខ្ញុំ នឹងប្រពន្ធខ្ញុំ តែខ្ញុំមិនចុះជារឿងរ៉ាវអីវែងឆ្ងាយច្រើនទេ គ្រាន់តែនិយាយប្រាប់តែប៉ុណ្ណឹងថា គេតាមដានយើងហើយ។

[១១:០៣:១៣]

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសម្រង់ដែលខ្ញុំដកស្រង់ពីលោក គឺផ្នែកចុងក្រោយ។ ព្រះរាជអាជ្ញាបើសិនបើខ្ញុំនិយាយខុស លោកអាចកែតម្រូវ។ អ្វីដែលយើងស្តាប់ឮ គឺថា លោកនិយាយថា "នៅពេលដែលមិនទាន់<>រៀបការ<>គឺគេលូនចូលមកតាមដាន ដើម្បីថាជាភ្នាក់ងារ សេ.អ៊ី.អា ឬកា.ហ្សេ.បេ ប៉ុន្តែនៅពេលដែលរៀបការហើយ គឺគេលូនមក ដើម្បីតាមដានថាយើងរួមដំណេក ឬក៏អត់។" ដូច្នេះអ្វីដែលខ្ញុំចង់បញ្ជាក់ គឺថាលោកបានបញ្ជាក់ថាចេតនារបស់ឈ្លប ដែលចូលមកហ្នឹង គឺមកដើម្បីតាមដានថាតើលោករួមដំណេក ឬក៏អត់ មិនមែនមកតាមដានថាតើលោកជាភ្នាក់ងារ សេ.អ៊ី.អា ឬកា.ហ្សេ.បេ។ ខ្ញុំចង់ដឹងថាលោកធ្វើយ៉ាងម៉េចបានដឹងភាពខុសប្លែកគ្នាហ្នឹង?

**ឆ៖** ពីមុនដំបូង អ្នកដែលគ្រប់គ្នានៅ អត់ទាន់មានដៃគូ អត់ទាន់រៀបថ្ងៃ រៀបការកើតថ្មីអ៊ីចឹងទេ គេពីរបីថ្ងៃ គេមកតាមដាន។ អ៊ីចឹងបានសេចក្តីថា ទាហាន ឬគ្រូបង្រៀន និស្សិត និងបញ្ញវន្ត ឬអ្នកភ្នាក់ងារ កា.ហ្សេ.បេ គេអី គេតាមដានរឿងហ្នឹងហើយ គេមករាល់ដងហ្នឹង។ តែថ្ងៃខ្ញុំរៀបការនេះហើយ ដែលមកសន្តិសុខ មកលូនក្រោមផ្ទះខ្ញុំ បានន័យថាថ្ងៃនេះ គេមិនមកតាមដានយើងហើយ យើងមិនព្រមដេកជាមួយគ្នា ឬដេកជាមួយគ្នា គេដឹងថ្ងៃហ្នឹងហើយ។ ខ្ញុំនិយាយអ៊ីចឹង ទាល់គេតាមដានយើងរហូត។

**ស៖** ខ្ញុំសាកល្បងអ៊ីចេះវិញ តើលោកធ្លាប់ឮមានការបញ្ជាឲ្យឈ្លបតាមដានប្តីប្រពន្ធដែលទើបការហ្នឹង ថារួមដំណេកឬក៏អត់នោះទេ? តើលោកធ្លាប់ឮគេបញ្ជាមកឈ្លបបែបនេះទេ?

**ឆ៖** រឿងនេះមិនបាច់អ្នកណាបញ្ជាអ្នកណាទេ គឺក្រុមឈ្លប គេតាមដានអ៊ីចឹងតែរហូត។

**ស៖** អ៊ីចឹងបានន័យថា លោកគិតតែខ្លួនឯងទេ?

[១១:០៥:៤៤]

**ឆ៖** ខ្ញុំគិតខ្លួនឯង ក៏ប៉ុន្តែវាសកម្មភាពហ្នឹងវាធ្វើដូចយើងគិតអ៊ិចឹង។ បើសិនណាយើងមិនទាន់

មានដៃគូប្ដីប្រពន្ធ វាតាមដានដោយសាររឿងថាយើងហ្នឹង កា.ហ្សេ.បេ ឬមួយក៏ជាចោរលួចអីគេ ឬក៏ជាទាហាន ឬមួយក៏និស្សិត ឬមួយបញ្ញវន្ត ហ្នឹងខ្ញុំគិតខ្លួនឯង។ ណាប៉ុន្តែសកម្មភាពហ្នឹងឃើញជាទូទៅ។ ដល់ពេលខ្ញុំមានប្រពន្ធហើយ គេមកតាមដានខ្ញុំពីរឿងការដេកនៅជាមួយគ្នាអត់។ ហ្នឹងគំនិតរបស់ខ្ញុំគិតអ៊ីចឹង ប៉ុន្តែសកម្មភាពអស់ទាំងហ្នឹង ខ្ញុំធ្លាប់ឃើញ។

**ស៖** ខ្ញុំនៅសល់សំណួរពីរបីបន្តទៀត។ ឥឡូវនេះខ្ញុំនិយាយពីប្រពន្ធរបស់លោក។ កាលពីម្សិលមិញនៅប្រហែលជាម៉ោង១៥:២៧ យើងស្ដាប់ឮលោកឆ្លើយថា នៅក្នុងជីវិតរបស់លោក គឺថានៅពេលដែលលោកគេងជាមួយប្រពន្ធរបស់លោកហ្នឹង គឺជាពេលតែម្ដងគត់ដែលរួមភេទជាមួយប្រពន្ធរបស់លោក។ ហើយបន្ទាប់មកទៀត គឺលោក<ត្រូវបានគេបំ>បែកពីគ្នា។ ហើយក្រោយមកទៀត លោកនិយាយថាគេបញ្ជូនលោកទៅនៅ<ទូក> ភ្នំ<ទំពែក ដើម្បីបំបែកថ្ម ហើយអាចជួបគ្នារៀងរាល់>១០ថ្ងៃ។ ដូច្នេះខ្ញុំចង់សួរឲ្យលោកបញ្ជាក់បន្តិច តើលោកមានន័យថា នេះគឺជាលើកទី១ហើយដែលលោករួមភេទជាមួយមនុស្សស្រី អ៊ីចឹងមែនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ស៊ូ សុធាវី៖**

**ឆ៖** ខ្ញុំពិបាកនឹងឆ្លើយថាខ្ញុំអត់ស្រឡាញ់ទេស្រី កុំតែជំនាន់អាពត បើជំនាន់ដូចឥឡូវមានសិទ្ធិសេរីភាពបរិបូណ៌ ខ្ញុំអត់យកទេ។ អ៊ីចឹងខ្ញុំមិនមែននៅម្នាក់ឯង មានការឈឺចាប់ ឈឺយប់ព្រលប់អី ដែលខ្ញុំអត់យកស្រី ម៉េចក៏ខ្ញុំមិនរក។ រឿងបញ្ហាហ្នឹងហើយថា ខ្ញុំអត់មានអារម្មណ៍រួមភេទទេ ដោយសារខ្លាចងាប់ទេ បានប្រថុយប្រថានម្ដងទៅ ដោយសារជាតិស្រាផង។

[១១:០៨:០០]

**ស៖** ច្បាស់ហើយអ៊ីចឹង។ ឥឡូវនេះខ្ញុំបន្តបន្តិចទៀត។ លោកនិយាយថា លោកបានជួបគ្នាប្រហែលជា១០ថ្ងៃម្ដង។ ខ្ញុំចង់ដឹងថា តើការជួបគ្នាក្រោយមក១០ថ្ងៃម្ដងហ្នឹង តើវាបន្តប្រហែលជាប៉ុន្មានខែ ប៉ុន្មានឆ្នាំតទៅមុខទៀត?

**ឆ៖** មិនកំណត់ទេ។ អត់ដឹងជាថ្ងៃណាអីគេត្រូវឲ្យទៅផ្ទះឬអីទេ សម្រាក១០ថ្ងៃហ្នឹង។ ប៉ុន្តែខ្ញុំបានត្រឹមតែមកជួបប្រពន្ធ ១០ថ្ងៃម្ដង មិនមែនជា១០នេះមក ១០ថ្ងៃក្រោយមកទៀត ១០ថ្ងៃក្រោយមក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៀត អត់ទេ។ ជួនកាលរយៈកាល១០ថ្ងៃ អ៊ីចឹងមកអើតផ្ទះអ៊ីចឹងមក បានជួបគ្នា និយាយលេងតែមួយភ្លែតហ្នឹង ក៏ត្រឡប់ទៅកន្លែងធ្វើការវិញទៅ។ អ្ហ៎! ដល់១០ថ្ងៃក្រោយមកទៀតហ្នឹង ជួនកាលមកផ្អួនគ្នា២០ថ្ងៃហ្នឹង ជួនកាលអត់ក៏មានដែរ។ ខ្ញុំគេបញ្ជូនទៅកងចល័តនៅភ្នំទំពែករ៉ែថ្ម ចំណែកខាងប្រពន្ធខ្ញុំគេបញ្ជូនទៅផ្នែកខាងនារី កងចល័តនារី មិនដឹងទៅធ្វើអី ធ្វើអី។

**ស៖** តើលោកនៅជួបគ្នារហូតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬមួយក៏មានពេលណាដែលលោកដាច់ទំនាក់ទំនងលែងបានជួបគ្នា?

**ឆ៖** ដាច់ទំនាក់ទំនង ទាល់ពេលប្រពន្ធខ្ញុំជិតឆ្លងទន្លេ ហ្នឹងដាច់ទំនាក់ទំនងគ្នារហូតដល់ថ្ងៃឆ្លងទន្លេ។ ខ្ញុំមិនដែលមកផ្ទះ ព្រោះខ្ញុំអត់មានអី មានកម្លាំងទៀតទេ រ៉ែថ្មមិនបានសម្រេចឲ្យគេ គេមិនឲ្យបាយស៊ី នៅដេក នៅស៊ីបាយ*(ឮមិនច្បាស់)*ហ្នឹង មិនបានជាទាំតួ ថាមកឲ្យជួបប្រពន្ធរហូតដល់កូនកើតទេ។

[១១:១០:០៤]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ។ ខ្ញុំមិនដឹងថាខ្ញុំស្ដាប់ច្បាស់ ឬក៏អត់ទេ ខ្ញុំឮថាលោកនិយាយថាប្រហែលជា១០ថ្ងៃ ប៉ុន្តែមិនមែនប្រាកដថា១០ថ្ងៃទេ អាចតិចជាង ឬក៏ច្រើនជាង។ ប៉ុន្តែខ្ញុំចង់សួរថាលោកមកជួបប្រហែល១០ថ្ងៃម្ដងហ្នឹង លោកនៅប៉ុន្មានយប់ដែរ មួយយប់ ឬក៏ពីរយប់ ឬក៏ប៉ុន្មានយប់ដែរ?

**ឆ៖** ប៉ានៅតែពីរយប់ ឥឡូវគេយកទៅរ៉ៃចោល។ ឥឡូវគេកំណត់ឲ្យតែមួយថ្ងៃមកហ្នឹងឡើងតែមួយយប់ហ្នឹង ប៉ុន្តែខ្ញុំអត់ដេកនៅទេ ខ្ញុំបានជម្រាបពីម្សិលមិញ ខ្ញុំថាមកលេងគ្រប់១០ថ្ងៃហ្នឹង មកលេងហ្នឹង មកម៉ោងបី ម៉ោងបួនល្ងាច ព្រោះឆ្ងាយណាស់ផ្លូវដើរ អ៊ីចឹងខ្ញុំហត់ណាស់ ខ្ញុំត្រឡប់ទៅវិញទៅ វាត្រជាក់ពេលយប់ អ៊ីចឹងខ្ញុំទៅដល់កន្លែងធ្វើការវិញ។ ខ្ញុំអត់ដែលបាននៅដេកដល់ប្រាំ ប្រាំមួយយប់ ឬពីរ បីយប់ដូចពាក្យមេធាវីសួរ បើប៉ានដេកតែពីរយប់ គេរ៉ៃចោលបាត់ហើយ។

**លោកស្រី ដូរីន ជិន៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំមិនមានសំណួរបន្តទៀតទេ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកស្រីមេធាវី។ សូមអញ្ជើញលោកមេធាវី ខៀវ សំផន មានសំណួរលើដើមបណ្ដឹងរដ្ឋប្បវេណីនេះ។

[១១:១១:២០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ ភាគី សូមជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរបន្ថែម។ ជាដំបូងខ្ញុំចង់ដឹងពីទីកន្លែងដែលលោកបានស្នាក់នៅជាក់លាក់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ លោកមិនបាច់រាប់កន្លែងដែលលោកគ្រាន់តែធ្វើដំណើរឆ្លងកាត់ទេ លោកអាចបញ្ជាក់ពីទីតាំង អាចភូមិ ឃុំ ឬក៏សហករណ៍ដែលលោកស្នាក់នៅជាក់លាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានទេ ថានៅកន្លែងណាខ្លះ?

**លោកស្រី ស៊ូ សុធារី៖**

**ឆ៖** សូមសំណួរម្ដងទៀត តើខ្ញុំរៀបរាប់ តើអាកន្លែងនៅអត់បានធ្វើ រៀបរាប់តាមពាក្យបណ្ដឹង ឬមួយគ្រាន់តែសួរអាខ្ញុំដាក់ពាក្យបណ្ដឹង? ព្រោះកន្លែងវាផ្លាស់ច្រើនណាស់ សូមលោកមេធាវីសួរម្ដងទៀត។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់ដឹងពីទីកន្លែងដែលលោកនៅ អាចថាជាកន្លែងដែលលោកធ្វើការ ឬក៏កន្លែងដែលលោកស្នាក់នៅជាលក្ខណៈអចិន្ត្រៃយ៍ ឬក៏លក្ខណៈបណ្ដោះអាសន្នរយៈពេលវែងណាមួយ ដោយមិនគិតពីទីកន្លែងដែលគ្រាន់តែធ្វើដំណើរឆ្លងកាត់ទេ ឧទាហរណ៍ថាការឆ្លងកាត់មួយយប់ ឧទាហរណ៍ថាលោកបានឆ្លើយព្រឹកមិញនេះ ឆ្លងកាត់នៅក្រាំងតាចាន់ លោកស្នាក់នៅថាមន្ទីរឃុំឃាំងក្រាំងតាចាន់មួយយប់ អ៊ីចឹងមិនបាច់រៀបរាប់ទេ។ អ៊ីចឹងកន្លែងដែលលោកធ្វើការ លោកនៅកន្លែងណាខ្លះ លោកចាំបានទេ?

[១១:១៣:០៨]

**ឆ៖** បាទ វគ្គទី១ ខ្ញុំរៀបឲ្យអស់ លោកស្ដាប់បាន ចេញពីទីក្រុងភ្នំពេញ ខ្ញុំនៅវត្តចំប៉ាច្រើនយប់ណាស់វត្តចំប៉ា មិនដឹងជាប៉ុន្មានយប់ទេ។ កន្លែងហ្នឹងជាស្នាក់នៅយូរដែរ ដល់ថ្ងៃ៣០ បានខ្ញុំដឹងថាថ្ងៃ៣០ ហ្នឹងដោយសារគេប្រកាសថា ខែ៥ ព្រោះយើង១៧មេសា ចេញទៅដល់នៅ៣០ ហ្នឹងចាំច្បាស់ប៉ុណ្ណឹងថាយើងនៅហ្នឹង ទី១។ ទី២ បញ្ជូនខ្ញុំទៅនេះ ម៉ែៗអត់ៗនិយាយរកទេ ខ្ញុំនិយាយរឿងនៅដេកយូរយប់ជាងគេ ហើយនៅជាអចិន្ត្រៃយ៍តែម្ដង មកឃុំត្រឡាច ស្រុកខ្ញុំហ្នឹងតែម្ដង ភូមិកន្ទួតធំ ឃុំត្រឡាច បាន១០

យប់។ ក្រៅពីហ្នឹងទៅ គេផ្លាស់ឲ្យខ្ញុំទៅនៅពោធិ៍ពាចរហូត ដល់ខ្ញុំទៅនៅកងចល័ត។ ហើយផ្លាស់ពីកងចល័តហ្នឹងទៀត គេឲ្យនៅឃុំស្នំក្រពើ ស្រុកគងពិសីរាល់ថ្ងៃនេះ ប៉ុន្តែខ្ញុំមិនដាក់ពាក្យបណ្ដឹងទេ អូសបន្លាយវែងច្រើនពេក ខ្ញុំដាក់តែឃុំចេក ឃុំដូង -- ភូមិចេក ឃុំដូង ស្រុកបាទីហ្នឹងទេ។ បីកន្លែងដែលខ្ញុំដាក់។ នៅបានបន្តិចៗទេ តាមការពិតខ្ញុំរស់នៅក្នុងគុករហូត។

**ស៖** បាទ ក្នុងកន្លែងទាំងអស់ ដែលលោកបានធ្វើការ ឬក៏ប្រាស្រ័យទាក់ទងជាមួយអ្នកខាងក្រៅច្រើន ទីកន្លែងណាសំខាន់ជាងគេ អាចលោកអាចរើសបានពីរបី ដែលលោកគិតថា លោកមានពេលវេលាធ្វើការខាងក្រៅច្រើន?

[១១:១៥:១៤]

**ឆ៖** បាទ ទី១ មានតែការទាក់ទងខាងក្រៅបានច្រើនស្គាល់គ្នាច្រើនហ្នឹង ធ្វើការនៅវាលពោធិ៍ពាច កន្លែង១៧មេសានៅជិត១០០០គ្រួសារ បីបួនប្រាំទួលហ្នឹង គេហៅវាលពោធិ៍ពាចហ្នឹង បានប្រាស្រ័យទាក់ទងគ្នាច្រើន ដើររកក្ដាម ដើររកអីស៊ីទៅ បានជួបគ្នាទៅ និយាយស្ដីអីទៅ។ ទី២ បានមកនៅឃុំស្នំក្រពើហ្នឹង ក្នុងរយៈកាលតិចតួចណាស់។ ហើយបានជួបគុករហូត ដល់រួចពីគុកហ្នឹងមកបានមកនៅភូមិចេកហ្នឹង ឃុំដូងហ្នឹង ស្រុកបាទីហ្នឹង ហើយនិងភ្នំទំពែកហ្នឹងឯង បានស្គាល់គ្នាតិចតួចច្រើន។

**ស៖** បាទ សូមអរគុណ។ នៅក្នុងឃុំ ឬក៏វាលពោធិ៍ពាច ស្នំក្រពើ ឬឃុំចេក លោកមានស្គាល់មនុស្សប្រភេទទី៣ ច្រើននាក់ទេ? ខ្ញុំស្ដាប់ខាងដើម មានកន្លែងខ្លះលោកបានឃើញមានមនុស្សប្រភេទនោះដែរ។

**ឆ៖** ប្រភេទទី៣ បើនិយាយរួមមកគឺថាច្រើន មិនមែនតិចទេ ប្រភេទដូច ខ្ញុំប្រុសស្រឡាញ់ប្រុសស្រីស្រឡាញ់ស្រីនេះ គ្នាច្រើន។ ក៏ប៉ុន្តែខ្ញុំឲ្យចាំច្បាស់ថា អ្នកនេះជាអ្នកនោះ ក្រៅពីពួកម៉ាកជិតដិតដែលនៅជំនាន់ លន់ នល់ ទៅជំនាន់ខ្មែរក្រហមពីរនាក់ហ្នឹង ឬបីនាក់ហ្នឹង ដែលស្គាល់គ្នាតាមផ្លូវហ្នឹង គឺអត់សូវបានទៅទាក់ទងណាទេ។

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់ថាច្រើនហ្នឹង អាចបញ្ជាក់ពីចំនួន ក្នុងចំនួនណាមួយបានទេ?

**ឆ៖** ចំនួនដែលប្រាកដតែម្ដង វាមិនពិតប្រាកដទេ ព្រោះជួបមិនមែនមួយភ្លែតហ្នឹងប្រាំនាក់ ឬ១០នាក់ឯណា។ ខ្ញុំជួបអីនេះមួយ អីនោះមួយទៅ ប៉ុន្តែឃើញទៅថា ថាពេលនេះ ចរិតប្រភេទទី៣ ឆាប់ស្គាល់គ្នាណាស់ ស្រីស្រឡាញ់ស្រី ហើយប្រុសស្រឡាញ់ប្រុសហ្នឹង ឆាប់ស្គាល់គ្នា។ ទៅ ឆាប់យល់ទឹក

ចិត្តគ្នា ក៏សួរអ្នកគ្នាបន្តិចហើយ ហើយមួយភ្លែតអ៊ីចឹងបែកទៀតហើយ។ បើអ៊ីចឹងអត់ពិតប្រាកដថា ជាប៉ុន្មានៗទេ ប៉ុន្តែឲ្យតែចាប់ពីខ្ញុំជួបពីរនាក់ឡើងទៅរហូត ម្តងមួយ ម្តងមួយ ខ្ញុំយល់ខ្ញុំចិត្តខ្ញុំថាច្រើន។

[១១:១៧:៥៩]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរលោកទាក់ទងនឹងសំណួរមួយ គឺទាក់ទងនឹងបុរសម្នាក់ឈ្មោះ ស៊ន ដែលលោកបានមានស្នេហាជាមួយ ក្រោយពីរៀបការហើយ។ ខ្ញុំចង់ដឹងថា ស៊ន ហ្នឹងក្រៅពីតួនាទីជាមេកង លោកដឹងថា គាត់មានការទទួលខុសត្រូវគ្រប់គ្រង ឬក៏ធ្វើអ្វីខ្លះដែរទេ?

**ធ៖** សូមជម្រាបថា មិនមែន ស៊ន ទេ ឈ្មោះ សន ជាមេកងនៅសន្ទុង គុកសន្ទុងហ្នឹង តែតួនាទីគេដើរត្រួតអីផ្សេងទៀត អត់ដឹងទេ ប៉ុន្តែគេឧស្សាហ៍មកកន្លែងវ៉ៃថ្មខ្ញុំ ហើយជាដៃគូទៀត។

**ស៖** បាទ សូមអរគុណ។ មានទំនាក់ទំនងអ្វីដែលលោកដឹងពីការទទួលខុសត្រូវរបស់ឈ្មោះ សន ហ្នឹងដែលលោកនិយាយអំមិញហ្នឹង ដែលធ្វើឲ្យលោកមានឱកាសអាចជួបគ្នាបាន?

**ធ៖** រឿងបញ្ហា ខ្ញុំអត់បានស៊ើបការណ៍ជាប្រធានកងផ្នែកទទួលខុសត្រូវខាងអីទេ ប៉ុន្តែមកកន្លែងវ៉ៃថ្មហ្នឹង កូនចៅគេមក គេឲ្យទៅធ្វើនេះធ្វើនោះ គេបញ្ជាប្រាប់បាន ឃើញទៅ ខ្ញុំថា អ្ហ៎! បែបប្រធានកងធំហើយ។ ខ្ញុំគ្រាន់តែដាក់ថាមេកងប៉ុណ្ណឹង ខ្ញុំអត់ដឹងថាតួនាទីអីខ្លះនៅក្នុងហ្នឹង។ ប៉ុន្តែតាមការដែលខ្ញុំមើលឃើញ កូនចៅគេខ្លាចទាំងអស់។ បើអ៊ីចឹងបានសេចក្តីថា ជាមេគេហើយ។

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់ផងដែរពីតួនាទីរបស់ប្រពន្ធ អតីតប្រពន្ធរបស់លោកឈ្មោះ រដ្ឋា ហ្នឹងថាជាមេកងដែរ។ ហើយលោកបានឆ្លើយបញ្ជាក់ថា លោកមិនបានដឹងពីតួនាទីរបស់គាត់ទេ។ ចុះលោកដឹងតួនាទីឈ្លបនៅក្នុងសហករណ៍ ឬក៏ក្នុងក្រុម ជាសហជីព ជាភូមិ ជាឃុំរបស់លោកដែលលោកបានរស់នៅទេ?

[១១:២១:០៤]

**ធ៖** រឿងប្រពន្ធរបស់ខ្ញុំជាប្រធានកង១៧មេសា ខ្ញុំអត់បានទៅនៅជាមួយគេផ្ទាល់ថា ជាប្រធានកង គេធ្វើខាងអីៗ គ្រាន់តែដឹងថា មេប្រធានកង។ ចំណែកនៅភូមិឃុំទាំងអស់ ដឹងអ្នកនេះ តានេះ តានោះអ៊ីចឹង ដឹងថាអ្នកនេះប្រធានសហករណ៍ អ្នកនេះប្រធានសហករណ៍។ ដល់ពេល សន ហ្នឹងក៏ខ្ញុំដឹងដោយតាមរយៈដែលមកធ្វើការជាមួយខ្ញុំជិតដិតហ្នឹង ដែលគេមកមើលខ្ញុំវ៉ៃថ្មហ្នឹង ឬអី។ ខ្ញុំដឹងថា នេះគេជាប្រធានកង។ គេអត់មានប្រាប់ គេថាគេហ្នឹងជាប្រធានកងដែរ។ ខ្ញុំទេ ដែលខ្លួនឯងថា គេជាមេកងព្រោះមានការងាររបស់គេធ្វើមានលំដាប់ថ្នាក់កំពូល។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** បាទ សំណួររបស់ខ្ញុំអំមិញគឺទាក់ទងនឹងឈ្លប ហើយខ្ញុំចង់ដឹងថែមទៀតថា តើលោកដឹងថា ឈ្លបហ្នឹងអ្នកណាអ្នកគ្រប់គ្រងទេ?

**ឆ៖** ឈ្លបហ្នឹងមិនដឹងជាអ្នកណាគ្រប់គ្រង ប៉ុន្តែគេហៅតែវាឈ្លបភូមិអ៊ីចឹង ឈ្លបឃុំអ៊ីចឹងទៅខ្ញុំអត់នរណា ដឹងថាឃុំគឺឃុំគេគ្រប់គ្រងហើយ ភូមិគឺភូមិគ្រប់គ្រងហើយ។ ខ្ញុំដឹងតែឈ្លបប៉ុណ្ណឹងទេ។ បើថា គេធ្វើអីទៀត យើងអត់ដឹង។ តែឈ្លបឃុំ ខ្ញុំប្រាប់ថាឈ្លបឃុំ ឈ្លបស្រុក ខ្ញុំប្រាប់ឈ្លបស្រុក ឈ្លបភូមិ ប្រាប់ឈ្លបភូមិ។ ដល់ប្រធានកងដូច សន ហ្នឹងអ៊ីចឹងខ្ញុំប្រាប់ថា ប្រធានកង ប៉ុន្តែមិនដឹងគេខាងអីខាងត្រួតអី អត់ដឹង។

**ស៖** បាទសូមអរគុណ។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតដកស្រង់ឯកសារ E3/5729 ត្រង់លេខ ERN ជាភាសាខ្មែរ 00279735, ភាសាអង់គ្លេស 00279718 ដល់19, ភាសាបារាំង 00845996។ នៅក្នុងចំណុចនេះ ខ្ញុំសូមឲ្យលោកបញ្ជាក់ពីភាពខុសគ្នាមួយដែលលោកបានផ្តល់។ ខ្ញុំសូមដកស្រង់៖ "ពួកគេឲ្យក្មេងទៅយកការណ៍នៅក្រោមផ្ទះយើងដេករាល់យប់" សូមចប់ការដកស្រង់។ សុំឲ្យលោកបញ្ជាក់នូវចម្លើយរបស់លោកដែលលោកបានឆ្លើយក្នុងពេលព្រឹកនេះថា លោកបានឃើញឈ្លបចូលមកតាមលបស្តាប់ ឬក៏លូនក្រោមផ្ទះរបស់លោក។ លោកអាចបញ្ជាក់បានទេថា តើជាក្មេងៗ ឬក៏ជាឈ្លបដែលចូលមកលបស្តាប់លោកហ្នឹង? មួយណាពិតប្រាកដ?

[១១:២៤:៤៧]

**ឆ៖** លោកមេធាវី រូបរាងអ្នកអស់ទាំងហ្នឹង ក្នុងនាមដែលខ្ញុំមើលទៅហ្នឹង សុទ្ធតែមនុស្សពេញវ័យ។ ប៉ុន្តែគ្រាន់ខ្ញុំហៅក្មេងៗនោះ គឺជាវាក្មេងមែនទែន មិនមែនក្មេងតូចនៅបៅដោះទេ អានេះគឺៗក្មេងធំ ប៉ុន្តែខ្ញុំគ្រាន់ថា ដាក់ក្មេងធំ វាមិនចាំបាច់ក្មេងធំ ក្មេងតូចទេ គ្រាន់ថាក្មេង កងឈ្លបច្រើនតែអាយុពីរបីដណ្តប់ហ្នឹង។

**ស៖** ធ្វើម៉េចបានលោកដឹងថា កងឈ្លបហ្នឹង មានអាយុ១២, ១៣ឆ្នាំ?

**ឆ៖** ទោះជាខ្ញុំ វាមិនប្រាប់អាយុពីរបីដណ្តប់ឆ្នាំ ក៏ខ្ញុំមើលទៅរូបរាងវា អាយុតែប៉ុណ្ណឹងដែរ ព្រោះវាស្តាយកាំភ្លើងអត់ផុតពីជើងផង ឲ្យខ្ញុំឆ្លើយថាម៉េចទៅ បើវានៅអួសផង អីផង។ មើលពីលើផ្ទះតាមប្រហោងរនាបទៅ វាឃើញទាបៗ លូនចូលអ៊ីចឹងហើយ។ ហ្នឹងឲ្យខ្ញុំឆ្លើយវាអាយុហាហុកសិបម៉េចទៅកើត ខ្ញុំថាក្មេងទៅ។

**ស៖** លោកធ្លាប់ស្គាល់ពួកគេពីមុនមកដែរទេ?

**ឆ៖** ខ្ញុំអត់ដែលស្គាល់គេច្បាស់លាស់ ប្រហែលគេស្គាល់ខ្ញុំច្បាស់លាស់ បានគេមកស៊ើបផ្ទះខ្ញុំដឹងនោះ។ ខ្ញុំអត់ដែលស្គាល់ទេ ថាអ្នកណាជាអ្នកណា អ្នកណាជាអ្នកណី។ ពេលថ្ងៃ អ្នកហ្នឹងដើរលេងធម្មតាទៅ ពេលយប់ទៅស៊ើបការណ៍ក្រោមផ្ទះខ្ញុំក៏មិនដឹងដែរ ព្រោះកូនចៅគេក្នុងមូលដ្ឋាន ខ្ញុំអត់ដឹង។

[១១:២៧:០៥]

**ស៖** បាទសូមអរគុណ។ លោកបញ្ជាក់ពីខាងដើមថា ពេលដែលការរួច លោកបានមកនៅត្រឹមតែមួយថ្ងៃទេ ហើយ១០ថ្ងៃត្រូវទៅធ្វើការ។ អ៊ីចេះលោកអាចបញ្ជាក់បានទេថា ៗការតាមដានលោកហ្នឹងតាមដានញឹកញាប់បែបយ៉ាងម៉េចទៅ?

**ឆ៖** ព្រោះបញ្ហាតាមដាន គឺខ្ញុំដឹងថាតាមដាន ព្រោះពេលយើងដេកជាមួយគ្នាហ្នឹង ដូចខ្ញុំជម្រាបអំមិញអ៊ីចឹង ថាលូនមកអ៊ីចឹង មិនមែនដានជើងទេ លូនមក មកដូចពស់ថ្លាន់អ៊ីចឹង។ ហើយខ្ញុំមើលតាមប្រហោងរនាប ស្គាល់ ឃើញច្បាស់ថាជាមនុស្ស។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមនិយាយអំពីពិធីរៀបអាពាហ៍ពិពាហ៍របស់លោក ដែលលោកបានឆ្លើយយ៉ាងច្រើនហើយ គឺទាក់ទងទៅនឹងការចូលរួមរបស់មេឃុំ និងមេភូមិ។ លោកអាចបញ្ជាក់បានទេថា អាពាហ៍ពិពាហ៍របស់លោកហ្នឹង គឺកាលពី ខ្ញុំសូមអនុញ្ញាតដកស្រង់ចម្លើយរបស់លោក នៅឯកសារE3/4609 ត្រង់សំណួរចម្លើយលេខ៥៣ ខ្ញុំសូមដកស្រង់កន្លែងដែលពាក់ព័ន្ធ។ លោកថា៖ "មិនមានវត្តមានមេភូមិ និងមេឃុំទេ" សូមបញ្ចប់ការដកស្រង់។ ប៉ុន្តែនៅក្នុងការឆ្លើយផ្តល់សក្ខីកម្មពីម្សិលមិញនេះ នៅខាងលើម៉ោង១៥:៤៤ លោកឆ្លើយថា៖ "ប៉ុន្តែគណៈស្រុកនៅហ្នឹងឃើញ គណៈនៅហ្នឹងឃើញ ប្រធានយុវជនអីឃើញទាំងអស់ ប៉ុន្តែយើងមិនស្គាល់ឈ្មោះគេ។" សូមចប់ការដកស្រង់។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើចម្លើយណាមួយជាចម្លើយពិតប្រាកដរបស់លោក?

[១១:៣០:០៧]

**ឆ៖** ចម្លើយដែលខ្ញុំឆ្លើយពេលអារៀបការហ្នឹង មានគេឡើងស្តីអាហ្នឹង មកគេចេញវោហាស័ព្ទមកប្រាប់ថារឿងពីគោលការណ៍អីគេហ្នឹង គេថាត្រូវអង្គការដឹងគុណអ្នកឯង ការប្រពន្ធឲ្យអ្នកឯក តើអ្នកឯងដឹកគុណអង្គការវិញ ដោយបង្កើតកូនបង្កើតចៅឲ្យបានច្រើន។ ខ្ញុំបាននិយាយអ៊ីចឹងមែន ប៉ុន្តែដូចខ្ញុំបានជម្រាបអ៊ីចឹងថា ខ្ញុំអត់ស្គាល់ច្បាស់ថាអ្នកណាជាគណៈឃុំ អ្នកណាគណៈស្រុកទេ។ ខ្ញុំមុនដំបូង ខ្ញុំឆ្លើយថា មិនដឹងជាអ្នកណាគណៈឃុំ គណៈស្រុកទេ មិនដឹងអ្នកណាមេភូមិ មេស្រុកទេ។ ខ្ញុំឆ្លើយថាអត់មាន។ ប៉ុន្តែដល់ពេលគេនេះមក និយាយអ៊ីចឹង គេឆ្លើយ ខ្ញុំនឹកឃើញ គេថា អ៎! អាហ្នឹងឆ្លើយថាគណៈ

ស្រុក ខ្ញុំឆ្លើយតាម។ អ៊ីចឹងអាការងារក្រោយដែលថាខ្ញុំមានគេចូលរួមច្រើននេះ អាហ្នឹងជាការពិត។

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់ថា មានគេឆ្លើយហើយ លោកឆ្លើយតាមថាមានគណៈស្រុកហ្នឹង លោកឆ្លើយតាមអ្នកណាគេ?

**ឆ៖** ខ្ញុំឆ្លើយតាមពេលគេឡើងថ្លែងការណ៍ហ្នឹង អាថ្លែងការណ៍ថា អង្គការមានគុណលើអ្នកឯង អ៊ីចឹងអ៊ីចឹងទៅ បានរៀបការឲ្យយុវជន យុវនារីអ៊ីចឹង ហើយតើអ្នកឯងសងគុណអង្គការវិញម៉េច របៀបម៉េច ឲ្យមានកូនចៅច្រើន ឲ្យមានអីដើម្បីបន្តវេន ព្រោះយើងខ្វះប្រជាជនធ្វើការច្រើន អ៊ីចឹងវាវែងឆ្ងាយពេក។ ដល់យើងប្រាប់អ៊ីចឹង គេហ្នឹង អ្នកដែលធ្វើសេចក្ដីថ្លែងការណ៍ហ្នឹង គេប្រាប់ថាគេមកពីខាងស្រុក។

[១១:៣២:០១]

**ស៖** បាទ យើងត្រឡប់ទៅសំណួរដំបូងរបស់ខ្ញុំវិញ ដែលខ្ញុំសួរលោកហ្នឹងថា ហេតុអីបានជាក្នុងចម្លើយដំបូងរបស់លោក លោកថាអត់មានវត្តមានខាងស្រុក ខាងភូមិខាងឃុំអីហ្នឹងទេ បានទើបតែក្រោយនេះ លោកប្ដូរថាមានវិញ។ អ៊ីចឹងបានខ្ញុំសួរបញ្ជាក់ លោកអាចបញ្ជាក់ពីភាពខ្វះចន្លោះនេះបានទេ?

**ឆ៖** ខ្ញុំបានជម្រាបលោកហើយថា អាខាងក្រោយនេះហើយជាការត្រឹមត្រូវ ព្រោះខ្ញុំយល់ទៅអាពេលគេបង្ហាញពីទឹកចិត្តរបស់គេ -- នែ៎ពីសតិសម្បជញ្ញៈគេ ថាគេជាឡើងថ្លែងការណ៍ថ្លែងអី ពីមុននោះ គឺជាខ្ញុំអត់បានយល់ទេ គឺថាខ្ញុំថាខុសទេ។ ឥឡូវអាក្រោយនេះដែលខ្ញុំយល់ថាគេថ្លែងការណ៍អង្គាល់ហ្នឹង គេប្រាប់គេ ៗថាប្រធានយុវជនស្រុក អ៊ីចឹងស្រុកគេទៅ។ ខ្ញុំនឹកឃើញត្រង់ហ្នឹង។ ក្រោយបានត្រឹមត្រូវ អាមុន បើលោកថាមិនត្រឹមត្រូវ គឺជារឿងរបស់លោកទេ ប៉ុន្តែខ្ញុំថាមុនខុសហើយ គឺខាងក្រោយនេះបានត្រឹមត្រូវ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវដល់ពេលសម្រាកអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់មួយកន្លះរសៀល សូមអញ្ជើញចូលវិញបន្តកិច្ចដំណើរការសវនាការ។

លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ឥឡូវនេះដល់ពេលឈប់សម្រាកថ្ងៃត្រង់ហើយ លោកស្រីអាចសម្រាកបានហើយ អង្គជំនុំជម្រះអញ្ជើញលោកស្រីមកកាន់កន្លែងផ្ដល់សក្ខីកម្មវិញឲ្យបានមុនម៉ោងមួយ

កន្លះរសៀល។

បង្គាប់--

[១១:៣៣:៤១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំចង់បញ្ជាក់សួរបន្តិចទេ ថាតើមេធាវីការពារក្តី ខៀវ សំផន មានសំណួរច្រើនបន្ថែមទៀតទេ?

**លោក គង់ សំអុន៖**

បាទ យើងមានសំណួរថែមទៀត។

**ប្រធានអង្គជំនុំ៖**

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤៥ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:៣០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមអញ្ជើញលោកមេធាវី ខៀវ សំផន បន្តសំណួរ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះសាជាថ្មី ហើយសូមជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំចង់សួរបន្តទៅលើសំណួរដែលខ្ញុំបានសួរពីមុនសម្រាកនេះ គឺទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍ ហើយដែលលោកត្រូវបានទទួលការតាមដានពីឈ្លប។ នៅពីព្រឹកមិញនេះផងដែរ លោកបានឆ្លើយចំពោះសំណួររបស់សហមេធាវីជាតិលោក នួន ជា លោកថាមិនបានដឹងថាមានគូដែលរៀបអាពាហ៍ពិពាហ៍ណាមួយ ក្រោយពីរៀបការហើយទទួលការតាមដានដូចលោកទេ។ តើលោកនៅចាំសម្តីនេះទេ?

**លោកស្រី ស៊ូ សុធារី៖**

**ឆ៖** ខ្ញុំអត់បានដឹងថាគូទាំងអស់ហ្នឹងមានគេតាមដានដូចគូខ្ញុំទេ ព្រោះអត់មានពេលទៅបានពិភាក្សាគ្នា។

[១៣:៣១:៤១]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងតួនាទីរបស់មេកងដែលខ្ញុំបានសួរពីព្រឹកមិញផងដែរ ខ្ញុំចង់ឱ្យលោកបញ្ជាក់បន្ថែមថា នៅក្នុងភូមិ ឬក៏សហករណ៍របស់លោក ជាពិសេសសហករណ៍ដែលលោកបានរៀបអាពាហ៍ពិពាហ៍ជាមួយនាង រដ្ឋា នោះ ថាតើនៅក្នុងភូមិ ឬក៏សហករណ៍របស់លោកហ្នឹងមានមេកងប៉ុន្មាននាក់នៅក្នុងភូមិហ្នឹង ឬក៏ឃុំហ្នឹង តាមដែលលោកដឹង?

**ឆ៖** អត់ដឹងថាប្រធានកងមានប៉ុន្មានទូទាំងឃុំទេ។

**ស៖** បាទ សូមអរគុណ។ លោកអាចចាំបានថាមានកងអីខ្លះដែរទេ?

**ឆ៖** គ្រប់មុខព្រួញនៃអង្គការខ្មែរក្រហមហ្នឹង គេសុទ្ធតែមាន សូម្បីតែចិញ្ចឹមជ្រូកក៏មានប្រធានក្រុមរបស់គេដែរ ប៉ុន្តែយើងវាមិនបានចាត់ចែង យើងចង់សុំអី ដូចឧទាហរណ៍អីចឹង ចង់សុំអំបិលអីពីកន្លែងអ្នកចិញ្ចឹមជ្រូក គេថាទៅសុំប្រធានខ្ញុំ អ្នកនោះ! គ្រាន់តែប៉ុណ្ណឹងប្រធានកងខ្ញុំនៅហ្នឹង គ្រាន់តែគេប្រាប់អីចឹង យើងអត់ដែលហ៊ានសុំប្រធានកង សុំគ្នាឯង បើអីចឹងយើងអត់នឹងមានប្រធានកងកន្លែងណាខ្លះ ប៉ុន្តែដឹងថាក្នុងមួយឃុំហ្នឹង ប្រធានកង មុខយល់មិនច្បាស់គ្រប់គ្នាទាំងអស់ហ្នឹង អ្នកថ្មីទាំងអស់ អ្នកអីក៏ដោយ ក៏អត់ដឹងថាប្រធានកងនេះទទួលខុសត្រូវអី ប្រធានកងនោះអត់ដឹង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ឱ្យច្បាស់បានទេថាប្រធានកង និងប្រធានក្រុមមានតួនាទីខុសគ្នា ឬក៏តាមអ្វីដែលលោកនិយាយអំមិញហ្នឹង ប្រធានក្រុម ឬប្រធានកងហ្នឹងគឺជាមនុស្សតែមួយប្រភេទទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំអត់ដឹងថានរណាជាប្រធានកង ប្រធានក្រុមអីទេ ប៉ុន្តែគ្រាន់តែដឹងថា ដឹងតែប្រធានកង ស្អីក៏កង ស្អីក៏កង ដឹងតែពាក្យមួយម៉ាត់ថាប្រធានកង ខ្ញុំអត់ដែលសួរប្រើពាក្យប្រធានក្រុមអីជាមួយគេផង គេឆ្លើយខ្ញុំវិញមក គេប្រាប់តែប្រធានកងអ៊ីចឹង ចប់អត់មានដឹងរឿងអីទាំងអស់។

[១៣:៣៤:៣៥]

**ស៖** បាទ សូមអរគុណ។ លោកប្រធានសូមអនុញ្ញាតអានឯកសារ E3/4609 ត្រង់សំណួរចម្លើយលេខ៥៤។ សូមដកស្រង់៖ "នៅក្នុងយប់នោះ យើងមិនបានរួមភេទជាមួយគ្នាទេ គឺដេកនៅម្ខាងម្នាក់ ហើយមេកងបានចាត់ឱ្យមានឈ្លបមកស៊ើបនៅក្រោមផ្ទះ"។ ចប់ការដកស្រង់។ ខ្ញុំសូមមានសំណួរចំពោះលោកដើមបណ្តឹងរដ្ឋប្បវេណីថា ធ្វើម៉េចបានលោកដឹងថា មានមេកងចាត់ឈ្លបឱ្យមកស៊ើបនៅក្រោមផ្ទះរបស់លោក?

**ឆ៖** ខ្ញុំបានជម្រាបលោកហើយ ខ្ញុំច្រើនប្រើពាក្យ "មេកង"។ អ៊ីចឹងការមកឈ្លបក្រោមផ្ទះខ្ញុំស្តាប់រឿងរ៉ាវនេះ គឺមានមេកងគេចាត់តាំងហើយ បានមានមនុស្សមកស៊ើបការណ៍។ អ៊ីចឹងខ្ញុំប្រើពាក្យថា "ច្រើនតែមេកង" បើអ៊ីចឹង ខ្ញុំប្រើពាក្យ "មេកង" ប្រហែលជាគេឱ្យឈ្លបនឹង។

**ស៖** បាទសូមអរគុណ។ នៅពេលដែលលោកបានផ្តល់សក្ខីកម្មនៅទីនេះ អំពីអត្តសញ្ញាណភេទរបស់លោក លោកបានបញ្ជាក់ថា លោកជាបុរសដែលមានភេទទី៣។ ខ្ញុំចង់សួរលោកថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅពេលនោះ តើអត្តសញ្ញាណជាភេទទី៣នេះ លោកបានបង្ហាញជាសាធារណៈ ឬមួយក៏លោកមានការបិទបាំងដើម្បីបង្ហាញថាខ្លួនឯងជាបុរស?

**ឆ៖** បើសិនណាកាលហ្នឹងខ្ញុំបង្ហាញអត្តសញ្ញាណរបស់ខ្លួនថា ខ្លួនជាប្រភេទទី៣ ប្រុសស្រឡាញ់ប្រុស ហើយនិងស្រីស្រឡាញ់ស្រី មិនបានលោកសួរខ្ញុំថ្ងៃនេះទេ គេយកទៅវ៉ៃចោលបាត់ហើយ។

[១៣:៣៧:១១]

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងទៅនឹងភរិយា អតីតភរិយារបស់លោកឈ្មោះ រដ្ឋា ហ្នឹង គាត់បានដឹងពីអត្តសញ្ញាណរបស់លោកក្នុងលក្ខណៈថា ជាបុរសភេទទី៣ហ្នឹង នៅពេលណាដែរ?

**ឆ៖** នៅពេលរៀបការហើយហ្នឹង បានដឹងជាច្បាស់លាស់ យើងបង្ហាញប្រាប់ប្រពន្ធថា ខ្ញុំជាប្រភេទទី៣ អត់មានចិត្តអីស្រឡាញ់ស្រីទេ។ អាហ្នឹងគេដឹងពេលហ្នឹង ពីដើមមកមិនដែលជួបគ្នា បាននិយាយគ្នាផង ក៏អត់មានដឹងរឿងអី បាននិយាយចរចាជាមួយគ្នាទេ។

**ស៖** បាទ លោកបានបញ្ជាក់ខាងដើមរួចមកហើយថា លោកមិនមានពេលវេលានិយាយគ្នាជា

មួយភរិយារបស់លោកទេ ហើយជាពិសេសលោកថា លោកបានជួបគ្នាប្រហែល១០ថ្ងៃម្តង ហើយពេលនៅជាមួយគ្នា ក៏មិនបានពិភាក្សាគ្នាពីអ្វីដែរ។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើលោកដឹងថាភរិយារបស់លោកឈ្មោះ វង្ហា ហ្នឹងគាត់មានការមិនពេញចិត្ត ឬក៏មិនសប្បាយចិត្ត ហើយគាត់ទៅនិយាយនៅខាងក្រៅ ឬក៏ទៅប្តឹងដល់មេភូមិ មេឃុំ ឬក៏អ្នកណាម្នាក់ដែលជាអ្នកគ្រប់គ្រងគាត់ហ្នឹង អំពីស្ថានភាពរបស់លោកដែរទេ?

**ឆ៖** រឿងប្រពន្ធខ្ញុំ គ្មានរឿងការតូចចិត្តនឹងអាការមិនបានរួមភេទហ្នឹងជារឿងធំទេ។ អត់បានទៅរាយការណ៍ប្រាប់អង្គការហ្នឹងទាំងអស់ ទុកជាដឹងប្តីថា មិនចូលចិត្តស្រីក៏ដោយចុះ ព្រោះអាចិកំបាំងនេះ ខ្ញុំបាននិយាយពេលខ្ញុំប្រាប់អង្គសវនាការរួចហើយថា ខ្ញុំបាននិយាយពីគ្នាពីពេលបង់កក្រមា ប្រាកដជាមានពាក្យដែលនិយាយបង្ហាញពីអត្តសញ្ញាណរបស់ខ្ញុំរួចហើយ។ អ៊ីចឹងគេអត់មានអន់ចិត្ត អន់ថ្លើមជាមួយខ្ញុំទេ។

**ស៖** គាត់បាននិយាយជាមួយលោកពីបញ្ហាហ្នឹង ថាគាត់មិនមានការអន់ចិត្ត ឬមួយក៏លោកធ្វើការសន្និដ្ឋានដោយខ្លួនឯងទេ ក្នុងចំណុចនេះ?

[១៣:៣៩:៥៨]

**ឆ៖** ចំណុចនេះ ប្រពន្ធខ្ញុំក៏មិនដែលនិយាយអីប្រាប់ខ្ញុំថា រឿងអ៊ីចេះអ៊ីចុះទេ។ វាធម្មតា ប្តីប្រពន្ធទៅជួបញញឹមញញែមគ្នា ខ្ញុំតើសន្និដ្ឋានខ្លួនឯង។

**ស៖** បាទ សូមអរគុណ។ ដោយសារលោកជាពលរដ្ឋខ្មែរម្នាក់ ខ្ញុំចង់សួរជាលក្ខណៈទូទៅអំពីប្រពៃណីក្នុងការរៀបអាពាហ៍ពិពាហ៍។ ថាតើលោកយល់ដឹង ជាពិសេសនៅក្នុងសម័យមុន កម្ពុជាប្រជាធិបតេយ្យ មុនឆ្នាំ១៩៧៥ តើការរៀបចំគូស្រករឱ្យកូនចៅហ្នឹង ខ្មែរយើងធ្វើអ្វីខ្លះ លោកអាចបញ្ជាក់បានទេ?

**ឆ៖** លោកមេធាវីគួរដឹងជ្រាបហើយ ថាប្រពៃណីខ្មែរមុនពី៧៥ហ្នឹង រហូតដល់៧៩ហ្នឹង គេដឹងឮគ្រប់គ្នាទាំងអស់ មិនបាច់ខ្ញុំនិយាយប្រាប់ ក៏ដឹងដែរ ថាប្រពៃណីខ្មែររៀបការរបៀបម៉េច។ អ៊ីចឹងខ្ញុំមិនបាច់សបញ្ជាក់ប្រាប់ទេ។ វាខុសពីជំនាន់ ប៉ុល ពត ដែលចាប់បង្ខំរៀបការ យកទៅគំរាមកំហែង សម្លុតហ្នឹងវាខុសគ្នាត្រង់ហ្នឹង។ ព្រោះកាលពីជំនាន់ដើម មកឥឡូវ ៗរាល់ថ្ងៃអ៊ីចឹងដែរ ការគេមានប្រពៃណីព្រោះប្រពៃណីខ្មែរ គឺគោរពប្រពៃណីខ្មែរ។ លោកដឹងហើយ អ៊ីចឹងលោកមិនបាច់សួរខ្ញុំទេ ហើយប្រជាជនទាំងអស់ ក៏ដឹងឮទាំងអស់ដែរ លើកលែងតែអ៊ំៗ ហើយនិងបងៗជនជាតិបរទេស ដែលគាត់មិនសួរ

ដឹងប្រពៃណីខ្មែរ តែគាត់ចូលមកប៉ុន្មានឆ្នាំនេះ ក៏គាត់ដឹងដែរ។ ៣០ឆ្នាំហើយ ដឹងទាំងអស់។

**ស៖** បាទ សូមអរគុណ។ បើលោកអាចបញ្ជាក់ពីចំណុចជាក់លាក់ណាបាន លោកអាចបញ្ជាក់ទៅ ពីព្រោះយើង ដូចលោកមានប្រសាសន៍អ៊ីចឹង ថាមានចៅក្រមបរទេសនៅទីនេះដែរ ហើយគាត់មានសិទ្ធិក្នុងការសម្រេចនៅក្នុងរឿងនេះ។ លោកមានអ្វីចង់បន្ថែមទេ?

[១៣:៤២:៤២]

**ឆ៖** បើលោកចង់ឲ្យខ្ញុំបញ្ជាក់ពីរឿងរៀបអាពាហ៍ពិពាហ៍ ខ្មែរយើងប្រពៃណីល្អណាស់។ ខ្ញុំបញ្ជាក់ប្រាប់លោកថា "មុននឹងស្ដីដណ្ដឹងកូនចៅត្រូវមើលផៅសន្ដាន មុននឹងដាំជើងក្រាន ឲ្យប្រមាណនឹងឆ្នាំង"។ បើអ៊ីចឹងត្រូវយល់ហើយ ទៅសួរខាងស្រី ថាកូនគេចូលដណ្ដឹងហើយ កូនព្រមទេ? ថាព្រមរៀបការ។ រៀបការខ្មែរមានអី ភ្ជាប់ពាក្យអ៊ីចឹងទៅ ពាក់ជាចិញ្ចៀនពាក់ជាអ៊ីចឹងទៅ។ ហើយប្រពៃណីយប់ទី១ ត្រូវធ្វើអី? សូត្រមន្តអ៊ីចឹងទៅ អ៊ីចឹងទៅ សុំសីលប្រាំ ចាំសីលប្រាំបីអ៊ីចឹងទៅ ឬមួយក៏អីទៅ។ ថ្ងៃទី២ ត្រូវធ្វើអី? ហែកំណត់ ហែអ៊ីចឹងទៅ។ ដល់ភ្លឺឡើង ថ្ងៃទី៣ស្អី ធ្វើអី? ត្រូវផ្ទឹមអ៊ីចឹងទៅ។ ហ្នឹងជាប្រពៃណីខ្មែរយើង តែបើជំនាន់ប៉ុលពត អត់មានលោកសូត្រមន្ត អត់មានហែហាមអីទេ អត់មានសម្លៀកបំពាក់សំអាងការអីទេ។ ស្រួលជាទីបំផុត ខោខ្មៅ អាវខ្មៅ ស្បែកជើងកងឡាន ហើយក្រមាមួយ ចប់។

**ស៖** បាទ សូមអរគុណ។ ចុះលោកដែលឮពីពាក្យចាស់ដែលថា "ម្ដាយទុកឪពុកដាក់" បានន័យថា ម្ដាយឪពុកហ្នឹងជាអ្នករៀបចំគូស្រករឲ្យកូន។ លោកដែលដឹងទេ?

**ឆ៖** ឮតើពាក្យហ្នឹង មិនមែនថាមិនឮទេ ព្រោះយើងជាខ្មែរ ស្ដាប់ភាសាហ្នឹងបាន។ កូនចង់បានប្រពន្ធ ម៉ែឪទៅស្ដីឲ្យ ហើយកូនស្រីអ៊ីចឹងដែរ គេចូលស្ដីដណ្ដឹង ទទួលបានក៏ទទួល ទទួលមិនបានក៏អត់វាមានភាគតិចណាស់ បង្ខំឲ្យរៀបការទាំងទទឹងទិស ប៉ុន្ដែនៅជាប្រពៃណីខ្មែរដដែល។ តែដោយឡែកខ្មែរក្រហម ជំនាន់កាលនេះគឺគ្មានសួរសុខទុក្ខ សួរអ្នកឯងស្អីៗទេ។ ត្រូវគូណា ជល់គូហ្នឹងទៅ ដូចខ្ញុំជម្រាបខាងដើមហើយ។

[១៣:៤៥:១៦]

**ស៖** បាទសូមអរគុណ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យបានច្បាស់អំពីគោលការណ៍ដែលអាចលោកដឹង ឬក៏ទទួលតាមរយៈការប្រជុំជាដើមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសមុនពេលដែលលោករៀបអាពាហ៍ពិពាហ៍ហ្នឹង លោកបានទទួលការណែនាំជាលក្ខណៈគោលការណ៍ជាទូទៅយ៉ាងដូចម្ដេចដែរទេ ឬក៏មានការនិយាយនៅក្នុងភូមិ នៅក្នុងអង្គភាពរបស់លោកដែរទេ អំពីរបៀបនៃការរៀបការ

មុននឹងអាចសម្រេចទៅរកការរៀបការហ្នឹងបាន?

**ឆ៖** ខ្ញុំស្ដាប់អត់បានច្បាស់ទេ លុលៗ។ បើអ៊ីចឹង សូមសំណួរសួរម្ដងទៀត ខ្ញុំស្ដាប់អត់បានច្បាស់ទេ ហ៊ីងស្ទឹកត្រចៀក។

**ស៖** បាទ ខ្ញុំនឹងនិយាយសាឡើងវិញ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើលោកបានដឹងអំពីគោលការណ៍ទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែរទេ ដូចជាតាមរយៈការប្រជុំ ឬក៏ការណែនាំណាមួយរបស់អ្នកដឹកនាំមូលដ្ឋាននៅក្នុងទីកន្លែងរបស់លោកធ្វើហ្នឹង? លោកមានបានដឹងទេថា ដើម្បីរៀបគូស្រករបានគេត្រូវមានលក្ខខណ្ឌអ្វីខ្លះ?

[១៣:៤៧:១១]

**ឆ៖** បាទ រឿងបញ្ហាមានការណែនាំពីខាងក្រៅ ឬក៏ប្រជុំ ឬក៏អី ក៏ខ្ញុំអត់ដែលបានចូលរួមនឹងគេហើយអត់បានឮដែរ។ តែរឿងបញ្ហាដូចខ្ញុំជម្រាបពីខាងដើមថា គេប្រកាសឲ្យរៀបការយុវជន យុវនារីនេះ គ្រាន់តែឮតាមរហិចរហៀងមកទេ។ អាហ្នឹងគេនិយាយថា គេរៀបការឲ្យយុវជន យុវនារី ខែកុម្ភៈនេះ ៧៧នេះ។ អត់ ខ្ញុំចាំមើល ចាំមើលអ៊ីចឹងទៅ មិនដឹងគូណានឹងគូណា។ ដល់ពេលខ្ញុំដឹងខ្លួនទាន់ដោយសារមានគេកាត់សក់ខ្ញុំ គេមកឲ្យខ្ញុំកាត់សក់ គេកាត់សក់ឲ្យផ្ទាល់ទៀត។ ខ្ញុំក៏សន្និដ្ឋានក្នុងចិត្តខ្ញុំ ថាប្រហែលជាមានរូបខ្ញុំដែរ។ តែខ្ញុំមិនអររំភើបអីទាំងអស់ ព្រោះខ្ញុំនឹកឃើញថា មិនបាច់ក៏បានដែរ រឿងការប្ដីប្រពន្ធ បើសិនណាអាចចៀសបាន ខ្ញុំចៀស។ ប៉ុន្តែកាលជំនាន់ហ្នឹង ដូចខ្ញុំបានជម្រាប បានក្លាយទៅជារៀបគ្នានេះ ដោយសារខ្ញុំចៀសមិនរួច ខ្លាចការស្លាប់។

**ស៖** បាទ សូមអរគុណ។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតដកស្រង់ឯកសារ E3/765 ត្រង់ ERN ជាភាសាខ្មែរលេខ 00376493 ដល់94, ភាសាបារាំង 00540024 ដល់25, ភាសាអង់គ្លេស 00539994។ លោកចៅក្រមបានស្ដាប់ការដកស្រង់នេះច្រើនដងហើយ ប៉ុន្តែខ្ញុំត្រូវការសួរដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីទទួលប្រតិកម្មរបស់គាត់។ អ៊ីចឹងខ្ញុំសូមដកស្រង់៖ “ចំណុចទី៦ កុំប្រព្រឹត្តអ្វីដែលល្មើសនឹងស្ត្រីភេទឲ្យសោះ និយាយរួមគឺកុំប៉ះពាល់សីលធម៌នារីបុរសឲ្យសោះ ព្រោះបញ្ហានេះវានាំឲ្យប៉ះពាល់កិត្តិយសយើង ឥទ្ធិពលយើងជាជនបដិវត្តន៍ នាំឲ្យប៉ះពាល់ដល់ប្រពៃណីស្អាតស្អំ ថ្លៃថ្នូររបស់ប្រជាជនយើង។ ដូច្នេះប៉ះពាល់ដល់ប្រជាជនយើង នេះម្យ៉ាង។ តែសំខាន់ម្យ៉ាងទៀត គឺបើយើងប៉ះពាល់សីលធម៌នារីបុរស ដែលជាធាតុពិតពុករលួយស្អុយគគ្រុករបស់ខ្មាំងសត្រូវគ្រប់ប្រភេទនោះ នឹងនាំឲ្យខ្មាំងអូសទាញយើងបាន។ ដូច្នេះគ្រោះថ្នាក់ដល់ខ្លួន គ្រោះថ្នាក់ដល់ចលនាបដិវត្តន៍។ ចំពោះបញ្ហារៀបចំគ្រួសារ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01355096



បច្ចុប្បន្ននេះ គ្មានអ្វីជាឧបសគ្គទេ ឲ្យតែឈរលើគោលការណ៍របស់បក្សទាំងពីរយ៉ាង គឺទី១ សាមីខ្លួនទាំងសងខាងយល់ព្រម។ ទី២ សមមូហភាពយល់ព្រម គឺជាការស្រេចទៅហើយ។ តើមានហេតុផលអីនាំឲ្យយើងប៉ះពាល់សីលធម៌បុរសនាទីទៀត។" សូមចប់ការដកស្រង់។

[១៣:៥០:៤៨]

លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកបានស្ដាប់នូវការដកស្រង់របស់ខ្ញុំ នូវគោលការណ៍សីលធម៌ ១២ប្រការនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំចង់សួរលោកថា តើលោកធ្លាប់បានឮនូវព័ត៌មានស្រដៀងគ្នានេះដែរទេ ពីមុនមកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? ហើយលោកមានប្រតិកម្មយ៉ាងណា នៅពេលដែលលោកបានស្ដាប់ការអានរបស់ខ្ញុំអម្បាញ់មិញនេះ?

**ឆ៖** គោលការណ៍នេះ ទើបតែស្ដាប់លោកអំមិញឲ្យស្ដាប់ តាំងពីដើមមក ខ្ញុំមិនដែលបានស្ដាប់គោលការណ៍ហ្នឹងទេ គឺតែលោកទើបបញ្ចេញអំមិញ ខ្ញុំឮអំមិញហ្នឹងឯង។ អត់ដែលឮទេ។

**ស៖** បាទ សូមអរគុណ។ លោកមានប្រតិកម្មអីឆ្លើយតបទៅនឹងខ្លឹមសារនៃគោលការណ៍នេះដែរទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី តើលោកអាចឲ្យសាក្សីបញ្ចេញប្រតិកម្មបែបណា ប្រសិនបើគាត់មិនដែលឮនោះ? លោកអាចសួរអីបាន ប៉ុន្តែតើឲ្យគាត់ឆ្លើយថា គាត់មានប្រតិកម្មយ៉ាងម៉េច បើគាត់មិនដែលឮ ឲ្យគាត់និយាយយ៉ាងដូចម្ដេចទៅវិញ?

**លោក គង់ សំអុន៖**

លោកចៅក្រម គាត់អត់បានឮ អាចមិនបានឮពីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែគាត់បានឮការអានរបស់ខ្ញុំជូនគាត់អម្បាញ់មិញនេះ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើប្រតិកម្មរបស់គាត់ យ៉ាងដូចម្ដេចឆ្លើយតបទៅនឹងគោលការណ៍នេះ។

[១៣:៥៤:១៤]

**លោកស្រី ស៊ូ សុធាវី៖**

**ឆ៖** ខ្ញុំអត់មានប្រតិកម្មអីនឹងសំឡេងលោកប្រកាសពេលនេះទេ ព្រោះគម្ពីរយុត្តិសាស្ត្រនេះ មិនមែនខ្ញុំជាអ្នករៀនទេ។ បើអ៊ីចឹងអាសូត្រមកអំមិញនេះ ខ្ញុំអត់មានប្រតិកម្មទេ គ្មានការឈឺចាប់អី ដំណាក់កាលប៉ុណ្ណោះ។ ៧៨ទៅហើយ នៅថ្ងៃស្លាប់ទៅវិញស្អែក ទៅប្រតិកម្មខឹងសម្បាររឿងអី។ សូម្បីតែដើម

01355097



ចោទ ក៏ចាស់ហើយ ពិការទៀត ចុងចោទជិតស្លាប់ទៀត។ អាយុដំណាក់បងគ្នាបន្តិចបន្តួច ប្រតិកម្មអី គ្មានប្រតិកម្មទេ។ សូមលោកទុកចិត្តចុះ ខ្ញុំអត់ខឹងនឹងលោកនិយាយរឿងហ្នឹង។ ប្រតិកម្មអី ខឹងឆេវឆាវ ទេ។ សូមអរគុណ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ពាក្យថា "ប្រតិកម្ម" នេះមិនមែនមានន័យថា ជាការប្រតិកម្មតប ដោយខឹងអីទេ គឺជាការឆ្លើយតបរបស់លោក ទៅនឹងគោលការណ៍នេះ ដែលលោកមិនដែលបានស្តាប់ឮ ពីមុនមក ប៉ុន្តែឥឡូវនេះលោកអាចឆ្លើយតប បើសិនជាលោកមាន។ បើថាលោកមិនមានទេ មិនជាថ្វីទេ បាទ។ ខ្ញុំនៅសំណួរតូចមួយទៀត ទាក់ទងទៅនឹងចំនួនគូរៀបអាពាហ៍ពិពាហ៍នៅសម័យកាលរបស់ លោក នៅជំនាន់លោក ដែលលោកបានឆ្លើយបញ្ជាក់ពីព្រឹកមិញមួយសាទៀតយ៉ាងច្បាស់ហើយថា លោករៀបការសម័យនោះ មានចំនួន១១៧គូ ដែលមានអ្នក១៧មេសាចំនួន៨០គូ។ ហើយលោកថា លោកមិនដែលនិយាយថា មានចំនួន១០៧គូទេ លោកបានបញ្ជាក់ពីព្រឹកមិញ។ ក៏ប៉ុន្តែខ្ញុំបានឃើញនៅ ក្នុងសវនាការពីម្សិលមិញហ្នឹងនៅម៉ោងប្រហែលជា០៣:៤៧នាទី មុនហ្នឹងបន្តិចហ្នឹង លោកបានឆ្លើយ ថា "មានចំនួន១០៧គូ"។ ដូច្នេះអាព័ត៌មាននេះវាខុសគ្នាបន្តិចបន្តួចទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យៗ លោកឆ្លើយថា តើមួយណាពិតប្រាកដ ១១៧គូ ឬក៏៧គូ? ពីព្រោះវាមានកំណត់ហេតុសវនាការបញ្ជាក់ ថា លោកបាននិយាយថា១០៧គូ។

[១៣:៥៥:៥៨]

**ឆ៖** ខ្ញុំ ជាសក្ខីកម្មសូមស្បថជូនតុលាការ ខ្ញុំមិនដែលនិយាយ១០៧គូទេ អត់សោះឡើយណា។ ខ្ញុំចាំក្នុងចិត្តរបស់ខ្ញុំជានិច្ច១១៧គូ ៨០គូក៏ជា១៧មេសា។ ហើយខ្ញុំបាននិយាយទៀត ខ្ញុំគូទី៧ ពេលគេ ហៅប្តេជ្ញា ខ្ញុំឡើងក្រោយគេ ជាគូទី៧ ខ្ញុំក៏ដាក់ខ្លួនឯងជាទី តែឲ្យពាក្យណាទាំងអស់ ដែលខ្ញុំនិយាយ បំផ្លើស សូមឲ្យបរាជ័យ ខ្ញុំស្បថជូនលោកថា ខ្ញុំអត់ដែលនិយាយ១០៧គូទេ។ ខ្ញុំចាំច្បាស់ ១១៧គូ។

**ស៖** បាទសូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរតូចមួយទៀតទាក់ទងទៅ នឹងសាច់ញាតិរបស់លោក ដែលលោកបានបញ្ជាក់ពីម្សិលមិញផងដែរ។ លោកថា លោកមានបងថ្លៃ បងថ្លៃហ្នឹងបងថ្លៃស្រី ហើយដែលជាអ្នកផ្តល់ព័ត៌មានពីកំណើតកូនស្រីរបស់លោក។ តើលោកនៅចាំ ចំណុចនេះបានទេ?

**ឆ៖** បាទ ខ្ញុំបានឆ្លើយប្រាប់ហើយថាបងថ្លៃស្រីរបស់ខ្ញុំប្រាប់ខ្ញុំនោះ បងថ្លៃស្រីខ្ញុំ ក៏មេម៉ាយដែរ

គេយកប្ដីយកទៅសម្លាប់បាត់ហើយ។ អ៊ីចឹងគាត់ប្រាប់ថា អ្អែងកើតបានកូនស្រីហើយ គ្រាន់តែដឹងតែប៉ុណ្ណឹងទេ តែមុខកូនក៏មិនឃើញ អីក៏មិនឃើញដែរ។ ខ្ញុំបានជម្រាប ខ្ញុំរាប់ប្រាប់ពីម្សិលមិញហើយ បងថ្លៃស្រីហ្នឹងមិនបាច់បញ្ជាក់ថាបងថ្លៃប្រុសបងថ្លៃស្រីទេ ព្រោះខ្ញុំប្រាប់ថាខ្ញុំមានបងប្អូនស្រីតែពីរនាក់ ប្រុសដល់បីដណ្ដប់នាក់ណោះ។ អ៊ីចឹងខ្ញុំភាគតិចណាស់ដែលមានបងថ្លៃប្រុសមកប្រាប់ខ្ញុំ អ៊ីចឹងមានតែបងថ្លៃស្រីទេ។ សូមអរគុណ។

[១៣:៥៨:១០]

**ស៖** បាទ លោកអាចបញ្ជាក់បានទេថា បងថ្លៃស្រីហ្នឹងខាងៗសាច់ថ្លៃខាងប្ដីជាបងបង្កើត ឬក៏ប្អូនបង្កើតរបស់លោក មិនមែនៗខាងប្រពន្ធលោក នាងរដ្ឋា ទេ អ៊ីចឹងមែនទេ?

**ឆ៖** ស្ដាប់សំណួរនេះមិនច្បាស់ទេ តែគ្រាន់តែខ្ញុំស្ដាប់បានចុងៗពាក្យថា សួរហ្នឹងបងថ្លៃខ្ញុំ ឬមួយក៏បងថ្លៃខាងប្រពន្ធខ្ញុំ ឬមួយក៏យ៉ាងម៉េច? បាទ ខាងប្រពន្ធខ្ញុំ ខ្ញុំប្រាប់ថាគ្នាកំព្រា អត់មានម៉ែមានឪ ហើយលោកមេធាវីក៏ចាំខ្ញុំឆ្លើយពីរសា បីសា បួនសាហើយ ប្រាប់ថាខាងប្រពន្ធខ្ញុំអត់មានទេ កំព្រានៅម្នាក់ឯងគត់ គឺជាបងថ្លៃប្រុសរបស់ -- បងថ្លៃស្រីខ្ញុំអ្នកប្រាប់។ ខ្ញុំកំព្រាមែន តែមានបងថ្លៃស្រីនៅដោយសារគេយកបងប្រុសបង្កើតទៅសម្លាប់អស់។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ ដោយសារបញ្ហានេះហើយ បានជាខ្ញុំសួរបញ្ជាក់បន្ថែម ពីព្រោះពាក្យខ្មែរយើង ពាក្យថា "បងថ្លៃ" វាអត់ច្បាស់ថាបងថ្លៃខាងណាទេ។ បាទ សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំអត់សំណួរហើយ។

[១៣:៥៩:២៩]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងឋានៈលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្ដាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ មករា ឆ្នាំ១៩៧៩ និងអំពីស្ថានភាពព្យសនកម្ម គឺការខូចខាតដែលកើតមានឡើងចំពោះលោក ជាអាទិ៍ ខូចខាតខាងរាយកាយ សម្ភារៈ ឬក៏ផ្លូវចិត្ត ហើយជាផលប៉ះពាល់

ផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានឡើងពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ ដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងទាមទារសំណង និងជាសមូហភាពពីជនជាប់ចោទ។

បើសិនជាលោកស្រីមានបំណងដូច្នេះ គឺលោកស្រីអាចថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មចំពោះមុខអង្គជំនុំជម្រះបាន ឬក៏អាចតាំងសំណួរទៅកាន់ជនជាប់ចោទបានតាមរយៈអង្គជំនុំជម្រះ។ សូមអញ្ជើញលោកស្រី!

[១៤:០០:៥៥]

**លោកស្រី ស៊ូ សុធាវី៖**

បាទ ខ្ញុំអត់មានសំណួរអីសួរទៅទេ អត់មានប្រយោជន៍អីនឹងសម្រាប់ជីវិតខ្ញុំ ព្រោះខ្ញុំបានឡើងមកធ្វើសក្ខីកម្មមុន បានសំណួរសួរទៅគាត់រួចហើយ គាត់ឆ្លើយពាក្យបង្វែងដាន អ៊ីចឹងខ្ញុំអត់ចង់បានទេ។ ប៉ុន្តែខ្ញុំសូមថ្លែងសក្ខីកម្ម ថាខ្ញុំមានការឈឺចាប់ណាស់ បាត់បង់អស់គ្រួសារ តែខ្ញុំអត់ប្ដឹងទេពីរឿងបញ្ហាបងខ្ញុំ ឪពុកខ្ញុំ ម្ដាយខ្ញុំ ព្រោះស្ដាប់ឃើញតែពីរនាក់ដែលគេចងបណ្ដើរកាត់មុខ តែចំពោះអ្នកអស់ទៀតអត់ឃើញពិតប្រាកដទេ ខ្ញុំអត់មានប្ដឹងជំនួសគេទេ គេនេះប្ដឹងពីការឈឺចាប់របស់ខ្ញុំ រឿងរបស់ខ្លួនខ្ញុំផ្ទាល់ដែលធ្វើឲ្យខ្ញុំពិការជើង ដំបៅជើង បាក់ឆ្អឹងថ្គាម បាត់បង់អស់នូវគ្រួសារ បាត់អស់រលីងអ្វីៗដែលនៅក្នុងខ្លួន បាត់ការរកក្ដៅជាមួយក្រុមគ្រួសារ គ្មានអីជាសំខាន់ទេ។ ខ្ញុំយំរីងហើយ តែថ្ងៃនេះខ្ញុំសូមបញ្ជាក់ប្រាប់ថា ខ្ញុំឆ្អែតនឹងរបប៣ឆ្នាំ ៨ខែ ២០ថ្ងៃណាស់ អ្នកណាក៏ជួប អ្នកណាក៏ស្គាល់ អ្នកណាក៏ឃើញ អ្នកណាក៏ឮដែរ តែខ្ញុំឈឺចាប់តាំងពីការបង្ខំរៀបការ គេគំរាមកំហែង គេមើលងាយ មានសព្វគ្រប់ទាំងអស់លើការបៀតបៀននូវផ្លូវភេទដែលខ្ញុំជាប្រភេទទី៣។ ខ្ញុំមានការឈឺចាប់ណាស់ ខ្ញុំបាត់ការចងចាំច្រើនណាស់។ ថ្គាមខ្ញុំបាក់ពេលណា ក៏ខ្ញុំឈឺ ក្ដៅពេញខ្លួនទាំងអស់។ ហើយអ្វីៗខ្ញុំមិនសូវជាចងចាំបាន១០០ភាគរយទេ ភ្នែកក៏ពិការ ដោយសារគ្រាប់កាំភ្លើង ខ្នងជើងខាងស្ដាំដោយសារជាប់ខ្នោះ ជាប់ច្រវាក់នៅក្នុងគុក រលួយទាំងអស់ រកថ្លែងអីមិនបាន រកអ្វីមកសងនូវការឈឺចាប់ខ្ញុំមិនបានទេ។ ដោយឡែកខ្ញុំចង់បង្ហាញទុក្ខសោកនេះ គ្រាន់ថាជាការឈឺចាប់របស់ខ្ញុំប៉ុណ្ណឹងបានហើយ ខ្ញុំមិនអាចនិយាយតទៅមុខទៀតបាន ព្រោះខ្ញុំវាអស់ហើយ អាយុ៧៨ ឲ្យវាឆាចោលមួយជីវិតទៅចុះ ថាអំពើទុក្ខសោកទាំងអស់នេះ ជាខ្ញុំអ្នកទទួលកម្មផលដែលខ្ញុំបានសាងពីជាតិមុនតែប៉ុណ្ណោះ។ សូមអរគុណ។

[១៤:០៣:៤៣]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះអរគុណលោកស្រីដែលបានចំណាយពេលវេលាមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។ លោកស្រីអាចត្រឡប់ទៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬគោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ សូមអញ្ជើញ!

*(ដើមបណ្តឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ)*

អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី និងសាធារណជនបានជ្រាបថា ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-264 ដែលនឹងត្រូវមកផ្តល់សក្ខីកម្មបន្ទាប់នៅថ្ងៃនេះ បានធ្លាក់ខ្លួនឈឺកាលពីយប់មិញ ហើយមិនទាន់បានធូរស្រាលនៅឡើយទេរហូតមកដល់ពេលនេះ។ អង្គជំនុំជម្រះមិនអាចស្តាប់សក្ខីកម្មដើមបណ្តឹងរូបនេះ នៅថ្ងៃនេះបានទេ ហើយនិងលើកការស្តាប់សក្ខីកម្មរបស់គាត់នៅថ្ងៃស្អែកវិញ។

[១៤:០៥:២១]

ដោយសារតែស្ថានភាពសុខភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-264 មានសភាពមិនច្បាស់លាស់ អង្គជំនុំជម្រះបានបង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញយកដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ដែលមានរហស្សនាម 2-TCCP-232 មកបម្រុងនៅថ្ងៃស្អែក។ ហេតុដូចនេះ ប្រសិនបើនៅថ្ងៃស្អែក ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-264 មិនអាចផ្តល់សក្ខីកម្មបានទេនោះ ភាគីត្រូវត្រៀមឲ្យបានរួចរាល់នូវការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-232 នៅព្រឹកថ្ងៃស្អែក សូមភាគីជ្រាប និង អញ្ជើញចូលរួមតាមពេលកំណត់។

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា, លោកខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកទី២៥ សីហា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញសម្រាក៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:០៧ នាទី)*